ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



## មជ្ឈមណ្ឌល ឯកសារកោះថ្ម

◆ ពិព័រណ៍បង្ហាញពេលវេលាប្រវត្តិសាស្ត្រ ដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់សម្តេចតេជោ ហ៊ុន សែន ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខពិសេស ឆ្នាំ២០២៤

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខពិសេស ឆ្នាំ២០២៤

# មាតិកា


## ផ្នែកសំបុត្រ

- ពិព័រណ៍បង្ហាញពេលវេលាប្រវត្តិសាស្ត្រដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ .... ១

## ផ្នែកឯកសារ

- ប៊ិន បាន ហៅ បូ លេខា ស្រុកពាមជីលាំង .... ៩

## ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

- ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទស្សនកិច្ចមជ្ឈ-មណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ ........... ១១
- អនុព័ន្ធយោធាសហរដ្ឋអាមេរិកទស្សនកិច្ចមជ្ឈ-មណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ ......... ១៥
- គណ: ប្រតិភូខេត្តត្បូងឃ្មុំធ្វើទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ.... ១៦
- ដំណើរទស្សនកិច្ចសិក្សារបស់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមកកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម......... ២១
- សាមណនិស្សិត និស្សិត និងសាស្ត្រាចារ្យនៃពុទ្ធិកសកលវិទ្យាល័យ សម្តេចអគ្គមហាសេនា.... ២៦
- ប្រវត្តិឃុំគគីរនៅក្នុងរបបខ្មែរក្រហម ........ ៣០
- រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនមានពិការ ............... ៣៣
- រឿងរ៉ាវជីវិតរបស់ប្រជាជនក្នុងរបបខ្មែរក្រហមនៅភូមិបុស្សតាអឹម ..........................៣៧
- ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យសុខភាពបឋមជូន..... ៤០

## ផ្នែកវេទិកាពិភាក្សាសាធារណៈ

- មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីអំពី «របបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស» សម្រាប់សិស្សវិទ្យាល័យ ប៊ុនរ៉ានី .................... ៤៣




ប្រជាជនកម្ពុជាឈប់សម្រាកនៅក្រែក មុននឹងវិលត្រឡប់ទៅភូមិកំណើត បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


- មជ្ឈមណ្ឌលឯកសារកោះថ្ម ត្រួតពិនិត្យ និងវាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា... ៤៥
- វេទិកាអប់រំសហគមន៍ស្តីពីជីវិតរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្ទៀង............ ៤៨
- វេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀង .................... ៥៣

## ផ្នែកស្រាវជ្រាវរកគ្រួសារ

- រឿងរ៉ាវរបស់ ឯម មុី ក្នុងរបបខ្មែរក្រហម .. ៥៨


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ ៖** ផេង ពង្សរ៉ាស៊ី, ផាត ចាន់សុនិតា, ឡុង ដានី, ឈុំ រ៉ា, គាត ស្រីឡែន, វី ស៊ីថា, គឹម សុវណ្ណដានី និង សុភ័ក្ត្រ ភាណា **អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ពិព័រណ៍បង្ហាញពេលវេលាប្រវត្តិសាស្ត្រ

## ដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់សម្តេចតេជោ ហ៊ុន សែន ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧

ផេង ពង្សរ៉ាស៊ី



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិទស្សនកិច្ច មជ្ឈមណ្ឌលឯកសារកោះថ្ម នៅវេលាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។
( ស៊ាង ចិន្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅក្នុងពិធីរំឭកខួបលើកទី៤៣ នៃទិវាចងចាំពីដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់សម្តេចតេជោ ហ៊ុន សែន ដែលប្រារព្ធធ្វើឡើងកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ កន្លងមកនេះ មានការរៀបចំដាក់តាំងពិព័រណ៍បង្ហាញពេលវេលាជាប្រវត្តិសាស្ត្រមួយ ដែលមានរូបភាពចំនួន១០៧សន្លឹក, រូបគំនូរចំនួន៣៦ផ្ទាំង និងផែនទីចំនួន៦ផ្ទាំង នៅក្នុង «មជ្ឈមណ្ឌលឯកសារកោះថ្ម»។ មជ្ឈមណ្ឌលឯកសារកោះថ្មនេះ គឺផ្តើមចេញពីគំនិតរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា ទៀ បាញ់ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសនៃក្រសួងការពារជាតិ ជាមួយនឹងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងដំណើរកម្មសិក្សានៅតំបន់កោះថ្ម នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។

នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០ នាយឧត្តមសេនីយ៍ សោ សុខា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានធ្វើលិខិតស្នើសុំបន្ទប់



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិទស្សនកិច្ច មជ្ឈមណ្ឌលឯកសារកោះថ្ម នៅវេលាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រៀនចំនួន ២បន្ទប់ នៅក្នុងសាលាបឋមសិក្សាប៊ុនរ៉ានី ហ៊ុន សែន កោះថ្ម ស្ថិតនៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ សម្រាប់រៀបចំជាសារមន្ទីររក្សាទុកឯកសារស្រាវជ្រាវ ដោយសហការរៀបចំនិងប្រតិបត្តិជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ លិខិតពីឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពលើសំណើរសុំបន្ទប់សិក្សាចំនួន ២នេះ។

ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា រួមមាន ឡុង ដានី, ដេង ពងរ៉ាស៊ី, លី កុកឆាយ, សូ ហ្វារីណា, លឹម យ៉ុងហួត និងសុខ វណ្ណៈ បានរៀបចំដំឡើងផ្ទាំងពិព័រណ៍រូបថត និងរចនាមជ្ឈមណ្ឌលឯកសារកោះថ្មនេះឡើង។ ឯកសារពិព័រណ៍បង្ហាញពេលវេលាជាប្រវត្តិសាស្ត្រនេះយកចេញពី១) ឯកសារខ្មែរក្រហម ២) ឯកសារអាមេរិក និង៣) ឯកសារវៀតណាម និងរូបភាពទាំងឡាយ ផ្តើមចេញពីអ្នកថតរូបចំនួន៥រូប គឺ១) ម៉ៃ ឡាំ អ្នកថតរូបវៀតណាម, ២) ស៊ីល វ៉ាណាហ៊្វ័រ អ្នកថតរូបអាមេរិក ៣) ដេវីត ហ៊ិក អ្នកថតរូបអាមេរិក, ៤) ឆាំង យុ អ្នកថតរូបកម្ពុជា និង៥) ហ្គុនណា បឺយស្ត្រម អ្នកថតរូប ស៊ុយអែត និងរូបគំនូរទាំង៣៦ផ្ទាំង គូរដោយវិចិត្រករ អ៊ុត រឿន។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអ្នករៀបចំពិព័រណ៍នេះ ដើម្បីជាការចាប់ផ្តើមបង្កើតឲ្យមានមជ្ឈមណ្ឌលឯកសារកោះថ្ម សហការជាមួយក្រុមការងារវិមានឈ្នះ ឈ្នះ តំបន់ប្រវត្តិសាស្ត្រយោធានៃក្រសួងការពារជាតិ។ មជ្ឈមណ្ឌលឯក-សារកម្ពុជា និងក្រុមការងារប្រវត្តិសាស្ត្រយោធានឹងខិតខំពង្រឹងកិច្ចសហការឲ្យមានការសិក្សាឈ្វេងយល់ និងស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាឲ្យកាន់តែប្រសើរជាងសព្វថ្ងៃ សម្រាប់ជាចំណេះចេះដឹងដល់យុវជន យុវនារី ជំនាន់ក្រោយ។ មជ្ឈ-មណ្ឌលឯកសារកោះថ្មនេះ ក៏មានតួនាទីជាទីតាំងបណ្តោះអាសន្នសម្រាប់រៀបចំធ្វើ សារមន្ទីរក្រោមលំហមេឃមួយ នៅលើផ្ទៃដី នៅចំពីមុខសាលាបឋមសិក្សាកោះថ្ម។

រូបថតដែលបានដាក់តាំងបង្ហាញទាំងអស់ គឺជាបណ្តុំរូបថតបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។ រូបថតទាំងនេះ បង្ហាញដល់អ្នកទស្សនាអំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលចាប់ផ្តើមពីការធ្វើសង្គ្រាមនៅតាមព្រំប្រទល់កម្ពុជា-វៀតណាម ជាពិសេសនៅតំបន់កោះថ្ម ឃុំទន្លូង និងភូមិមួយចំនួន ក្នុងឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ), ការកកើត និងគ្រប់គ្រងប្រទេសទាំងស្រុងរបស់ខ្មែរក្រហម ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដែលបង្កឲ្យមានមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់ជីវិតប្រជាជនកម្ពុជាជាង២លាននាក់ និងហេដ្ឋារចនាសម្ព័ន្ធប្រទេសទាំងមូល, ដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបខ្មែរក្រហម និងជីវិតរស់នៅប្រចាំថ្ងៃ បន្ទាប់ពីរបបខ្មែរក្រហម ព្រមទាំងភស្តុតាងឧក្រិដ្ឋដែលបន្សល់ទុកពីរបបនេះ រហូតឈានដល់ការផ្តួចផ្តើមគំនិតបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ដើម្បីបង្រួបបង្រួមប្រទេសទាំងមូលដោយសន្តិភាពនិងសន្តិវិធី។

# ពិព័រណ៍រូបថតបង្ហាញពីសំណល់សង្គ្រាមទសវត្សរ៍ ៦០ ដល់ ៧០ នៅតំបន់កោះថ្ម ក្នុងឃុំដាំក្រវៀន





ឧទ្ធម្ភាគចក្រយោធារបស់អាមេរិក។
(ដេវីដ ហ៊ិក, ឆាំង យុ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិព័រណ៍ផ្នែកនេះ បង្ហាញពីការធ្លាក់ឧទ្ធម្ភាគចក្រយោធារបស់អាមេរិក និងមូលដ្ឋានទ័ពរបស់វៀតណាមខាងជើង ឬវៀតកុង នៅក្នុងទឹកដីឃុំដាំក្រវៀន ស្រុកមេមត់។ រូបឧទ្ធម្ភាគចក្រដែលកំពុងបន្ទាបខ្លួនចុះ មានឈ្មោះសម្គាល់ថា អេអេច-វ័នហ្គី កូប្រា បានធ្លាក់នៅចម្ងាយប្រមាណ១០០ម៉ែត្រ ភាគខាងលិចភូមិដងទង់ ឃុំដាំក្រវៀន នៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧០។ រូបថតមួយសន្លឹកទៀត ដែលអាចមើលឃើញថាជាប្រភេទឧទ្ធម្ភាគចក្រមានកង្ហារពីរមុខនិងក្រោយ មានឈ្មោះសម្គាល់ថា ជីនុក បានធ្លាក់នៅចំណុចខាងជើងភូមិដងទង់ ឃុំដាំក្រវៀន។ អ្នកភូមិបានប្រាប់ពីការធ្លាក់ឧទ្ធម្ភាគចក្រជីនុក ថាបានធ្លាក់នៅក្នុងឆ្នាំ១៩៧០។ រូបថតមួយសន្លឹកទៀតជាប្រភេទឧទ្ធម្ភាគចក្រអូអេច-៦ បានធ្លាក់នៅក្បែរស្រះទឹកមួយក្នុងភូមិរបងប្រុះ ឃុំដាំក្រវៀន ដែលមានចម្ងាយប្រមាណ៥០០ម៉ែត្រពីព្រំប្រទល់វៀតណាមក្នុងឆ្នាំ១៩៧០។ ចំណែករូបថតពីរសន្លឹកទៀតនៃផ្នែកនេះ បង្ហាញពីមូលដ្ឋានទ័ពរបស់វៀតណាមខាងជើង ដែលមានទីតាំងស្ថិតនៅចម្ងាយប្រមាណ១ពាន់៥រយម៉ែត្រ ប៉ែកខាងជើង ភូមិតាសោម និង៧គីឡូម៉ែត្រប៉ែកត្បូងសានភូមិតាសោម ឃុំដាំក្រវៀន ក្នុងទឹកដីប្រទេសកម្ពុជា។ មូលដ្ឋានទាំងពីរនេះ ត្រូវបានសាងសង់ឡើងក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០។ រូបថតបង្ហាញពីទាហានរបបសាធារណរដ្ឋខ្មែរវ័យជំទង់ពីររូប ឈរស្ពាយគ្រាប់ និងកាំភ្លើងនៅសងខាងស្ត្រីអ្នកកាសែត ដែលជាជនជាតិអាមេរិក គឺជាមូលដ្ឋានទ័ពមួយត្រូវបានប្រើប្រាស់ជាមន្ទីរ១០០របស់ខ្មែរក្រហម ក្នុងឆ្នាំ១៩៦៣ដល់ឆ្នាំ១៩៦៥។

អ្នកថតរូប និងជាអ្នកកាសែតរូបនេះមានឈ្មោះថា ស៊ីលវ៉ាណា ហ្វ័រ គឺជាអតីតអ្នកឆ្លើយឆ្លងព័ត៌មានបរទេស និងអ្នកជំនាញកិច្ចការសាធារណៈ។ គាត់គឺជាស្ត្រីដំបូងដែលបម្រើការជានិពន្ធនាយករបស់ទីភ្នាក់ងារសារព័ត៌មានអន្តរជាតិដ៏ធំមួយនៃបណ្តាញទូរទស្សន៍អាមេរិក និងជាស្ត្រីដំបូងបង្អស់ដែលបម្រើការជាអ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ។ នៅខែមេសា ឆ្នាំ១៩៧៣ លោកស្រីត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជា ដោយសារតែលោកស្រីបានធ្វើសេចក្តីរាយការណ៍ អំពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ចំពោះសកម្មភាពទម្លាក់គ្រាប់បែកនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍របស់លោកស្រីបានធ្វើឲ្យព្រឹទ្ធសភាអាមេរិក ចេញបញ្ជាឲ្យបញ្ឈប់ជាបន្ទាន់នូវការទម្លាក់គ្រាប់បែកនៅកម្ពុជា។ បច្ចុប្បន្ន លោកស្រីរស់នៅក្នុងប្រទេសអ៊ីស្រាអែល។

# ពិព័រណ៍រូបថតបង្ហាញពីជីវិតក្នុងរបប ប៉ុល ពត



រូបថតក្នុងអំឡុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតជាច្រើនសន្លឹកក្នុងផ្នែកនេះ បង្ហាញពីប្រជាជនកម្ពុជា ទាំងចាស់ ទាំងក្មេង ធ្វើការងារពលកម្មលើកទំនប់ ជីកប្រឡាយធ្វើស្រែ កសាងប្រព័ន្ធធារាសាស្រ្ត និងកំណែនកុមារា និងកុមារី ឲ្យធ្វើជាកងទ័ពចូលប្រយុទ្ធក្នុងសមរភូមិប្រឆាំងនឹងកងទ័ពវៀតណាម។ ពុំមានរូបថតមួយសន្លឹកណាទេ ដែលបង្ហាញពីការយកចិត្តទុកដាក់របស់ខ្មែរក្រហមក្នុងវិស័យអប់រំ។ ក្មេងៗ និងយុវជន យុវនារី ត្រូវបង្ខំឲ្យធ្វើការងារពលកម្មស្រែចម្ការ និងបង្ខំឲ្យចូលរួម ប្រយុទ្ធនៅក្នុងសមរភូមិ។ សម្លៀកបំពាក់ខ្មៅ គឺជាឯកសណ្ឋានដែលសម្គាល់ពីភាពស្មើភាពគ្នា គ្មានវណ្ណៈសង្គម និងសមូហភាព។ ការងារពលកម្ម និងធ្វើស្រែចម្ការ គឺជាទិសដៅកំណត់ពីអង្គការថ្នាក់លើ ដើម្បីឈានដល់ការអភិវឌ្ឍន៍ប្រទេសឲ្យក្លាយទៅជាប្រទេស ដែលមានវិស័យកសិកម្មជឿនលឿនលើសាកលលោក។ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមបាននាំប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងសោកនាដកម្មយ៉ាងធ្ងន់ធ្ងរ ដែលបណ្ដាលឲ្យបាត់បង់ជីវិតប្រជាជនកម្ពុជាប្រមាណជាងពីរលាននាក់។ មេដឹកនាំកំពូលៗនៃរបបនេះ ត្រូវបាននាំខ្លួនមកកាត់ទោសពីបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត គឺបីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ រូបថតទាំងអស់នេះ ថតក្នុងឆ្នាំ១៩៧៧ និង១៩៧៨ ដោយអ្នកថតរូបខ្មែរក្រហមមិនស្គាល់ឈ្មោះម្នាក់ និងអ្នកសារព័ត៌មានជនជាតិស៊ុយអែតឈ្មោះ ហ្គុនណា បឺយស្រ្តម និងមានតម្កល់នៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ហ្គុនណា បឺយស្រ្តម បានមកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យក្នុងខែសីហា ឆ្នាំ១៩៧៨។ គាត់គឺជាអ្នកគាំទ្រខ្មែរក្រហមម្នាក់លើវិស័យនយោបាយ សង្គម និងសេដ្ឋកិច្ច។ ហ្គុនណា បឺយស្រ្តម ធ្លាប់ជួបដោយផ្ទាល់ជាមួយ ប៉ុល ពត ហើយគាត់ត្រូវបានបំផុសគំនិតថា ការកសាងសង្គមមួយ គឺត្រូវពឹងផ្អែកលើភាពឯករាជ្យម្ចាស់ការ និងសមភាព។ នៅឆ្នាំ២០០៨ និងឆ្នាំ២០១៦ ហ្គុនណា បឺយស្រ្តម បានមកទស្សនកិច្ចប្រទេសកម្ពុជា ដើម្បីធ្វើការសុំទោសជាសាធារណៈដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបានបង្រៀនដល់ក្មេងៗជំនាន់ក្រោយឲ្យខិតខំថែរក្សា និងចងចាំពីប្រវត្តិសាស្រ្តខ្លួនឯងក្នុងន័យទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យកើតឡើងម្ដងទៀត។ ហ្គុនណា បឺយស្រ្តម សព្វថ្ងៃនេះរស់នៅទីក្រុងស្តុកឃម ប្រទេសស៊ុយអែត។



រូបថតក្នុងអំឡុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិព័រណ៍រូបថត និងរូបភាពបច្ចាញពីដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់ សម្តេចតេជោ ហ៊ុន សែន ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧

រូបថត និងរូបគំនូរដែលមាននៅក្នុងផ្នែកនេះ គឺជាដំណើរដ៏គ្រោះថ្នាក់របស់សម្តេចតេជោ ហ៊ុន សែន កាលពីពាក់កណ្តាលឆ្នាំ១៩៧៧ ឆ្ពោះទៅកាន់ប្រទេសវៀតណាម ក្នុងគោលបំណងប្រមូលកម្លាំងអ្នកតស៊ូស្នេហាជាតិ ដើម្បីវាយរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ គឺជាថ្ងៃដែលសម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្តដ៏ស្មោះស្ម័គ្រ៤រូបទៀត សម្រេចចិត្តរត់ចេញទាំងក្តីបារម្ភបំផុត ពីបន្ទាយកោះថ្ម ស្ថិតក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម ដែលជាទីតាំងបន្ទាយឈរជើងរបស់សម្តេចតេជោ ហ៊ុន សែន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សម្តេច តេជោ ហ៊ុន សែន និងយុទ្ធមិត្ត បានធ្វើដំណើរឆ្លងកាត់អូរតូចមួយ ប៉ុន្តែនៅក្នុងមហិច្ឆតាដ៏ធំបំផុត ក្នុងតំបន់អាងកាច់ ដែលខណ្ឌចែកព្រំដែននៃប្រទេសទាំងពីរ ឆ្ពោះទៅកាន់ទឹកដីវៀតណាម។ នៅក្នុងទឹកដីវៀតណាម សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្តបានលាក់អាវុធ និងសម្ភារផ្សេងៗ រួចធ្វើដំណើរដោយថ្មើរជើងចូលទៅកាន់ភូមិមួយ ជាទីកន្លែងដែលសម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្តទទួលបានការស្វាគមន៍រាក់ទាក់ពីប្រជាជនវៀតណាម មុនពេលដែលប្រជាជនវៀតណាមទាំងនោះនាំសម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្តទាំងអស់ ទៅកាន់ទីស្នាក់ការឃុំរបស់វៀតណាម។ សម្តេចតេជោ ហ៊ុន សែន ត្រូវបានភាគីវៀតណាមសួរចម្លើយជាលើកទីមួយនៅទីនោះ។ បន្ទាប់មក សម្តេចតេជោ ហ៊ុន សែន ត្រូវបានបញ្ជូនទៅកាន់ស្រុកមិញភៀក ជាទីកន្លែងដែលសម្តេចត្រូវសួរចម្លើយម្តងទៀតពីកម្មាភិបាលថ្នាក់ស្រុក។ នៅឆ្នាំ១៩៧៨ សម្តេចតេជោ ហ៊ុន សែន បានក្លាយជាសមាជិកស្ថាបនិកនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ ដោយមានការសហការជាមួយចលនាស្នេហាជាតិនានា និងការគាំទ្រពីកងកម្លាំងស្ម័គ្រចិត្តវៀតណាម រណសិរ្សបានសង្គ្រោះប្រទេស និងប្រជាជនកម្ពុជាទាំងស្រុងនៅថ្ងៃទី៧ ខែ មករា ឆ្នាំ១៩៧៩។





រូបគំនូរអំពីដំណើររបស់សម្តេចតេជោ ហ៊ុន សែន ឆ្ពោះទៅប្រទេសវៀតណាម កាលពីពាក់កណ្តាលឆ្នាំ ១៩៧៧។ (អ៊ុត រឿន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបគំនូរពីដំណើរឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់សម្តេចតេជោ គូរដោយវិចិត្រករ អ៊ុត រឿន។ លោក អ៊ុត រឿន បានចាប់ផ្តើមគូរគំនូរដំបូង នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ លោកបានបោះពុម្ពសៀវភៅគំនូររឿង ព្រះថោង នាងនាគ, ធនញ្ជ័យ និងទុំទាវ។ ក្នុងរបបខ្មែរក្រហម លោកត្រូវបានខ្មែរក្រហមតម្រូវឲ្យគូរគំនូរស្តីអំពី«ផែនការសាងសង់សម្រាប់អង្គការបដិវត្តន៍»។ លោក អ៊ុត រឿន បានចូលនិវត្តន៍នៅឆ្នាំ២០០១។ បច្ចុប្បន្ន លោកគឺជាវិចិត្រករនៅវិមាន ឈ្នះ ឈ្នះ។

## ពិព័រណ៍រូបថតបង្ហាញពីការវិលត្រឡប់មកស្រុកភូមិវិញក្នុងឆ្នាំ១៩៧៩ បន្ទាប់ពីការដួលរលំរបប ប៉ុល ពត


ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតបន្ទាប់ពីរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។
(ឌិញ ហុង និងហូ វ៉ាន់តាយ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតទាំងអស់នៅក្នុងផ្នែកនេះ ដែលត្រូវបានថតឡើងក្នុងឆ្នាំ១៩៧៩ និង១៩៨០ ដោយអ្នកថតរូបជនជាតិវៀតណាមពីររូបគឺ ឌិញ ហុង និង ហូ វ៉ាន់តាយ បង្ហាញពីជ័យជម្នះលើរបបខ្មែរក្រហម តាមរយៈការចូលដល់ទីក្រុងភ្នំពេញរបស់កងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងកម្លាំងស្ម័គ្រចិត្តវៀតណាម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ និងការរស់ឡើងវិញរបស់ប្រជាជនកម្ពុជា។ បន្ទាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាប្រមាណ៥លាននាក់ ដែលភាគច្រើនជាកុមារ និងស្ត្រីមេម៉ាយ បានរួចរស់ជីវិតពីរបបខ្មែរក្រហម និងបានវិលត្រឡប់មកកាន់ស្រុកកំណើតរបស់ខ្លួនវិញ។ រូបថតបានបង្ហាញពីការធ្វើដំណើរដោយឥតគោលដៅ ប៉ុន្តែប្រកបដោយក្តីសង្ឃឹមថ្មី និងជីវិតវេទនារបស់ក្មេងកំព្រា, ការវិលត្រឡប់មកកាន់ស្រុកកំណើតរបស់ប្រជាជនដោយគ្មានស្បែកជើង និងការបង្ហាញពីស្លាកស្នាមធ្វើទារុណកម្មរបស់ខ្មែរក្រហម ព្រមទាំងពិការភាពដែលបន្សល់ទុកដោយខ្មែរក្រហម។

ឌិញ ហុង និង ហូ វ៉ាន់តាយ គឺជាអតីតអ្នកថតភាពយន្តឯកសារ «គុកទួលស្លែង» ដំបូងបង្អស់នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩។ អ្នកទាំងពីរ បានចូលទៅកាន់គុកទួលស្លែង តាមរយៈក្លិនស្អុយរបស់សាកសព និងបានថតរូបជាច្រើនសន្លឹកពីទិដ្ឋភាពក្នុងគុក ព្រមទាំងបានជួយសង្គ្រោះក្មេងកំព្រា៥នាក់ ដែលឪពុកម្តាយត្រូវបានសម្លាប់ដោយខ្មែរក្រហម។ សព្វថ្ងៃ ហូ វ៉ាន់តាយ រស់នៅសង្កាត់ ប៊ិញថាញ់។

## ពិព័រណ៍រូបថតបង្ហាញពីរូបភាពបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍


អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហម។
(ដេវីត ហ៊ក, ឆាំង យុ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតច្រើនសន្លឹកនៅក្នុងផ្នែកនេះ បង្ហាញពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា ក្នុងរយៈពេលនៃការកាន់កាប់ប្រទេសពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ថ្វីត្បិតតែមានប្រជាជនកម្ពុជាជាច្រើននាក់បានស្លាប់ដោយសារជំងឺ ហូបមិនគ្រប់គ្រាន់ ធ្វើការហួសកម្លាំង និងធ្វើទារុណកម្មក៏ដោយ ក៏នៅមានប្រជាជនកម្ពុជាជាច្រើននាក់ផ្សេងទៀតត្រូវបានសម្លាប់ក្រោមរូបភាពធ្វើបន្សុទ្ធកម្មដើម្បីស្វែងរកសមាសភាពក្បត់នឹងអង្គការបដិវត្តន៍ ដូចជា

គិញសម្ងាត់ សេអ៊ីអា របស់អាមេរិក គិញសម្ងាត់កាហ្សេបេ របស់រុស្ស៊ី និងទាហាននិងមន្ត្រីរដ្ឋការរបស់របបសាធារណរដ្ឋខ្មែរជាដើម។ ខ្មែរក្រហមបានបង្កើតឲ្យមានមន្ទីរសន្តិសុខបុគ្គុក ចំនួន១៩៧ កន្លែង ដើម្បីឃុំឃាំង ធ្វើទារុណកម្ម សួរចម្លើយអ្នកទោស និងសម្លាប់។ មន្ទីរសន្តិសុខទាំងនោះ បានប្រព្រឹត្តឡើងជាលក្ខណៈប្រព័ន្ធ ចាប់តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់មជ្ឈិម (មន្ទីរ ស-២១)។ នៅដើមឆ្នាំ១៩៨០ ឆ្អឹងលលាដ៍ក្បាល ឆ្អឹងដងខ្លួន និងឆ្អឹងអវយវៈរបស់ជនរងគ្រោះ ត្រូវបានប្រមូលទុកដាក់នៅក្នុងស្តូប ឬចេតិយក្នុងបរិវេណវត្តអារាមនៅតាមទីកន្លែងដែលស្ថិតនៅជិតៗកន្លែងសម្លាប់ ដើម្បីធ្វើជាភស្តុតាង និងសម្រាប់ធ្វើបុណ្យតាមប្រពៃណីសាសនា។ នៅថ្ងៃ២០ ខែឧសភា រៀងរាល់ឆ្នាំ ប្រជាជនកម្ពុជាទូទាំងប្រទេស តែងតែធ្វើពិធីបង្សុកូលគោរពដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ទៅក្នុងរបបខ្មែរក្រហម។

រូបថតទាំងអស់នេះ ថតដោយ ម៉ៃ ឡាំ នៅក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩។ ម៉ៃ ឡាំ បានមកដល់ប្រទេសកម្ពុជា ប្រហែលនៅក្នុងខែកុម្ភៈ ឬ មីនា ឆ្នាំ១៩៧៩ ក្នុងតួនាទីជាវរសេនីយ៍ឯករបស់កងទ័ពវៀតណាម។ គាត់មានចំណេះដឹងផ្នែកច្បាប់ជ្រៅជ្រះ និងមានជំនាញខាងរៀបចំ និងប្រតិបត្តិសារមន្ទីរបែបវិទ្យាសាស្ត្រ។ ម៉ៃ ឡាំ បានទទួលភារកិច្ចដ៏សំខាន់មួយ ក្នុងការរៀបចំឯកសារទាំងអស់ដែលត្រូវបានរកឃើញនៅក្នុងមន្ទីរ ស-២១ ឲ្យទៅជាសារមន្ទីរមួយ ដែលមានឈ្មោះហៅថា «សារមន្ទីរនៃសុបិនអាក្រក់របស់កម្ពុជា»។ កិច្ចការរបស់គាត់គឺជាកិច្ចការដ៏មានតម្លៃ និងជាភស្តុតាងក្នុងការបង្កើតតុលាការប្រជាជនបដិវត្តន៍កម្ពុជាក្នុងខែសីហា ឆ្នាំ១៩៧៩ ដើម្បីកាត់ទោស ប៉ុល ពត និងអៀង សារី ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

## ពិព័រណ៍រូបថតបង្ហាញពីរូបភាពជីវិតប្រចាំថ្ងៃរនៅទសវត្សរ៍៨០



ប្រជាជនកម្ពុជាក្នុងកំឡុងទសវត្សរ៍ ៨០។
(ដេវីត ហ៊ិក, ឆាំង យុ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតប៉ុន្មានសន្លឹកនៅក្នុងផ្នែកនេះ ដែលថតដោយ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រវត្តិវិទូសញ្ជាតិអាមេរិក ដេវីត ហ៊ិក បង្ហាញពីផ្នែកសំខាន់ៗចំនួនបួនគឺ ការចរាចរណ៍ទីផ្សារ និងវិស័យគមនាគមន៍, ការស្តារឡើងវិញនូវវិស័យព្រះពុទ្ធសាសនា និងការមិនរើសអើងពូជសាសន៍, សេរីភាពក្នុងការប្រកបការងារ និងរស់រានមានជីវិត, និងការចាប់ផ្តើមឡើងវិញនៃវិស័យអប់រំ។ រយៈពេលជាង៤០ឆ្នាំក្រោយរបបខ្មែរក្រហម កម្រងរូបថតទាំងនេះ ក្លាយជាកម្រងរូបថតអនុស្សាវរីយ៍ដែលមិនអាចបំភ្លេចបាន និងជាផ្នែកមួយនៃដំណើរការស្វែងរកយុត្តិធម៌សម្រាប់សង្គមកម្ពុជានាពេលបច្ចុប្បន្ន។ លោក ឆាំង យុ បានមានប្រសាសន៍ថា «ការចងចាំពីអំពើប្រល័យពូជសាសន៍នៅតែជាផ្នែកមួយនៃអត្តសញ្ញាណរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន និងជាច្រើនជំនាន់ទៀតទៅថ្ងៃអនាគត។ សង្គមមួយមិនអាចស្គាល់ខ្លួនឯងបានទេ ប្រសិនបើសង្គមនោះពុំមានការចងចាំច្បាស់លាស់អំពីប្រវត្តិសាស្ត្ររបស់

ខ្លួន» ។ ប្រវត្តិវិទូ ដេវីត ហ៊ិក បានអធិប្បាយថា «អ្នករស់រានមានជីវិត ក្រោយរបបខ្មែរក្រហមជាច្រើន បានព្យាយាមកប់ចោលនូវអតីតកាលរបស់ខ្លួន ប៉ុន្តែវានៅតែជាអតីតកាល និងជាអត្តសញ្ញាណរបស់ខ្លួនជានិច្ច។ ប្រជាជនខ្មែរដែលកើតក្រោយរបបខ្មែរក្រហម បានព្យាយាមឈ្វេងយល់អំពីមូលហេតុដែលបណ្តាលឲ្យសោកនាដកម្មក្នុងអតីតកាលកើតមានឡើង ឬអ្នកទាំងនោះប្រហែលជានៅមានមន្ទិលសង្ស័យថា តើសោកនាដកម្មទាំងនោះបានកើតឡើងពិតមែនឬយ៉ាងណា»។

ប្រវត្តិវិទូ ដេវីត ហ៊ិក គឺជាអ្នកប្រមែប្រមូលឯកសារខ្មែរក្រហមដំបូងបង្អស់ និងបានបង្កើតគណៈកម្មការមួយដើម្បីប្រមូល រៀបចំ ថែរក្សា និងចងក្រងឯកសារខ្មែរក្រហមនៅកម្ពុជា ក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០។ កិច្ចការស្រាវជ្រាវរបស់លោកទៅលើប្រវត្តិសាស្ត្រខ្មែរក្រហម បានបង្ហាញថា ប្រជាជនកម្ពុជាប្រមាណពីមួយលានទៅបីលាននាក់ ក្នុងចំណោមប្រជាជនសរុប ប្រាំពីរលាននាក់ ត្រូវបានសម្លាប់ ហើយវប្បធម៌ទាំងមូលត្រូវបានបំផ្លិចបំផ្លាញជាប្រព័ន្ធ។ លោក ដេវីត ហ៊ិក ក៏ដូចជាលោក ឆាំង យុ សព្វថ្ងៃអ្នកទាំងពីរ ផ្តោតការស្រាវជ្រាវមួយផ្នែកធំនៅក្នុងប្រទេសកូរ៉េខាងជើង និងប្រទេសភូមា។

## ពិព័រណ៍រូបថតបង្ហាញពីរូបសម្តេចតេជោ ហ៊ុន សែន ដែលចាប់ផ្តើមគិតពីគោលនយោបាយ ឈ្នះ ឈ្នះ

រូបថតសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងនៅក្នុងរដ្ឋសភាជាតិ ក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ការដដែក ពិភាក្សារបស់សម្តេច គឺបានផ្តោតសំខាន់ទៅលើការផ្តួចផ្តើមគំនិត ក្នុងការបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ ដែលនាំទៅដល់ការបង្រួបបង្រួមជាតិទាំងមូល រវាងក្រុមខ្មាំងផ្តាច់ខ្លួនខ្មែរក្រហម និងរដ្ឋាភិបាលកម្ពុជា ដោយសន្តិភាព និងសន្តិវិធី កាលពីឆ្នាំ១៩៩៨។

ពិព័រណ៍នេះ គឺជាផ្នែកមួយនៃការផ្សារអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់មជ្ឈមណ្ឌលឯក-សារកម្ពុជា នៅតាមបណ្តាខេត្តដទៃទៀតនៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ រំពឹងថា ក្រុមប្រវត្តិសាស្ត្រយោធា នឹងខិតខំពង្រឹងកិច្ចសហការជាមួយមជ្ឈ-មណ្ឌលឯកសារកម្ពុជា បន្តការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះឲ្យកាន់តែច្បាស់លាស់ជាងមុន ដើម្បីជាចំណេះចេះដឹងរបស់កូនខ្មែរជំនាន់ក្រោយៗទៀត មិនឲ្យភ្លេចពីវិនាសកម្មដ៏ជូរចត់ក្នុងប្រវត្តិសាស្ត្រកម្ពុជា។



សម្តេចតេជោ ហ៊ុន សែន នៅប្រទេសស៊ុយអែត ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៊ិន បាន ហៅ បូ លេខាស្រុកពាមជីលាំង តំបន់២១ ភូមិភាគបូព៌ា

**ផាត ចាន់សុនិតា**



យោធាខ្មែរក្រហមកំពុងដើរនៅសមរភូមិតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៊ិន បាន ហៅ បូ អាយុ៣៨ឆ្នាំ នៅឆ្នាំ១៩៧៧។ ខ្ញុំមានស្រុកកំណើតនៅភូមិខាងលិចវត្ត ឃុំប៉ើស ទី២ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៦៧ ខ្ញុំបានសឹកពីព្រះសង្ឃមកនៅផ្ទះជួយធ្វើស្រែឪពុកម្តាយ។ ថ្ងៃមួយនៅពេលខ្ញុំកំពុងភ្ជួរស្រែ អ្នកជិតខាងរបស់ខ្ញុំឈ្មោះ លីម បានមកសួរនាំអំពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្ញុំ។ ខ្ញុំក៏បានប្រាប់ទៅ លីម ថា ជីវភាពរស់នៅរបស់ខ្ញុំមានការខ្វះខាតណាស់។ ពុ ដូច្នេះ លីម ក៏បានបញ្ចុះបញ្ចូលខ្ញុំឲ្យធ្វើជាគិញស៊ើប-ការណ៍អំពីបដិវត្តន៍ដោយឲ្យប្រាក់ខែខ្ញុំ៣០០រៀលក្នុងមួយខែ។ មួយឆ្នាំក្រោយមក ខ្ញុំបានទាក់ទងជាមួយចៅហ្វាយស្រុកក្រូចឆ្មារ ឈ្មោះ វ៉ង់ ម៉េង ហើយខ្ញុំបានឡើងធ្វើជាមេឃុំប៉ើស ក្នុងឆ្នាំ១៩៧០។ ចាប់តាំងពីខ្ញុំធ្វើជាមេឃុំនៅប៉ើសមក បង ឆោម សារ៉ាត លេខាស្រុកឆ្លូង បានពន្យល់ណែនាំខ្ញុំថា កម្លាំងបដិវត្តន៍មិនអាចយកជ័យជម្នះលើកម្លាំងទ័ពដែលមានសហរដ្ឋអាមេរិកជាអ្នកគាំទ្របានទេ។ ដូចច្នេះ ទិសដៅរបស់ក្រុមយើង គឺត្រូវតែប្រឆាំងបដិវត្តន៍ ប៉ុន្តែពេលនេះយើងធ្វើការដើម្បីបង្កប់ស៊ីរូងផ្ទៃក្នុងរដ្ឋអំណាចក្នុងការធ្វើសកម្មភាពប្រឆាំងបដិវត្តន៍។

នៅឆ្នាំ១៩៧១ ខ្ញុំបានផ្លាស់មកធ្វើជាប្រធានឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារវិញ។ ក្រោយមកទៀត ក្នុងឆ្នាំ១៩៧២ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានមន្ទីរកសិកម្មតំបន់២១ ភូមិភាគបូព៌ា។ នៅឆ្នាំ១៩៧៤ ម៉ែ ជូ បានចាត់តាំងខ្ញុំឲ្យចុះតាមស្រុកដើម្បីធ្វើការសម្រិតសម្រាំងអ្នកស្មោះត្រង់បដិវត្តន៍ចេញពីសមាគមកសិករឲ្យអស់។ ពេលនោះ ខ្ញុំបានចុះទៅស្រុកត្បូងឃ្មុំ និងស្រុកតំបែរ។ នៅខែមិថុនា ឆ្នាំ

១៩៧៥ ខ្ញុំបានធ្វើជាលេខាស្រុកពាមជីលាំង។ នៅ
ខែសីហា ឆ្នាំដដែល មានការប្រជុំមួយនៅក្បែរផ្សារ
ជប់ចាស់ ដែលមានអ្នកចូលរួម៖ ចាន់, មុន, លីដែន,
ប៊ុន សានី, ម៉ែ ដូ, ចក្រី, ឆោម សាវ៉ាត, ជុំ, ផា និងអ្នក
ផ្សេងទៀត។ ខ្លឹមសារនៃកិច្ចប្រជុំនោះបានលើក
ឡើងអំពីការរៀបចំ ឡាន, កាណូត, គ្រាប់រំសេវ,
អាវុធ, ថ្នាំពេទ្យ, ស្បៀង ដើម្បីត្រៀមវាយផ្តួលរំលំ
បក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី៣០ ខែកញ្ញា ១៩៧៥
ដោយមានវៀតណាមជាអ្នកជួយគាំទ្រ។ ប៉ុន្តែនៅ
ពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៥ បន្ទាប់ពីខ្ញុំបានជួប
បងចាន់ បងចាន់បានណែនាំខ្ញុំឲ្យពន្យាសកម្មភាពធ្វើ
រដ្ឋប្រហារសិន ដោយរក្សាទុកអាវុធនៅដដែល។
នៅដើមឆ្នាំ១៩៧៦ ខ្ញុំបានទៅជួប បងចាន់ នៅមន្ទីរ
សេដ្ឋកិច្ចភូមិភាគបូព៌ា ដើម្បីស្នើសុំកម្លាំងនៅពាម
ជីលាំងបន្ថែម។ កងកម្លាំងដែលស្នើសុំទាំងនោះ
រួមមាន សុត ប្រធានឃុំកំពង់ទ្រាស, វុទ្ធី សមាជិកឃុំ,
ម៉ោង ប្រធានឃុំសំរោង, ហុង ប្រធានឃុំពាមជីលាំង,
ថុន ប្រធានឃុំបឹងព្រួល, ផាត ប្រធានឃុំជីរោទ៍ទី១ និង
ស៊ា ប្រធានឃុំថ្មពេជ្រ។ បន្ទាប់មក បងចាន់ ណែនាំឲ្យ
ខ្ញុំចុះ ទាក់ទងខ្មែរក្បត់ ដើម្បីបំផុសធ្វើវិច្ឆេទកម្ម ទូទៅ
នៅក្នុងតំបន់២១ ដូចជា ទម្លាយទំនប់, លាក់ស្រូវទុក,
បង្អត់ជីវភាពរស់នៅរបស់ប្រជាជន និងបង្ខំប្រជាជន
ឲ្យធ្វើការជាទម្ងន់។ នៅចុងឆ្នាំ១៩៧៦ មានកិច្ចប្រជុំ
នៅសេនាធិការភូមិភាគបូព៌ា ដោយមានអ្នកចូលរួម
ដូចជា ម៉ុន, ផន ប្រធានកងពលលេខ៤ របស់ភូមិ
ភាគបូព៌ា, ប៉ូលី វ៉ាន់ លេខាស្រុកសំរោងតំបន់២៣,
ធុច អនុលេខាតំបន់២៣, ម៉ែដូ, គីម, ជុំ, វ៉ែន ហុន,
ផា និង ឆោម សាវ៉ាត។ ខ្លឹមសារនៃកិច្ចប្រជុំគឺ ដើម្បី
ត្រៀមខ្លួនអនុវត្តផែនការវាយប្រហារភ្លាមៗទៅលើ
បក្សកុម្មុយនីស្តកម្ពុជា នៅថ្ងៃទី៨ ខែមករា ឆ្នាំ
១៩៧៧។ មួយវិញទៀត កិច្ចប្រជុំនេះធ្វើឡើងដើម្បី
ត្រៀមបោះខិត្តប័ណ្ណប្រកាសឲ្យប្រជាជនដឹងមុនពេល
ធ្វើរដ្ឋប្រហារ ហើយផ្តល់ព័ត៌មានទាំងនេះទៅឲ្យខ្មែរ
បណ្តាញរបស់បក្ខពួកក្បត់។ ចាត់តាំង ទុយ គណៈ
យោធាស្រុកពាមជីលាំងត្រៀមអាវុធ១២០ដើម។
ប៉ុន្តែ ក្រោយមកទៀត ផែនការធ្វើរដ្ឋប្រហារនេះក៏
ត្រូវអាក់ខានវិញ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៧ បងចាន់
បានបើកកិច្ចប្រជុំមួយដើម្បីខ្ទេសនាមអំពីមូលហេតុ
ដែលមិនបានអនុវត្តផែនការធ្វើរដ្ឋប្រហារនេះ គឺ
ដោយសារ ធុច និង ប៉ូលី វ៉ាន់ ដែលជាខ្មែរទាក់ទង
ជាមួយវៀតណាម ត្រូវអង្គការចាប់ខ្លួន ហើយខ្មែរ
ទាក់ទងនីរសារពីតំបន់មួយទៅតំបន់មួយក៏ដាច់
ទំនាក់ទំនងទៀត។ ដូច្នេះមានតែរក្សាការសម្ងាត់
ហើយលើកផែនការធ្វើរដ្ឋប្រហារនេះទៅថ្ងៃទី១៥
ខែមេសា ឆ្នាំ១៩៧៧ វិញ។ ប្រសិនបើកម្លាំងទ័ពក្បត់
ណាបាក់ទ័ពត្រូវរត់ទៅប្រទេសវៀតណាម ចំណែក
កម្លាំងក្បត់ដែលមិនទាន់បាក់ទ័ព ឬបែកការណ៍ទេគឺ
ត្រូវនៅបង្កប់ខ្លួនបន្តទៀត។

ក្រោយមក បងម៉ុន បានសរសេរសំបុត្រហៅខ្ញុំ
ទៅជួបនៅសេនាធិការយោធាភូមិភាគ។ ខ្ញុំក៏បានទៅ
ជួប គីម ផា, ម៉ែ ដូ, ភន សោម, ជុំ ផន និង ហន់។ បង
ម៉ុន បានរាយការណ៍អំពីសភាពការណ៍ដែលអង្គការ
កំពុងតែចាប់ខ្មែរក្បត់ជាច្រើននៅភូមិភាគបូព៌ា ហើយ
គាត់បានពន្យារពេលធ្វើសកម្មភាពដោយលើកទៅ
ខែឧសភា ឆ្នាំ១៩៧៧ វិញ។ ចំពោះសកម្មភាពដែល
ក្រុមខ្ញុំត្រូវធ្វើបន្តទៀត គឺប្រឆាំងមាគ៌ាកសាងប្រទេស
របស់បក្ស ដើម្បីរួមចំណែកធ្វើឲ្យបក្សបរាជ័យក្នុង
ពេលឆាប់ៗ តាមរយៈការធ្វើសកម្មភាពដូចជា បង្ក
ទំនាស់ក្នុងសហករណ៍ ក្នុងជួរកងទ័ព ធ្វើវិច្ឆេទកម្ម
បំផ្លាញទំនប់ និងបំផ្លាញស្រូវជាដើម។

បន្ទាប់ពីការប្រជុំលើកនេះរួច ខ្ញុំក៏បានចុះតាម
មូលដ្ឋានចាត់ចែងដឹកនាំខ្មែរបណ្តាញក្បត់ឲ្យធ្វើ
សកម្មភាពជាបន្តបន្ទាប់។ ក្រោយមកទៀត សកម្មភាព
ប្រឆាំងបដិវត្តន៍របស់ខ្ញុំបានបែកការណ៍ ហើយខ្ញុំក៏ត្រូវ
អង្គការចាប់ខ្លួននៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ ៖ អត្ថបទនេះដកស្រង់ចេញពី
ឯកសារចម្លើយសារភាពលេខ J00515។ រាល់
ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរ
សន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និង
ធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។
ដូច្នេះយើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាព
របស់ប៊ិនបាន ហៅ បូ ពិតប្រាកដឬយ៉ាងណានោះទេ។**

# ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ

ឡុង ដានី



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាលោក ប៉ាទ្រីក មូហ្វី និងគណៈប្រតិភូបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅវេលាម៉ោង១១ព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ។ ( សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅវេលាម៉ោង១១ព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០២១ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាលោក ប៉ាទ្រីក មូហ្វី (Patrick Murphy) និងគណៈប្រតិភូបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។

ដើម្បីអនុវត្តវិធានការរបស់ក្រសួងសុខាភិបាល គណៈប្រតិភូ និងអ្នកចូលរួមទាំងអស់បានពាក់ម៉ាស់ លាងដៃជាមួយអាកុល និងរក្សាគម្លាត ដើម្បីការពារការឆ្លងរាលដាលជំងឺកូវីដ១៩។ វត្តមានចូលរួមទទួលស្វាគមន៍លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងគណៈប្រតិភូរួមមាន៖ លោក ញឹក នៅ អភិបាលរងនៃគណៈអភិបាលស្រុកមេមត់ ខេត្តត្បូងឃ្មុំ លោក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឡុង ដានី អ្នកគ្រប់គ្រងនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងលោកគ្រូ អ្នកគ្រូសិស្សានុសិស្សចំនួន ២៥ រូប។ មុនការអញ្ជើញមកដល់របស់លោកឯកអគ្គ-រដ្ឋទូតអាមេរិក និងគណៈប្រតិភូ លោក ញឹក នៅ

បានមានមតិផ្តាំផ្ញើដល់សិស្សានុសិស្សឲ្យស្វែងយល់បន្ថែមអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលបានកើតឡើងនៅតំបន់កោះថ្ម ស្រុកមេមត់ និងសូមឲ្យសួរសំណួរច្រើនចំពោះលោកឯកអគ្គរដ្ឋទូត។ បន្ទាប់មកលោក ដេង ពង្សរ៉ាស៊ី បានធ្វើការពន្យល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសបានបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ ដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់។

នៅពេលលោកឯកអគ្គរដ្ឋទូត និងគណៈប្រតិភូអញ្ជើញមកដល់ លោកដេង ពង្សរ៉ាស៊ី និងលោក ឡុង ដានី បានធ្វើជាមគ្គុទ្ទេសក៍ក្នុងការនាំលោកឯកអគ្គរដ្ឋទូត និងគណៈប្រតិភូដើរទស្សនាការតាំងពិព័រណ៍នៃបណ្តុំរូបថត ដែលបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៦០ ដល់ទសវត្សរ៍ឆ្នាំ១៩៩០។ រូបថតទាំងអស់នោះបានបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាដោយចាប់ផ្តើមចេញពីតំបន់កោះថ្ម ឃុំទន្លូង និងតំបន់មួយចំនួននៃឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ រូបថតនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានធ្វើឲ្យប្រជាជនកម្ពុជាប្រមាណ ២លាននាក់ បានស្លាប់។ រូបថតភស្តុតាងមួយចំនួនអំពីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា។ រូបគំនូរបង្ហាញអំពីដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងចុងក្រោយគឺរូបថតស្តីអំពីការផ្តួចផ្តើមបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងការទទួលបានសន្តិភាពពេញលេញនៅក្នុងឆ្នាំ១៩៩៨។

ជាចុងក្រោយលោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកបានមានមតិសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សទាំង២៥រូប លោកឯកអគ្គរដ្ឋទូតមានប្រសាសន៍ថា លោកមានការរីករាយ ដែលបានមកទស្សនកិច្ចនៅខេត្តត្បូងឃ្មុំ និងមជ្ឈមណ្ឌលឯកសារកោះថ្ម ជាពិសេសបានជួបជាមួយលោកគ្រូ អ្នកគ្រូ





ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោក ប៉ាទ្រីក មូហ្វី និងគណៈប្រតិភូបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅវេលាម៉ោង១១ព្រឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ។
(សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សនៅទីនេះ។ លោកឯកអគ្គរដ្ឋទូតបានបន្ថែមថា សហរដ្ឋអាមេរិកបានផ្តល់ជំនួយច្រើនដល់ប្រទេសកម្ពុជា និងខេត្តត្បូងឃ្មុំជាពិសេស ទាក់ទងនឹងវិស័យអប់រំ កសិកម្ម បរិស្ថាន និងសុខាភិបាល។ សហរដ្ឋអាមេរិកក៏បានផ្តល់ជំនួយគាំទ្រជាច្រើនឆ្នាំ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីឲ្យយុវជនជំនាន់ក្រោយបានយល់ច្បាស់អំពីប្រវត្តិសាស្ត្រ និងទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតឡើងម្តងទៀត។ បន្ទាប់មក លោកឯកអគ្គរដ្ឋទូតបានផ្តល់ឱកាសឲ្យលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួន អំពីគោលបំណង

និងការបំពេញបេសកកម្មរបស់លោកនៅប្រទេសកម្ពុជា។ លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក បានមានប្រសាសន៍ថា លោកបានកើតនៅអំឡុងពេលសង្គ្រាមវៀតណាម ដែលប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់ពីសង្គ្រាមនោះដែរ។ លោកបានបន្ថែមថា លោកមានសាច់ញាតិបានបាត់បង់ជីវិតនៅក្នុងសង្គ្រាមវៀតណាម។ លោកមានប្រសាសន៍ថា លោកស្រឡាញ់ប្រទេសកម្ពុជា ស្រឡាញ់ប្រជាជនកម្ពុជា ស្រឡាញ់អាកាសធាតុ បរិស្ថាន និងម្ហូបអាហារ។ លោកក៏បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការសហការយ៉ាងល្អក្នុងការស្វែងរកអដ្ឋិធាតុទាហានសហរដ្ឋអាមេរិក ដែលបានបាត់ខ្លួននៅក្នុងប្រទេសកម្ពុជាក្នុងសម័យសង្គ្រាមវៀតណាម។ មកដល់ពេលនេះ នៅមានទាហានសហរដ្ឋអាមេរិកចំនួន ៤២នាក់ទៀត ដែលមិនទាន់រកឃើញអត្តសញ្ញាណ។

នៅអំឡុងឆ្នាំ១៩៧០ ទាហានសហរដ្ឋអាមេរិក និងទាហានវៀតកុង បានចូលមកដល់ប្រទេសកម្ពុជា។ នៅពេលនោះ ទាហានសហរដ្ឋអាមេរិកបានបោះទីតាំង និងសង់បន្ទាយនៅក្នុងភូមិកោះថ្ម ភូមិពងទឹក ឃុំទន្លូង និងទីតាំងផ្សេងៗទៀតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងស្រុកស្នួល នៃខេត្តក្រចេះ គឺដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតកុងដែលបានឆ្លងដែនចូលមកក្នុងទឹកដីប្រទេសកម្ពុជា។ ការប្រយុទ្ធគ្នារវាងទាហានសហរដ្ឋអាមេរិក និងកងទ័ពវៀតកុងបានបណ្ដាលឲ្យឧទ្ធម្ភាគចក្រនៃទាហានសហរដ្ឋអាមេរិក យ៉ាងតិចចំនួន៣គ្រឿងបានធ្លាក់នៅទឹកដីនៃឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឧទ្ធម្ភាគចក្រនៃទាហានសហរដ្ឋអាមេរិកដែលធ្លាក់មានដូចខាងក្រោម៖

១) ឧទ្ធម្ភាគចក្រ (AH-1G) របស់ទាហានអាមេរិកបានធ្លាក់នៅចម្ងាយ១០០ម៉ែត្រ ប៉ែកខាងលិចភូមិដង្កិត ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឧទ្ធម្ភាគចក្រនេះបានធ្លាក់នៅក្នុងថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧០។

២) ឧទ្ធម្ភាគចក្រស្ទាបពីររបស់ទាហានអាមេរិកបានធ្លាក់នៅខាងជើងភូមិដង្កិត ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្នុងឆ្នាំ១៩៧០។

៣) ឧទ្ធម្ភាគចក្រ(OH-6)របស់ទាហានអាមេរិកបានធ្លាក់នៅក្បែរត្រពាំងមួយក្នុងភូមិរបងប្រុះ ឃុំជាំ-ក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្នុងឆ្នាំ១៩៧០។ ឧទ្ធម្ភាគចក្រនេះបានធ្លាក់នៅចម្ងាយប្រហែល ៥០០ម៉ែត្រ ប៉ែកខាងជើងព្រំដែន កម្ពុជា - វៀតណាម

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោក ប៉ាទ្រីក មូហ្វី និងគណៈប្រតិភូបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅវេលាម៉ោង១១ព្រឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ។
( សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ក្នុងទឹកដីកម្ពុជា ។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ក៏មានមូលដ្ឋានកងទ័ពវៀតកុងស្ថិតនៅចម្ងាយប្រហែល ១៥០០ ម៉ែត្រប៉ែកខាងជើងភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំដែរ។ មូលដ្ឋានកងទ័ពវៀតកុងនេះមានមន្ទីរពេទ្យធំមួយ និងមានឃ្លាំងសម្ភារភស្តុភារមួយ។ មូលដ្ឋានកងទ័ពវៀតកុងនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៦ និងបានដំណើរការរហូតដល់ឆ្នាំ១៩៦៩។ មេបញ្ជាការមូលដ្ឋានកងទ័ពវៀតកុងនេះមានឈ្មោះ ស៊ិង មកពីវៀតណាម ខាងជើង និងចេះនិយាយភាសាខ្មែរ។ ស៊ិង បានរៀបការ ជាមួយនារីខ្មែរ ខណៈពេលដែលមូលដ្ឋានកងទ័ពវៀតកុងនេះស្ថិតភូមិគ្រៀង ឬភូមិក្បាលគ្រៀង។ ក្នុងឆ្នាំ១៩៦៩ ប្រពន្ធរបស់ ស៊ិង ត្រូវគ្រាប់រ៉ូកែត និងរបួស។ បន្ទាប់មកប្រពន្ធគាត់ត្រូវបានដឹកយកទៅមន្ទីរពេទ្យ។ នៅមន្ទីរពេទ្យនោះមានវេជ្ជបណ្ឌិត មានគ្រែដេក និងកន្លែងដាំបាយ ច្រើនកន្លែង។ យូៗម្តងប្រជាជនដែលរស់នៅក្បែរមូលដ្ឋានកងទ័ពវៀតកុងនេះ ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីជប់លៀងនៅក្នុងមូលដ្ឋានកងទ័ពវៀតកុងនេះដែរ។ ក្នុងឆ្នាំ១៩៦៩ ទាហានអាមេរិកបានទម្លាក់គ្រាប់បែកបេ-៥២ លើមូលដ្ឋានកងទ័ពវៀតកុងនេះ ដែលបណ្តាលឲ្យមនុស្សជាច្រើនបានស្លាប់។

ចំណែកទីតាំងមូលដ្ឋានកងទ័ពវៀតកុងមួយកន្លែងទៀត ស្ថិតនៅចម្ងាយប្រហែល៧គីឡូម៉ែត្រប៉ែកខាងត្បូងសានភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ទីតាំងមូលដ្ឋានកងទ័ពវៀតកុងនេះស្ថិតនៅជិតបូសសំពួរ ភូមិស្នួល និងព្រៃផ្គាវ។ ទីតាំងនេះស្ថិតនៅចម្ងាយប្រហែល១គីឡូម៉ែត្រពីព្រំដែនកម្ពុជា - វៀតណាម។ ទីតាំងមូលដ្ឋាន កងទ័ពវៀតកុងនេះ ក៏ប្រហែលជាមន្ទីរ១០០ ដែល ប៉ុល ពត និងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមផ្សេងៗទៀតបានមកស្នាក់នៅជាលើកដំបូងក្នុងចន្លោះពីឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៦៥។

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោក ប៉ាទ្រីក មូហ៊ី និងគណៈប្រតិភូបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅវេលាម៉ោង១១ព្រឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ។
( សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា )







# អនុព័ន្ធយោធាសហរដ្ឋអាមេរិកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ

ឡុង ដានី






មន្ត្រីអនុព័ន្ធយោធាសហរដ្ឋអាមេរិក Eric T Phillips ទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង១១:៣០នាទីព្រឹក ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១ លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ បានទទួលស្វាគមន៍ លោក Eric T Phillips មន្ត្រីអនុព័ន្ធយោធាសហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា និងសហការីដែលបានមកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងពិភាក្សាអំពីការងារស្រាវជ្រាវនៅអតីតតំបន់សមរភូមិ រវាងទាហានសហរដ្ឋអាមេរិក និងកងទ័ពវៀតកុង នៅអំឡុងដើមទសវត្សឆ្នាំ១៩៧០។




# គណៈប្រតិភូខេត្តត្បូងឃ្មុំធ្វើទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម អ៊ិច-១៦

ឈុំ រ៉ា



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ, លោក អ៊ិន ពៅសម្បត្តិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ ព្រមទាំងសហការមកពីសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តត្បូងឃ្មុំ បានដឹកនាំយុវជនចំនួន ៣០០នាក់ មកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ» នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម អ៊ិច-១៦ ក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ជាកិច្ចចាប់ផ្តើមលោក ផេង ពង្សរ៉ាសុី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាបានអញ្ជើញ ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ នៃគណៈអភិបាលខេត្តត្បូងឃ្មុំលោកអ៊ិនពៅសម្បត្តិប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តត្បូងឃ្មុំ ព្រមទាំងយុវជនកាយរិទ្ធិ កាកបាទក្រហម សហភាពសហព័ន្ធយុវជន



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្ដីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







កម្ពុជា និងក្រុមយុវជនចូលទស្សនាពិព័រណ៍រូបថតនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ដោយចាប់ផ្ដើមពីបណ្ដុំរូបថតនៃសង្គ្រាមនៅក្នុងប្រទេសកម្ពុជានៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ដោយចាប់ផ្ដើមចេញពីតំបន់កោះថ្ម, បណ្ដុំរូបថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), បណ្ដុំរូបថតនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩, បណ្ដុំរូបថតភស្ដុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) បណ្ដុំរូបគំនូរដែលសមមិត្ត ហ៊ុន សែន (សម្ដេចតេជោ ហ៊ុន សែន) និងយុទ្ធមិត្ត៤រូបចាកចេញទៅប្រទេសវៀតណាមដើម្បីរៀបចំកម្លាំងវាយផ្ដួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងផែនទីបង្ហាញផ្លូវដែលសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូបបានចាកចេញពីបន្ទាយយោធានៅភូមិកោះថ្មទៅតំបន់ព្រំដែនអាងដាច់ដើមត្រយឹង (អ៊ិច-១៦) និងទីតាំងមួយចំនួននៅក្នុងស្រុកឡុកនិញ ខេត្តសុងប៊ែរ ប្រទេសវៀតណាម និងការបង្កើតអង្គភាព១២៥ ដែលជាកងកម្លាំង

ប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាដំបូងបង្អស់ ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨។

បន្ទាប់ពីបានទស្សនាពិព័រណ៍រូបភាពនៅមជ្ឈ-មណ្ឌលឯកសារកោះថ្មរួចមក គណៈប្រតិភូ និងយុវជនបានបន្តដំណើរទៅកាន់តំបន់កោះថ្ម អ៊ិច-១៦ ដើម្បីរៀបចំវេទិកាថ្នាក់រៀននៅអគារមិត្តភាព។ ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ បានមានប្រសាសន៍អំពីការតស៊ូរបស់សម្តេចតេជោ ហ៊ុន សែន ជាការប្តូរសាច់ស្រស់ឈាមស្រស់ ដើម្បីទទួលបានសុខសន្តិភាព និងស្ថិរភាព។ នៅក្នុងភាពជាអ្នកដឹកនាំល្អ អ្នកដឹកនាំត្រូវមានតួនាទីដើរមុនគេជានិច្ច រៀបចំផែនការជាមុនដើម្បីឲ្យការងារមានភាពប្រសើរ។ ជាពិសេសអ្នកដឹកនាំល្អត្រូវតែគោរពតួនាទីជានិច្ច ត្រូវហ៊ានលះបង់ជាធំ។

ជាកិច្ចបន្តលោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ដល់យុវជនមានដូចខាងក្រោម ៖

- វាស់ស្ទង់ចំណេះដឹងមុនវេទិកាចាប់ផ្តើម ដោយប្រើប្រាស់កម្រងសំណួរវាស់ស្ទង់មតិ។
- ចែកចាយទស្សនាវដ្តីស្វែងរកការពិតដល់យុវជនទាំងអស់។
- បទបង្ហាញ និងពន្យល់អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖ គោលនយោបាយ ៨ ចំណុចរបស់របបកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩)។

លោក ផេង ពង្សរ៉ាស៊ី បានពន្យល់សិស្សានុសិស្សថា នៅដំណាក់កាលដំបូងយោធាខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ និងចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងប្រមាណ២លាននាក់ក្រោមមូលហេតុផ្សេងៗ ដូចជា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុង ប្រជាជនចេញទៅយកស្បៀងអាហារនៅទីជនបទ និងបំបែកចារកិច្ចរបស់ខ្មាំងជាដើម។ ការជម្លៀសដោយបង្ខំនេះបានបណ្តាលឲ្យប្រជាជនរាប់ពាន់នាក់ ជាពិសេសកុមារ មនុស្សចាស់ជរា និងអ្នកជំងឺបានស្លាប់នៅតាមផ្លូវ។



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ត្រីមានផ្ទៃពោះជាច្រើនបានស្លាប់នៅពេលសម្រាលកូនដោយសារគ្មានថ្នាំសង្កូវ ឬសេវាសុខាភិបាល។ ក្មេងៗបានវង្វេងបាត់ពីឪពុកម្ដាយ។ ប្រជាជនភាគច្រើនមិនដឹងថា តើនឹងមានអ្វីកំពុងតែកើតឡើង ទេ។ លោក ផេង ពង្សរ៉ាស៊ី បានបន្តថាការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី២ គឺខ្មែរក្រហមបានជម្លៀសប្រជាជននៅភូមិភាគបូព៌ា រួមមាន ខេត្តស្វាយរៀង ខេត្តព្រៃវែង និងផ្នែកខ្លះនៃខេត្តកំពង់ចាមដែលស្ថិតនៅត្រើយខាងកើតទន្លេមេគង្គ (បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ) ទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្ដាលបន្ទាប់ពីខ្មែរក្រហមបានចោទប្រកាន់មេដឹកនាំ និងកម្មាភិបាលនៅភូមិភាគបូព៌ាក្បត់ដោយបានចូលរួមជាមួយប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨។ ការជម្លៀសដោយបង្ខំទៅកាន់ភូមិភាគពាយ័ព្យ និងភូមិភាគកណ្ដាលនេះបានបណ្ដាលឲ្យប្រជាជនភូមិភាគបូព៌ាជាច្រើន បានស្លាប់ដោយសារការយកទៅសម្លាប់ ដោយសារជំងឺ និងអត់អាហារ។ ទី២) ការលុបបំបាត់លុយ និងផ្សារ។ ទី៣) ការលុបបំបាត់ទ្រព្យសម្បត្តិឯកជន។ ទី៤) ការលុបបំបាត់ប្រពៃណី សាសនា ទំនៀមទម្លាប់ និងបំផ្លាញសាលារៀន វត្តអារាម និងកន្លែងលក់ដូរផ្សេងៗ។ ទី៥) ខ្មែរក្រហមបានបង្កើតសហករណ៍ និងការដ្ឋានការងារដែលតម្រូវឲ្យប្រជាជនទាំងអស់ធ្វើស្រែចម្ការ និងលើកទំនប់ធំៗ។ ទី៦) ខ្មែរក្រហមបានសម្លាប់អ្នកចេះដឹង អតីតទាហានលន់ នល់ និងជនជាតិចាម វៀតណាម និង ចិន។ ទី៧) ខ្មែរក្រហមបានបង្កើតមន្ទីរឃុំឃាំងជិត២០០កន្លែង ដើម្បីឃុំឃាំងប្រជាជនដែលខ្លួនចោទថាក្បត់ ហើយប្រជាជនទាំងនោះភាគច្រើនត្រូវបានសម្លាប់យ៉ាងសាហាវ។ ទី៨) ខ្មែរក្រហមបានបង្កសង្គ្រាមជាមួយវៀតណាមនៅតាមព្រំដែនរហូតដល់ថ្ងៃដួលរលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

- បញ្ចាំងខ្សែភាពយន្តឯកសារចំនួនពីរ ទី១) ភាពយន្តឯកសារអំពីដំណើរឆ្ពោះទៅសង្គ្រោះជាតិរបស់សម្ដេចតេជោ ហ៊ុន សែន និងទី២) ខ្សែភាពយន្តឯកសារអំពីមរតក ២ធ្នូ។
- បទបង្ហាញ និងពន្យល់អំពីនិយមន័យ និងបុព្វហេតុដែលបង្កឲ្យមានឧក្រិដ្ឋកម្មឃោរឃៅ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារ ឬសហគមន៍ និងប្រទេសជាតិ។
- វាស់ស្ទង់ចំណេះដឹងសិស្សក្រោយវេទិកាបញ្ចប់ ដោយប្រើប្រាស់កម្រងសំណួរវាស់ស្ទង់មតិ។







គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្ដីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



គណៈប្រតិភូខេត្តត្បូងឃ្មុំ ធ្វើទស្សនកិច្ច និងចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្ម អ៊ិច-១៦ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ចំណាប់អារម្មណ៍របស់សិស្ស

ខ្ញុំឈ្មោះ **ធ្លា មុន្នាង** មានអាយុ១៨ឆ្នាំ ភេទស្រី គឺជាសិស្សមកពីសាលាអនុវិទ្យាល័យ ហ៊ុនសែនឈូក។ ខ្ញុំមានអារម្មណ៍រំភើប និងសប្បាយចិត្តជាខ្លាំងចំពោះការដែលបានមកចូលរួមនៅថ្ងៃនេះ។ ខ្ញុំបានដឹងពីព្រឹត្តិការណ៍ប្លែកៗដែលខ្ញុំមិនធ្លាប់បានដឹង និងទទួលបានចំណេះដឹងថ្មីៗ ព្រមទាំងបានយល់ដឹងអំពីដំណើរតស៊ូរបស់សម្តេចតេជោ ហ៊ុន សែន។ ខ្ញុំគិតថាព្រឹត្តិការណ៍សង្គ្រាមដែលបានកើតឡើងនេះ វាពិតជាឃោរឃៅ ដែលបានសម្លាប់មនុស្សជាច្រើនដែលគ្មានកំហុស។ ខ្ញុំមិនចង់ឲ្យមានសង្គ្រាមកើតឡើងជាលើកទីពីរទេ។ ក្រោយពីបានមកសិក្សា និងបានស្តាប់លោកគ្រូបកស្រាយរួចមក ខ្ញុំបានយល់ដឹងនិងខ្ញុំចង់ឲ្យក្មេងៗជំនាន់ក្រោយបានរៀនសូត្រអំពីប្រវត្តិសាស្ត្រឲ្យបានច្រើន និងបានដឹងអំពីផលវិបាកនៃសង្គ្រាម និងវិធីទប់ស្កាត់។ បើតាមគំនិតរបស់ខ្ញុំ ចង់មានការផ្សព្វផ្សាយពីវិធានការ និងការទប់ស្កាត់របបប្រល័យពូជសាសន៍ ដើម្បីឲ្យក្មេងៗបានដឹងអំពីបញ្ហារបស់ប្រទេសជាតិពេលមានសង្គ្រាម និងបង្រៀនឲ្យក្មេងជំនាន់ក្រោយស្រឡាញ់សន្តិភាព។ ជាចុងក្រោយប្រសិនបើមានឱកាសជាលើកទីពីរ ខ្ញុំចង់ចូលរួមនៅក្នុងកម្មវិធីប្រវត្តិសាស្ត្រនេះទៀត ព្រោះបានផ្តល់បទពិសោធន៍ថ្មីៗជាច្រើនដល់រូបខ្ញុំ។

ខ្ញុំបាទឈ្មោះ **លី ស៊ី** ភេទប្រុសមានអាយុ១៨ រៀនថ្នាក់ទី១២ គឺជាយុវជនមកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ក្តុលផ្សារ។ ថ្ងៃនេះខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយក្រៃលែងចំពោះកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់ក្រុមកាយរិទ្ធិយុវជនសសយកយុវជនកាកបាទក្រហម មកកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់កោះថ្មអ៊ិច-១៦។ នៅពេលដែលខ្ញុំបានសិក្សា និងបានទស្សនាខ្សែភាពយន្តឯកសារខ្លីៗដែលនិយាយអំពីប្រវត្តិសាស្ត្រ និងថ្នាក់ដឹកនាំរួចមក ធ្វើឲ្យខ្ញុំដឹងពីការលះបង់ និងការតស៊ូរបស់ថ្នាក់ដឹកនាំឆ្ពោះទៅរកសន្តិភាព និងការអភិវឌ្ឍន៍។ ម្យ៉ាងទៀតបានឲ្យខ្ញុំយល់ដឹងពីព្រឹត្តការណ៍ថ្មីៗជាច្រើន។ ជាចុងក្រោយ ខ្ញុំសូមអរគុណចំពោះបងៗក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មដែលបានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រឲ្យក្មេងៗជំនាន់ក្រោយបានសិក្សារៀនសូត្រ និងឈ្វេងយល់អំពីបញ្ហានៃសង្គ្រាម ព្រមទាំងបង្រៀនឲ្យយុវជនស្រឡាញ់សន្តិភាព។ ខ្ញុំសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកោះថ្មបន្តធ្វើកម្មវិធីបែបនេះទៀត ដើម្បីឲ្យយុវជនជំនាន់ក្រោយបានចូលរួម។

# ដំណើរទស្សនកិច្ចសិក្សា

## របស់និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មកកាន់មជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ

គាត ស្រីឡែន



និសិ្សតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចថតរូបជុំគ្នាជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ក្រុមនិសិ្សតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន១៩នាក់និងលោកសាស្ត្រាចារ្យ បានមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ។ លោក ឡុង ដានី គឺជានាយកនៅមជ្ឈមណ្ឌលឯកសារកោះថ្ម បានទទួលស្វាគមន៍ សាស្ត្រាចារ្យ និស្សិត ហើយក៏បានជម្រាបអំពីប្រវត្តិនៃការបង្កើត មជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ។

មជ្ឈមណ្ឌលឯកសារកោះថ្មត្រូវបានបង្កើតឡើងក្រោមការផ្តួចផ្តើមរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនាទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសក្រសួងការពារជាតិ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ មជ្ឈមណ្ឌលឯកសារកោះថ្មត្រូវបានដាក់ឲ្យប្រើប្រាស់ជាសាធារណៈកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ក្នុងគោលបំណង ៖

១) បង្ហាញអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។ ជាពិសេសដំណើរឆ្ពោះទៅរកការផ្តួល



លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ ធ្វើបទបង្ហាញអំពីរូបថតដែលដាក់តាំងបង្ហាញ ទៅដល់ក្រុមនិសិ្សតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



រំលំរបបប្រល័យពូជសាសន៍ប៉ុល ពត, សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូប កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

២) ពង្រឹងដល់ដំណើរការសន្តិភាព និងទប់ស្កាត់ជម្លោះនានាតាមរយៈកម្មវិធីអប់រំដែល នឹងផ្តល់ឱកាសឲ្យយុវជនជំនាន់ក្រោយដែលភាគច្រើនរស់នៅតាមជនបទ។

៣) លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងការចែករំលែកអំពីរឿងរ៉ាវ បុប ទពិសោធន៍ផ្ទាល់ខ្លួនដល់ក្មេងៗជំនាន់ក្រោយ។

៤) ប្រមែប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងបទឧក្រិដ្ឋដែលបន្សល់ពីរបបខ្មែរក្រហម។

៥) លើកកម្ពស់សុខុមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមរយៈការវាយតម្លៃស្ថានភាពសុខភាព និងធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពពួកគាត់។

៦) ពង្រឹងតួនាទីជាអ្នកដឹកនាំដល់អ្នកធ្វើការងារស្ម័គ្រចិត្តតាមរយៈការចូលរួមការបណ្តុះបណ្តាលផ្នែកប្រវត្តិសាស្ត្រ និងសុខភាព និងផ្តល់ឱកាសដល់អ្នកស្ម័គ្រចិត្តធ្វើការងារដោយផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

បន្ទាប់មកលោក ឡុង ដានី បានដឹកនាំនិសិ្សត និងសាស្ត្រាចារ្យដើរទស្សនាពិព័រណ៍រូបថតចំនួន ១៣៣ សន្លឹក រូបគំនូរចំនួន៣៦ផ្ទាំង និងផែនទីចំនួន ៦ផ្ទាំង។ រូបថត និងរូបគំនូរ ទាំងនោះបង្ហាញអំពី ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដោយសង្គ្រាមចាប់ផ្តើមចេញពីតំបន់កោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងស្រុកស្នួល ខេត្តក្រចេះ,បណ្តុំរូបថត នៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), ភ័ស្តុតាងមួយចំនួន អំពីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើ








និស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទស្សនាពិព័រណ៍រូបថតដែលដាក់តាំងបង្ហាញនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនកម្ពុជា, ដំណើរសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្តទាំង ៤រូប ធ្វើដំណើរឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧, ការបង្កើតអង្គភាព ១២៥ និងរូបថតនៃការផ្តួចផ្តើមបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ របស់ សម្តេចតេជោ ហ៊ុន សែន នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងការទទួលបានសន្តិភាពពេញលេញនៅក្នុងឆ្នាំ១៩៩៨។ រូបថតទាំងនោះថត ដោយ លោក ដេវីត ហក គឺជាអ្នកថតរូបជនជាតិអាមេរិក, លោក ឆាំង យុ គឺជាអ្នកថតរូបជនជាតិកម្ពុជា, លោកស្រី ស៊ីវ៉ាំណា ហ៊ុរ គឺជាអ្នកថតរូបជនជាតិអាមេរិក, លោក ម៉ៃ ឡាំ គឺជាអ្នកថតរូបជនជាតិវៀតណាម, លោក ហ្គុនណា ប៊ើយស្រ្តម គឺជាអ្នកថតរូបជនជាតិស៊ុយអែត។ ចំណែករូបគំនូរគូរដោយវិចិត្រករ អ៊ុត វឿន។

នៅចុងបញ្ចប់ លោក ឡុង ដានី បានបន្ថែមថា មជ្ឈមណ្ឌលឯកសារកោះថ្មគឺជាទីតាំងប្រវត្តិសាស្ត្រយោធាមួយដែលសម្តេចតេជោ ហ៊ុន សែនបានយកអាយុជីវិតធ្វើជាដើមទុនដើម្បីស្វែងរកកិច្ចអន្តរាគមន៍ និងកសាងកម្លាំងប្រដាប់អាវុធវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។ ចាប់ផ្តើមពីថ្ងៃ២០ ខែមិថុនា ឆ្នាំ១៩៧៧ សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត ៤រូប

រួមមាន៖ នុត ថត, សន សាញ់, ញឹក ហួន និង វ៉ា ប៉ោអ៊ាន បានចាកចេញពីទីបញ្ជាការដ្ឋាន វរសេនាធំតំបន់២១ ស្ថិតនៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ទាំងយប់ឆ្ពោះទៅកាន់ស្រុក ឡុកនិញ ខេត្តសុងបែ (បច្ចុប្បន្នស្រុក ឡុកនិញ ខេត្តបិញហ្វឿក) ប្រទេសវៀតណាមប្រកបដោយគ្រោះថ្នាក់បំផុតៗ ឱកាសល្អនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ អង្គភាព១២៥ ដែលជាកងកម្លាំងប្រដាប់អាវុធដំបូងដើម្បីតស៊ូប្រឆាំងនឹងរបបប្រល័យពូជសាសន៍ ប៉ុល ពត ត្រូវបានប្រកាសឡើងនៅក្នុងប្រទេសវៀតណាម ដោយមាន សមមិត្ត ហ៊ុន សែន ជាប្រធានទទួលបន្ទុកនយោបាយ និងយោធា, សមមិត្ត នុត ថន គឺជាអនុប្រធានទទួលផ្នែកនយោបាយ, សមមិត្ត ហែម សាមិន គឺជាអនុប្រធានទទួលបន្ទុកភស្តុភារ និងហិរញ្ញវត្ថុ។ បន្ទាប់ពីការប្រកាសបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ អង្គភាព១២៥ បានកើនឡើងរហូតទៅដល់ ២២វរសេនាតូចបុរស និងមួយកងវរសេនាតូចនារី ដែលមានសមមិត្តនារី មាន សំអាន គឺជាប្រធានកងវរសេនាតូច និងមានកម្លាំងសរុបរហូតដល់ជាង១ម៉ឺននាក់។ ចាប់ផ្តើមពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធ



និសិ្សតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមកធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ពិព័រណ៍រូបថតដែលដាក់តាំងបង្ហាញនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គភាព ១២៥ និងកងទ័ពស្ម័គ្រចិត្តវៀតណាម បានវាយសម្រុកជាទ្រង់ទ្រាយធំមកលើរបបខ្មែរក្រហម និងបានចូលកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់មកអង្គភាព ១២៥ បានក្លាយទៅជាកងទ័ពប្រជាជនបដិវត្តន៍នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជាពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ១៩៩៣។ ថ្នាក់ដឹកនាំកងយោធពលខេមរភូមិន្ទនាពេលបច្ចុប្បន្នភាគច្រើនបានប្រសូត្រចេញពីអង្គភាព១២៥នេះ។

បន្ទាប់មកនិស្សិតមកទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម បង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

**គង់ គាយសេង** ភេទប្រុស អាយុ២១ ឆ្នាំ គឺជានិស្សិតឆ្នាំទី៣ផ្នែកទំនាក់ទំនងអន្តរជាតិ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លើកឡើងថា «នៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម គឺជាកន្លែងមួយដែលអាចឲ្យខ្ញុំស្រាវជ្រាវទាក់ទងនឹងឯកសារមួយចំនួនអំពីដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្តទាំង៤រូប ធ្វើដំណើរទៅប្រទេសវៀតណាមនៅក្នុងគោលបំណងសង្គ្រោះប្រទេសកម្ពុជាឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ចំពោះឯកសារមួយចំនួនទៀតដូចជារូបថតអំពីរបបខ្មែរក្រហមថា ប្រជាជនកម្ពុជាពិតជាលំបាកវេទនាខ្លាំង។ ចំណែកដែនទីដំណើររបស់សម្តេចតេជោ ហ៊ុន សែន ទៅវៀតណាមវិញ ខ្ញុំគិតថា បើសិនខ្ញុំចង់ស្រាវជ្រាវលើប្រធានបទនេះ ខ្ញុំអាចរកបាន នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ យើងជាយុវជនជំនាន់ក្រោយ ទាំងអស់ ត្រូវតែរៀនសូត្រអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហមដើម្បីទប់ស្កាត់កុំឲ្យរបបនេះវិលមកវិញម្តងទៀត»។

**ត្រាំង គីមថូ** ភេទស្រី អាយុ២០ឆ្នាំ ជានិស្សិតឆ្នាំទី៣ផ្នែកទំនាក់ទំនងអន្តរជាតិនៃសកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច «ខ្ញុំមានចំណាប់អារម្មណ៍ខ្លាំងទាក់ទងនឹងរបបខ្មែរក្រហម ព្រោះលោកតា លោកយាយ ខ្ញុំតែងតែនិយាយរឿងរ៉ាវកាលពីសម័យខ្មែរក្រហមប្រាប់ខ្ញុំជាច្រើន គាត់និយាយថា កាលពីសម័យខ្មែរក្រហម អង្គការបង្ខំប្រជាជនឲ្យធ្វើការងារពលកម្មធ្ងន់ៗ ខ្មែរក្រហមបានបែងចែកឲ្យប្រជាជនឲ្យធ្វើពលកម្មទៅតាមកងនីមួយៗ ដូចជាមនុស្សចាស់ធ្វើពលកម្មនៅតាមកងដូចជាលើកដី, ធ្វើស្រែ។ ចំណែកកូនក្មេង ធ្វើពលកម្មនៅក្នុងកងកុមារ។ នៅពេលពួលោកតា លោកយាយ ខ្ញុំនិយាយ ខ្ញុំចាប់ផ្តើមចង់ដឹងពីសម័យខ្មែរក្រហម ព្រោះរបបនេះបានធ្វើបាបប្រជាជនខ្មែររាប់លាននាក់។ ខ្ញុំគិតថា ខ្លួនឯងមានសំណាង ដែលមិនបានឆ្លងកាត់របបខ្មែរក្រហម។ អ្វីដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍កាន់តែខ្លាំងនោះ គឺនៅពេលបានមកទស្សនកិច្ចសិក្សានៅមជ្ឈ-មណ្ឌលឯកសារកោះថ្ម ដែលពោលពេញទៅដោយរូបភាពនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំគិតថាការសិក្សាប្រវត្តិសាស្ត្រ វាមានសារសំខាន់ណាស់ ព្រោះធ្វើឲ្យយុវជនជំនាន់ក្រោយ បានយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរ និងទប់ស្កាត់របបខ្មែរក្រហមកុំឲ្យកើតមានឡើងម្តងទៀត។



# សាមណនិស្សិត និស្សិត និងសាស្ត្រាចារ្យ នៃពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## ទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ុច-១៦

**ឡុង ដានី**





សាមណនិស្សិតចំនួន២អង្គ ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យចំនួន៤០នាក់ មកពីពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ខេត្តកំពង់ចាម បានមកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង ៨:៣០នាទីព្រឹក ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣ សាមណនិស្សិតចំនួន២អង្គ ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យចំនួន៤០នាក់ មកពីពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ខេត្តកំពង់ចាម បានមកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។

ជាកិច្ចចាប់ផ្តើម លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានណែនាំខ្លួន ក្រុមការងារ និងមជ្ឈមណ្ឌលឯកសារកោះថ្មដែលមានទីតាំងស្ថិតនៅក្នុងសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កោះថ្ម។ បន្ទាប់មក លោក ឡុង ដានី បានដឹកនាំ សាមណនិស្សិត និស្សិត និងសាស្ត្រាចារ្យទាំងអស់

ដើរទស្សនាពិព័រណ៌រូបថត ដែលបានដាក់តាំងបង្ហាញនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម និងរៀបរាប់អំពីបណ្តុំរូបថតអំពីសង្គ្រាមចាប់ពីចុងទសវត្សរ៍ឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៧៥, បណ្តុំរូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩), បណ្តុំរូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩, បណ្តុំរូបថតអំពីភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩), រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូបចេញទៅប្រទេសវៀតណាមកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើងដោយមានសមមិត្ត ហ៊ុន សែន ជាស្ថាបនិក។ ចាប់ពីខែឧសភា ដល់ចុងខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរីកធំធាត់ និងកើនចំនួនរហូតដល់២៣កងវរសេនាតូច និងប្រមាណជាង១០០ក្រុមប្រតិបត្តិការប្រដាប់អាវុធ ដែលមានកងកម្លាំងសរុបប្រមាណជាងមួយម៉ឺននាក់។ បន្ទាប់មក កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងឱកាសនោះ លោក ឡុង ដានី ក៏បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារដំណើរឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត ដល់និស្សិត និងសាស្ត្រាចារ្យបានទស្សនា។

តមកលោក ឡុង ដានី បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ លោក ឡុង ដានីបានរៀបរាប់ថា បន្ទាប់ពីទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានអនុវត្តគោលនយោបាយ ៨ចំណុចរបស់ខ្លួន មានដូចជា៖ ១) ជម្លៀសប្រជាជនដោយបង្ខំ ២) បំបាត់ផ្សារ និងរូបិយប័ណ្ណ ៣) ផ្សឹកព្រះសង្ឃ និងកម្ទេចវត្តអារាម ៤) បិទសាលារៀន ៥) បង្កើតសហករណ៍ ៦) បំបែកក្រុមគ្រួសារមិនឲ្យជួបជុំគ្នា ៧) សម្លាប់បញ្ញវន្ត មន្ត្រីរដ្ឋការ និងប្រជាជនស្លូតត្រង់ ៨) បណ្តេញជនជាតិវៀតណាម និងធ្វើសង្គ្រាមតាមព្រំដែនជាមួយវៀតណាម។ ដោយសារខ្មែរក្រហមអនុវត្តគោលនយោបាយខាងលើបានបណ្តាលឲ្យប្រជាជនកម្ពុជាប្រមាណ២លាននាក់បានស្លាប់ដោយសារការសម្លាប់ អត់អាហារ ធ្វើការងារហួសកម្លាំង និងឈឺគ្មានការព្យាបាលត្រឹមត្រូវ។ របបកម្ពុជាប្រជាធិបតេយ្យមានរយៈពេលត្រឹមតែ៣ឆ្នាំ ៨ខែ ២០ថ្ងៃប៉ុណ្ណោះ ប៉ុន្តែបណ្តាលឲ្យប្រទេសកម្ពុជាប្រឈមនឹងបញ្ហាដូចតទៅគឺ៖ ទី១) សុខភាពប្រជាជនទ្រុឌទ្រោម ដោយសារខ្មែរក្រហមបង្ខំប្រជាជនឲ្យធ្វើការងារពលកម្មហួសកម្លាំង ហូបចុកមិនគ្រប់គ្រាន់ និងពេលមានជំងឺគ្មានគ្រូពេទ្យ និងថ្នាំព្យាបាលត្រឹមត្រូវ ទី២) ខ្មែរក្រហមបានធ្វើបន្សុទ្ធកម្មកម្មាភិបាល យុទ្ធជន យុទ្ធនារី កងទ័ព និងប្រជាជនខ្លួនឯងជាទ្រង់ទ្រាយធំ ជាពិសេសនៅភូមិភាគបូព៌ាចាប់ពីឆ្នាំ១៩៧៧ ដែលជាមូលហេតុធ្វើឲ្យកម្មាភិបាល យុទ្ធជន និងប្រជាជនមួយចំនួនធំបានរត់ភៀសខ្លួនទៅប្រទេសជិតខាង និងងើបឡើងបះបោរប្រឆាំងនឹងរបបខ្មែរក្រហមវិញ ទី៣) ការប៉ះទង្គិចជាមួយប្រទេសវៀតណាមគឺជាមូលហេតុធំបំផុតមួយដែលបណ្តាលឲ្យរបបខ្មែរក្រហមដួលរលំលឿន។ នៅខែធ្នូ ឆ្នាំ១៩៧៧ របបខ្មែរក្រហមបានប្រកាសផ្តាច់ទំនាក់ទំនងការទូតទាំងស្រុងជាមួយវៀតណាម ហើយប្រទេសទាំងពីរបានប្រយុទ្ធគ្នាស្ទើរពេញមួយរយៈកាលនៃឆ្នាំ១៩៧៨ ជាពិសេសនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយចូលប្រទេសកម្ពុជាជាទ្រង់ទ្រាយធំ និងបានចូលកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅ



សាមណនិស្សិតចំនួន២អង្គ ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យចំនួន ៤០នាក់ មកពីពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និង ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សង្គមកម្ពុជា ទាំងមូលបានទទួលផលប៉ះពាល់ដូចខាងក្រោម៖

១) បន្សល់ទុកស្ត្រីមេម៉ាយ និងក្មេងកំព្រារាប់ពាន់នាក់នៅក្នុងសង្គមកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ

២) ប្រជាជនកម្ពុជាភាគច្រើនមានជំងឺបាក់ស្បាត និងមានប្រជាជនកម្ពុជាមួយចំនួនបានសម្រេចចិត្តធ្វើចំណាកស្រុក និងជាជនភៀសខ្លួន

៣) បានបន្សល់ទុកគ្រាប់មីនរាប់លានគ្រាប់

៤) អ្នករស់រានមានជីវិតភាគច្រើនមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ

៥) សេដ្ឋកិច្ចប្រទេសកម្ពុជាបានធ្លាក់ដល់កម្រិតសូន្យ

៦) ពុំមានអ្នកចេះដឹងច្រើន សម្រាប់ជួយអភិវឌ្ឍន៍ប្រទេស

នៅចុងបញ្ចប់នៃវេទិកាថ្នាក់រៀន លោក ឡុង ដានី បានធ្វើបទបង្ហាញអំពីដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង០០១ និង០០២នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅក្នុងសំណុំរឿង០០១ ពាក់ព័ន្ធនឹងការជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច។ ឌុច គឺជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ (ដែលប្រជាជនកម្ពុជា ទូទៅបានស្គាល់ថា ជាគុកទួលស្លែង ស្ថិតនៅ ទីក្រុងភ្នំពេញ)។ នៅឆ្នាំ២០១២ ឌុច ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តន្ទាទោស ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។

សំណុំរឿង០០២ នៅឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៤រូប រួមមាន៖ អៀង សារី នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ដោយសារភាពស្មុគស្មាញនៃរឿងក្តី និងអាយុរបស់ជនជាប់ចោទ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចបំបែក

សំណុំរឿង០០២ ជាពីរគឺ សំណុំរឿង០០២ វគ្គ១ និង សំណុំរឿង០០២ វគ្គ២ សម្រាប់ការជំនុំជម្រះពីរផ្សេងគ្នា។ សំណុំរឿង០០២វគ្គ១ ដោយសារ អៀង សារី និង អៀង ធិរិទ្ធ មានជំងឺ និងទទួលមរណភាពនៅឆ្នាំ២០១៣ និង២០១៥។ ដូច្នេះ នៅឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តន្ទាទោស នួន ជា និង ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការសម្លាប់ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងដំណាក់កាលទីពីរនៃការផ្លាស់ប្តូរទីលំនៅប្រជាជន។

សំណុំរឿង០០២ វគ្គ២ គឺជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងក្រុមមនុស្សដែលជាក្រុមគោលដៅជាក់លាក់ ដូចជាជនជាតិចាម ជនជាតិវៀតណាម អ្នកកាន់សាសនាព្រះពុទ្ធ និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និង អំពើប្រល័យពូជសាសន៍ ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មព្រហ្មទណ្ឌរួមជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត។ នៅឆ្នាំ២០១៩ នួន ជា បានស្លាប់ដោយសារជរាភាព។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចផ្តន្ទាទោស ខៀវ សំផន់ឲ្យជាប់ពន្ធនាគារអស់មួយជីវិតបន្ថែមទៀត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មខាងលើ និងបានបិទបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែម្តង។

នៅវេលាម៉ោង១១៖៣០នាទីព្រឹកថ្ងៃដដែល សាមណនិស្សិត និស្សិត និងសាស្ត្រាចារ្យនៃពុទ្ធិកសកលវិទ្យាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ខេត្តកំពង់ចាម បានបន្តដំណើរទៅទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ មុននឹងបញ្ចប់កម្មវិធី។





សាមណនិស្សិតចំនួន២អង្គ ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យចំនួន ៤០នាក់ មកពីពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតតេជោ ហ៊ុន សែន ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និង ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦។ ( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )

# ប្រវត្តិឃុំគគីរនៅក្នុងរបបខ្មែរក្រហម

*ឈុំ រ៉ា*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មកំពុងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃុំគគីរមានចម្ងាយប្រមាណ៥០ គីឡូម៉ែត្រ ពីមជ្ឈមណ្ឌលឯកសារកោះថ្ម និងចម្ងាយប្រមាណ២៥ គីឡូម៉ែត្រ ពីទីរួមស្រុកមេមត់ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៧ បត់ស្តាំចូលតាមផ្លូវក្រាលកៅស៊ូនៃភូមិផ្លាកសំរោង ឃុំដារ ក្នុងចម្ងាយប្រមាណ១៥គីឡូម៉ែត្រ និងបត់ស្តាំតាមផ្លូវលំក្នុងចម្ការកៅស៊ូប្រមាណ៥គីឡូ-ម៉ែត្រទៀត ទើបដល់ឃុំគគីរ។ បច្ចុប្បន្ន ឃុំគគីរមានភូមិចំណុះចំនួន៨ភូមិ គឺភូមិគគីរជើង, ភូមិគគីរត្បូង, ភូមិក្រោក, ភូមិចំការថ្មី, ភូមិទួលថ្ម, ភូមិព្រែកពួយ, ភូមិសាឡង់៣ និងភូមិស្រែពោល។ ឃុំគគីរមានព្រំប្រទល់ខាងត្បូងជាប់ឃុំមេមត់ ខាងជើងជាប់ឃុំកំពាន់ ខាងលិចជាប់ឃុំដារ និងខាងកើតជាប់ឃុំមេមង់។

កាលពីជំនាន់បារាំង ឃុំគគីរមានប្រជាជនរស់នៅតិចតួច និងប្រកបរបរធ្វើស្រែចម្ការ។ នៅក្នុងភូមិមានដើមគគីរដុះច្រើនមានទាំងដើមតូចនិងធំ។ កាលនោះប្រជាជននាំគ្នាទៅធ្វើស្រែនៅត្រើយម្ខាងព្រែក។ ដោយសារគ្មានស្ពានឆ្លងកាត់ព្រែកអ្នកភូមិបានយកដើមគគីរធ្វើស្ពានសម្រាប់ដើរឆ្លងព្រែកទៅធ្វើស្រែចម្ការ។ ក្រោយមក អ្នកស្រុកបាននាំគ្នាហៅភូមិនេះថា ភូមិគគីរ។ បារាំងបានមកធ្វើចម្ការកៅស៊ូនៅឃុំគគីរ ស្រុកមេមត់ ដោយជួលកម្មករជនជាតិខ្មែរ-ចាម និងវៀតណាមធ្វើការ។ នៅក្នុងឃុំគគីរមានជនជាតិបារាំងម្នាក់នៅមើលការខុសត្រូវ និងធ្វើរបាយការណ៍ផ្ញើទៅ

ថ្នាក់លើ។ នៅក្នុងរបបសង្គមរាស្ត្រនិយមអាផ្ទារធរបាន បង្កើតជាឃុំគគីរ ដោយមានភូមិគគីរ និងភូមិផ្សេងៗ ទៀតជាចំណុះរហូតមកដល់សព្វថ្ងៃ។

បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ប្រជាជនក្នុងស្រុកមេមត់បានធ្វើបាតុកម្មដើម្បីទាមទារ សម្ដេចព្រះ នរោត្តម សីហនុ ចូលមកគ្រប់គ្រងប្រទេសឡើងវិញ។ អំឡុងពេលធ្វើបាតុកម្មមានការប៉ះទង្គិចគ្នារវាងទាហាន លន់ នល់ និងប្រជាជនដែលគាំទ្រសម្ដេចព្រះ នរោត្តម សីហនុ។ ខណៈពេលនោះ មានទាំងប្រជាជនដែលគាំទ្រសម្ដេចសីហនុ និងទាហាន លន់ នល់ រងរបួស។ ទាហាន លន់ នល់ មានកាំភ្លើងគ្រប់គ្នា។ ចំណែកប្រជាជនមានតែ កាំបិត ពូថៅ និងដំបង។ ប្រជាជនធ្វើបាតុកម្មនៅខ្ទង់ក្រពើ ស្រុកមេមត់ អស់រយៈពេល៣ថ្ងៃទើបឈប់។ នៅតាមដងផ្លូវប្រជាជននាំគ្នាស្រែកថា «ជយោសម្ដេចឳអ្នកណាមិនទៅកាប់ចោល» ។ ពេលបាតុកម្មចប់ប្រជាជននាំគ្នាត្រឡប់មកផ្ទះធ្វើស្រែចម្ការរៀងៗខ្លួនវិញ។ នៅក្នុងឆ្នាំ១៩៧០ ដដែល ទាហានអាមេរិកបានទម្លាក់គ្រាប់បែកលើឃុំគគីរ ពីព្រោះមានវត្តមានកងទ័ពវៀតកុងលាក់ខ្លួននៅក្នុងឃុំនេះ។ ការទម្លាក់គ្រាប់បែកនេះ បណ្ដាលឲ្យប្រជាជនស្លាប់ និងរបួសចំនួន៤០នាក់។ នៅឆ្នាំ១៩៧៣ ទើបកងទ័ពវៀតកុង ដកចេញអស់ពីឃុំគគីរ និងលែងមានការទម្លាក់គ្រាប់បែកទៀត។

នៅពេលខ្មែរក្រហមឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជន១៧ មេសា មកដាក់នៅក្នុងឃុំគគីរ រយៈពេល២ខែរួចហើយក៏ជម្លៀសបន្តឲ្យទៅនៅភូមិកំពែ ភូមិខ្ពប ឃុំរំចេក ទាំងអស់។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបង្កើតជាសហករណ៍ ហើយខ្មែរក្រហមបានបែងចែកប្រជាជនជាក្រុមៗ។ ប្រធានក្រុមនីមួយៗបានឲ្យសមាជិកក្នុងក្រុមប្រមូលរបស់របរនៅតាមផ្ទះដូចជាក្របី គោ មាន់ ទា និងទ្រព្យសម្បត្តិផ្សេងៗ



ផ្លូវលំនៅក្នុងឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មកដាក់រួម ទាំងអស់ ទុកតែស្លាបព្រាមួយ និងចានមួយ សម្រាប់ហូបបបរ ប៉ុណ្ណោះ។

នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ខ្មែរក្រហមបានជ្រើសរើសប្រជាជននៅក្នុងឃុំគគីរឲ្យចូលធ្វើជាកងចល័ត ធ្វើទាហាន និងធ្វើជាគ្រូពេទ្យជាដើម។ ក្មេងៗប្រុសស្រីដែលមានអាយុចាប់ពី១៥ឆ្នាំ ឡើងទៅ ត្រូវបាត់តាំងឲ្យធ្វើជាកងចល័តលើកទំនប់ជីកប្រឡាយ ប្រូតកាត់ ដកស្ទូង ដែលស្ថិតនៅឆ្ងាយៗពីភូមិ។

នៅឆ្នាំ១៩៧៨ កងទ័ពមកពីភូមិភាគនិរតីបានចូលមកចាប់កម្មាភិបាលដែលជាប្រធានកងតូច ប្រធានកងធំ គ្រូពេទ្យ គ្រូបង្រៀននៅខាងភូមិភាគបូព៌ាយកទៅសម្លាប់នៅព្រែកឆ្លូងក្នុងស្រុកឆ្លូង ខេត្តក្រចេះ។ ចំណែកប្រជាជនត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិ ទាំងអស់ ប្រជាជនខ្លះជម្លៀសទៅដល់ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តកំពង់ធំ និងមានប្រជាជនខ្លះបានរត់ទៅប្រទេសវៀតណាមរហូតដល់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមចូលមកវាយផ្ដួលរំលំរបបខ្មែរក្រហម និងទទួលបានជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបប្រជាជនដែលរត់ភៀសខ្លួនទាំងនោះវិលត្រឡប់មកស្រុកភូមិវិញ។



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មកំពុងធ្វើដំណើរទៅសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគីរ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ខ្លោងទ្វារវត្តនៅឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនមានពិការ

## នៅក្នុងភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

ទី ស៊ីថា



កិ ផាន់ អាយុ៨៥ឆ្នាំ រស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

### កិ ផាន់

ខ្ញុំឈ្មោះ កិ ផាន់ ភេទប្រុស អាយុ៨៥ឆ្នាំ មានស្រុកកំណើតនៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ កិ (ស្លាប់) និងម្តាយឈ្មោះ សាន់ (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់។ ខ្ញុំមានប្រពន្ធ២នាក់ ប្រពន្ធទី១ មានឈ្មោះ ខ្សុយ ស្លាប់ដោយសារត្រូវគ្រាប់កាំភ្លើងរបស់ជនខិលខូចលួចបាញ់សម្លាប់ ខណៈពេលកំពុងអង្គុយកោសខ្យល់ឲ្យខ្ញុំ។ បន្ទាប់មកខ្ញុំមានប្រពន្ធម្នាក់ទៀតឈ្មោះ ផាត់ វេ អាយុ៦៩ឆ្នាំ និងមានស្រុកកំណើតនៅស្រុកកៀនស្វាយ ខេត្តកណ្តាល។ ខ្ញុំមានកូនប្រុសម្នាក់ជាមួយប្រពន្ធទី២។

កាលនៅក្មេងខ្ញុំបានរៀនត្រឹមថ្នាក់ទី១០ ចាស់នៅសាលាក្តុល។ ខ្ញុំអាចសរសេរ និងអានបានខ្លះៗ។ ចូលដល់សម័យខ្មែរក្រហម (១៩៧៥-១៩៧៩) ខ្មែរក្រហមមិនអនុញ្ញាតឲ្យក្មេងៗរៀនសូត្រឡើយ។ ចំណែកវត្តអារាមត្រូវបិទ និងផ្សឹកព្រះសង្ឃ។ ពេលនោះខ្មែរក្រហមបានជម្លៀសខ្ញុំ និងក្រុមគ្រួសារទៅរស់នៅស្រុកស្នួល។ នៅទីនោះខ្មែរក្រហមបង្ខំឲ្យធ្វើការទាំងយប់ថ្ងៃគ្មានពេលសម្រាក។ ខ្ញុំត្រូវដើរទៅធ្វើការតាំងពីម៉ោង៦:០០ព្រឹក រហូតដល់១២:០០ថ្ងៃត្រង់ទើបបានឈប់សម្រាកហូបបបរ។ ពេលហូបរួចខ្ញុំចុះទៅធ្វើការបន្តរហូតដល់ម៉ោង៥ល្ងាចទើបបានឡើងមកភូមិវិញ។ នៅម៉ោង៨:០០-៩:០០យប់ ខ្ញុំទើបបានហូបបបរម្តងទៀត។

ខ្ញុំធ្លាប់ឃើញខ្មែរក្រហមយកមនុស្សទៅវាយទម្លាក់ក្នុងអណ្តូង ដោយសារតែច្រៀងចម្រៀងមិនមែនបទបដិវត្តន៍។ នៅពេលយប់តែងតែមានកងឈ្លបលួចចូលមកក្រោមផ្ទះដើម្បីលួចស្តាប់ លួចមើលក្រែងមានប្រជាជនណាលួចដាំបាយ ឬនិយាយអ្វីមិនល្អពីអង្គការ ហើយប្រសិនបើឈ្លបនោះរាយការណ៍ទៅថ្នាក់លើ និងចាប់យកអ្នកទាំងនោះទៅវាយចោលតែម្តង។ ខ្មែរក្រហមបានជម្លៀសខ្ញុំទៅម្ចិច ស្រុកស្នួលឲ្យធ្វើស្រែចម្ការបានពីរទៅបីថ្ងៃ បន្ទាប់មកខ្មែរក្រហមឲ្យដើរទៅមុខដឹះការណូតរហូតទៅដល់ស្រុកស្នឹងត្រង់។ ខ្ញុំនៅទីនោះបានរយៈពេលប្រហែល១ខែ ក៏ពួការប្រកាសថា ប្រជាជននៅស្រុកណាសូមធ្វើដំណើរត្រឡប់ទៅស្រុកនោះវិញ។ ខ្ញុំក៏ធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ ពេលធ្វើដំណើរមកដល់ក្តុល ខ្ញុំក៏ឈប់សម្រាករយៈពេលប្រាំយប់សិន ដើម្បីឲ្យក្រុមដោះមីនស្វែងរកគ្រាប់មីននៅក្នុងភូមិក្តុលលើរួចទើបបានចូលមករស់នៅក្នុងភូមិ និងធ្វើស្រែចម្ការចិញ្ចឹមជីវិតរហូតមក។ សព្វថ្ងៃនេះ ខ្ញុំមានជំងឺញ័រដៃញ័រជើង និងមានការពិបាកនៅពេលហូបបាយ ធ្វើដំណើរ និងពេលសម្រាន្ត។



ផាត់ វេ អាយុ៦៩ឆ្នាំ រស់នៅភូមិគុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ផាត់ វេ

ខ្ញុំឈ្មោះ ផាត់ វេ ភេទស្រី អាយុ៦៩ឆ្នាំ មានស្រុកកំណើតនៅភូមិចន្ទក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិគុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ម៉ាន់ ផាត់ និងម្តាយឈ្មោះ ស៊ុក សុខ។ ខ្ញុំមានបងប្អូនបង្កើតចំនួន៦នាក់ (ស្លាប់៤នាក់ និងនៅរស់២នាក់)។

កាលនៅក្មេង ខ្ញុំចូលរៀនបានត្រឹមថ្នាក់ទី១២ចាស់ នៅក្នុងរបបសង្គមរាស្ត្រនិយម។ ពេលនោះខ្ញុំរៀនតែក ខ ពេញមួយឆ្នាំ ជាមួយគ្រូបង្រៀនឈ្មោះ សុខុម និង ស៊ីស្វា។ ខ្ញុំឈប់រៀនដោយសារតែជីវភាពខ្វះខាត ព្រោះឪពុកខ្ញុំត្រូវស៊ីឈ្នួលបោសសម្អាតនៅមន្ទីរពេទ្យដើម្បីដូរយកអង្ករចិញ្ចឹមកូនៗ។ ពេលខ្ញុំមានអាយុ១៦ឆ្នាំ ក៏លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ។ បន្ទាប់មកខ្ញុំបានរៀបការ និងបានផ្លាស់មករស់នៅព្រែកឯងវិញ។ បងប្រុសខ្ញុំទី១ឈ្មោះ ផាត់ សែម ឬ សែប ញិល ធ្វើជាទាហានជំនាន់សម្តេចឪបានទៅចូលរួមធ្វើបាតុកម្មជាមួយប្រជាជនផ្សេងៗទៀត និងមិនបានត្រឡប់មកផ្ទះវិញរហូតដល់សព្វថ្ងៃ។ បងថ្លៃខ្ញុំនៅខេត្តស្វាយរៀងបានធ្វើទាហាននៅក្នុងបន្ទាយត្បូកកី និងបានបបួលប្តីរបស់ខ្ញុំចូលធ្វើជាទាហាននៅទីនោះដែរ។ ពេលនោះខ្ញុំបានឃើញបងថ្លៃខ្ញុំកាន់កាំភ្លើង M105 និង M115។ បន្ទាប់មកប្តីខ្ញុំក៏បានទៅធ្វើទាហានដែរ។ បន្ទាប់មកបងថ្លៃខ្ញុំជាអ្នកបើកឡាន ហើយប្តី និងប្អូនរបស់ខ្ញុំជាអ្នកលើកដីដាក់ឡាន។ នៅយប់មួយនោះ អ្នកភូមិនាំគ្នារត់ចេញពីផ្ទះទៅនៅក្នុងព្រៃអស់ ចំណែកខ្ញុំដេកមិនដឹងខ្លួនទាល់តែប្អូនជីដូនមួយរបស់ខ្ញុំមកទាត់ទ្វារផ្ទះដាស់ឲ្យខ្ញុំក្រោក ហើយនិយាយថាឆាប់រត់ចេញពីភូមិ។ ក្រុមគ្រួសារខ្ញុំបានជិះទូកទាំងកណ្តាលយប់ទៅដល់ភូមិកោះចាស់ ដែលនៅជុំវិញសុទ្ធតែទឹកទន្លេ។ នៅទីនោះមានប្រជាជនចំនួន៣គ្រួសារ គឺ គ្រួសារបងស្រីបងបន្ទាប់របស់ខ្ញុំ និងគ្រួសារខ្ញុំរួមទាំងឪពុកម្តាយខ្ញុំ។ កោះចាស់ស្ថិតក្នុងឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ក្រុមគ្រួសារខ្ញុំប្រកបរបរធ្វើចម្ការ ដាំបន្លែ ដាំត្រសក់ សណ្តែកគួរ និងរកត្រី។ វៀតកុងបុកវៀតណាមខាងជើងបានចូលមកវាយទាហាន លន់ នល់ ពេលនោះខ្ញុំនៅចូលរួមពិធីមង្គលការសាច់ញាតិក្នុងភូមិចម្ការមុំ។ កោះស្លាកែត។ កងទ័ពវៀតកុង បានចូលបន្លំខ្លួននៅក្នុងពិធីមង្គលការនោះ បណ្តាលឲ្យអ្នកចូលរួមពិធីមង្គលការបានភ្ញើលឆោឡោ។ បន្ទាប់មកគ្រួសារខ្ញុំបានផ្លាស់ទៅនៅបន្ទាយទាហានត្បូកកី។ ប្រជាជននៅទីនោះភាគច្រើននិយាយពាក្យស្លោកមួយឃ្លា ហើយម្តាយខ្ញុំក៏និយាយប្រាប់កូនចៅដែរថា «កោះស្លាកែតមានរបាំងមើលមិនឃើញ» ដោយសារតែកោះនេះតាំងពីសម័យមុនៗមិនដែលមានសង្គ្រាមទេគឺជៀសរួចរហូត។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនត្រូវបានបែងចែកកម្លាំងជា៣កម្រិតគឺ កម្លាំងស្រួច រួមមានស្ត្រីមេម៉ាយ ឬកម្លាំងនារី, កម្លាំងកណ្តាល និងកម្លាំងមនុស្សចាស់។ ពេលធ្វើការខ្មែរក្រហមហាមមិនឲ្យប្រជាជនច្រៀងបទលោកីយ៍ទេ គឺច្រៀងបានតែបទចម្រៀងបដិវត្តន៍តែប៉ុណ្ណោះ។

នៅពេលប្រជាជននៅព្រែកឯង និងក្បាលកោះត្រូវបានខ្មែរក្រហមប្រើឲ្យជីករណ្តៅខ្លួនឯង ហើយនាំគ្នាទៅប្រជុំនៅក្នុងរណ្តៅ។ ពេលនោះមានសំណាងដែលប្រធានកងមិនបានត្រឡប់មកភូមិវិញ កុំអីប្រជាជនត្រូវស្លាប់នៅក្នុងរណ្តៅទាំងអស់គ្នា។ បន្ទាប់មកក្រុមគ្រួសារខ្ញុំ និងអ្នកភូមិទាំងអស់ត្រូវជម្លៀសទៅនៅព្រែកប្រា ក៏ស្រាប់តែផ្ទុះសង្គ្រាម។ ប្តីខ្ញុំទៅវាយនៅសមរភូមិ ហើយគាត់ដេញឲ្យខ្ញុំនាំកូនត្រឡប់មកផ្ទះមុនចាំគាត់ត្រឡប់មកតាមក្រោយ។ ខ្ញុំបាននាំកូនមកនៅស្រុកកំណើត ប៉ុន្តែមិនឃើញប្តីខ្ញុំត្រឡប់មកទេ។ នៅអំឡុងឆ្នាំ១៩៨០ ខ្ញុំបានរៀបការជាមួយប្តីក្រោយ និងបានមករស់នៅគុលលើ ដែលជាស្រុកកំណើតរបស់ប្តីក្រោយ និងប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ សព្វថ្ងៃនេះ ខ្ញុំងងឹតភ្នែក ពេលធ្វើដំណើរទៅណាមកណាម្តងៗមានការលំបាកខ្លាំង។



ជិន គឿន អាយុ៥៧ឆ្នាំ រស់នៅភូមិគ្គុលលើ ឃុំទន្ទឹង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ជិន គឿន

ខ្ញុំឈ្មោះ ជិន គឿន ភេទប្រុស អាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅភូមិគ្គុលលើ ឃុំទន្ទឹង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិគ្គុលលើ ឃុំទន្ទឹង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងជាប្រធានប្រជាការពារឃុំទន្ទឹង។ ខ្ញុំមានឪពុកឈ្មោះ ជិន និងម្ដាយឈ្មោះ កិ ស្មាន់។ ខ្ញុំមានបងប្អូនបង្កើតចំនួន៨ នាក់ (ស្លាប់៣នាក់)។ ខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ ប៉ោង អៀង មានអាយុ៥៥ឆ្នាំ។

នៅមុនសម័យខ្មែរក្រហម ខ្ញុំរៀនបានថ្នាក់ទី១១ចាស់ នៅសាលាគ្គុលលើ ដែលមានគ្រូបង្រៀនឈ្មោះ ហ៊ិ និងគ្រូឈ្មោះ សុវណ្ណ រស់នៅភូមិចង្កុំក្រោម មកបង្រៀននៅសាលាគ្គុលលើ។ ពេលខ្ញុំអាយុ១១ឆ្នាំ ឪពុកនិងម្ដាយខ្ញុំត្រូវខ្មែរក្រហមចាត់តាំងឲ្យធ្វើកងចល័ត និងត្រូវដើរទៅធ្វើការតាំងពីព្រឹករហូតដល់ព្រលប់ទើបត្រឡប់មកផ្ទះវិញ។ នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមជម្លៀសអ្នកភូមិគ្គុលលើទៅនៅភូមិស្រែតាពេជ្រ។ ខ្ញុំរស់នៅ ទីនោះបានរយៈពេល១០ថ្ងៃ ខ្មែរក្រហមជម្លៀសខ្ញុំទៅ ម្ទិច ក្នុងស្រុកស្នួល ខេត្តក្រចេះ បន្តទៀត។ នៅម្ទិច មានអ្នកភូមិស្លាប់ច្រើន ដោយសារអត់បាយ។ ក្រោយមក ខ្មែរក្រហមជម្លៀសខ្ញុំទៅភូមិភាគកណ្ដាល ហើយនៅ ទីនោះខ្មែរក្រហមមិនបានប្រើឲ្យធ្វើការធ្ងន់ធ្ងរទេ និងបានបាយហូបគ្រប់គ្រាន់ទៀត។

នៅឆ្នាំ១៩៧៩ ពេលខ្ញុំនិងក្រុមគ្រួសារត្រឡប់មកដល់ភូមិគ្គុលលើវិញ ខ្ញុំបានចូលធ្វើឈ្លបឃុំទន្ទឹង មានតួនាទីមើលសណ្ដាប់ធ្នាប់ និងសុវត្ថិភាពប្រជាជនក្នុងឃុំ។ ប្រសិនបើមានកងទ័ពរដ្ឋាភិបាលស្នើឈ្លបឃុំឲ្យទៅសមរភូមិជាមួយកងទ័ព គឺយើងត្រូវតែទៅ។ នៅឆ្នាំ១៩៨២ ខ្ញុំចូលធ្វើកងទ័ពនៅអង្គភាព «គ១» ឃុំទន្ទឹង និងបានចេញទៅប្រយុទ្ធនៅតាមសមរភូមិចំនួន៣លើក រួមមាន សមរភូមិនៅភូមិម្កោរ បន្ទាប់មកសមរភូមិភូមិពងទឹក ចុងក្រោយសមរភូមិភូមិហុចម្ទូរ។ ពេលនោះយើងវាយឈ្នះកងទ័ពខ្មែរក្រហមរហូត។ នៅឆ្នាំ១៩៨៨ ខណៈពេលខ្ញុំកំពុងស្ថិតនៅខ្សែត្រៀមការពារ មិត្តភក្តិដែលធ្វើកងទ័ពជាមួយគ្នាបានបាញ់កាំភ្លើងលេង។ ខ្ញុំប្រាប់ថា ប្រយ័ត្នបាញ់ត្រូវខ្ញុំ ប៉ុន្តែមិត្តភក្តិនោះតបមកវិញថាមិនអីទេ។ បន្ទាប់មកស្រាប់តែកាំភ្លើងរៀលកៃមកត្រូវភ្លៅខ្ញុំធ្វើឲ្យបាក់ឆ្អឹងភ្លៅ។ ខ្ញុំត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាម។ ខ្ញុំត្រូវគេដណ្ដឹងផ្ដាច់៣ពាក្យ ដោយសារតែខ្ញុំធ្លាក់ខ្លួនពិការ។ បន្ទាប់ពីបានជាសះស្រួលបួល ហើយខ្ញុំក៏ចូលធ្វើកងទ័ពបន្តទៀត។ នៅពេលនោះថ្នាក់លើបានបញ្ជូនខ្ញុំទៅសមរភូមិប៉ៃលិនបានមួយរយៈពេល ខ្ញុំក៏សុំច្បាប់មកស្រុកវិញ។ នៅឆ្នាំ១៩៨៩ ខ្ញុំបានរៀបចំសែនព្រេនជាមួយប្រពន្ធខ្ញុំឈ្មោះ ប៉ោង អៀង ហើយរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃ។



កិ យ៉ាន់ អាយុ៩៣ឆ្នាំ រស់នៅភូមិគ្គុលលើ ឃុំទន្ទឹង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## កិ យ៉ាន់

ខ្ញុំឈ្មោះ កិ យ៉ាន់ ភេទស្រី អាយុ៩៣ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិគ្គុលលើ ឃុំទន្ទឹង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិ ឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ កិ (ស្លាប់) និងម្ដាយឈ្មោះ សាន (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់។ កាលពីក្មេង ខ្ញុំរៀនសូត្របានត្រឹមថ្នាក់ទី១២ចាស់ គឺរៀននៅតាមផ្ទះ។ ពេលនោះជីវភាពគ្រួសារខ្ញុំលំបាកខ្លាំង ក៏ឈប់រៀនមកជួយធ្វើស្រែចម្ការជាមួយ

ឪពុកម្តាយវិញ។ កាលនោះមានការទម្លាក់គ្រាប់បែកនៅជាយៗភូមិខ្ញុំ ប៉ុន្តែមិនមានអ្នកភូមិណាត្រូវរបួសទេ។ បន្ទាប់ពីមានរដ្ឋប្រហារឆ្នាំ១៩៧០ រដ្ឋអំណាចភូមិបានរៀបចំឲ្យប្រជាជនធ្វើស្រែរួមគ្នា ហើយនៅពេលបានផលបែកគ្នាហូបតាមផ្ទះរៀងៗខ្លួន។ ក្រោយមកខ្មែរក្រហមចាប់ផ្តើមដាក់របស់របររួម ហូបបាយរួម ជង្រុកស្រូវរួម និងបង្កើតជាសហករណ៍។ ក្រោយឆ្នាំ១៩៧៩ កូនប្រុសរបស់ខ្ញុំបានចូលក្នុងព្រៃរកសត្វ ឈ្លូស ត្រូវខ្មែរក្រហមបាញ់ស្លាប់។ សព្វថ្ងៃនេះ ខ្ញុំងងឹតភ្នែក និងមានជំងឺវង្វេងវង្វាន់។



ម៉ៅ ជិន អាយុ៨៨ឆ្នាំ រស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ម៉ៅ ជិន

ខ្ញុំឈ្មោះ ម៉ៅ ជិន ភេទប្រុស អាយុ៨៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិយ្រឹម ឃុំយ្រឹម ស្រុកស្នួល ខេត្តក្រចេះ។ ឪពុកឈ្មោះ ជិន និង ម្តាយឈ្មោះ ផាន់ ស្លាប់ដោយសារជំងឺ។ ខ្ញុំមានបងប្អូនចំនួន២នាក់ ប៉ុន្តែប្អូនខ្ញុំស្លាប់តាំងពីឆ្នាំ១៩៩៤។ កាលពីក្មេងខ្ញុំចូលរៀននៅសាលា ក្នុងឃុំយ្រឹម។ លោកគ្រូបង្រៀនឈ្មោះ អេង ហើយមួយថ្នាក់មានសិស្សចំនួន៣០នាក់។ រៀនបានត្រឹមថ្នាក់ទី៤ ខ្ញុំឈប់រៀន ដោយសារតែគ្រួសារខ្វះខាត។ រួចមករស់នៅជាមួយឪពុក មិនបានជួយធ្វើស្រែចម្ការទេ។ ខ្ញុំរៀបការឆ្នាំ១៩៦៧ រួចមករស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ចូលដល់សម័យ លន់ នល់ ទៅរៀនបើកឡានបានពីរឆ្នាំបានលុយក៏ទៅប្រឡងយកពាក់មី។ ខ្ញុំបើកឡានដឹកឈើមុខ៧០ មុខ៨០ ឈើធំៗទៅទម្លាក់នៅថ្មគ្រែ ហើយបើមានអ្នកដំណើរខ្ញុំដឹកពីភ្នំពេញទៅក្រចេះ និង ពីក្រចេះមកភ្នំពេញ។ ពេលធ្វើរដ្ឋប្រហារ នៅក្នុងភូមិមានអ្នកទៅចូលរួមដែលតែទៅដោយស្ម័គ្រចិត្ត និង មានឡានគេមកដឹកយកទៅធ្វើបាតុកម្ម នៅជីរោទ៍។ ប្រជាជនដែលទៅធ្វើបាតុកម្មភាគច្រើនមិនឃើញមានយកអ្វីទៅទេ ហើយទៅមួយថ្ងៃពីរថ្ងៃត្រឡប់មកវិញធ្វើស្រែចម្ការ។ ទាហានអាមេរិកចូលមកក្នុងភូមិ ប៉ុន្តែមិនធ្វើបាបប្រជាជនទេ ហើយ ទាហានអាមេរិកមានបន្ទាយនៅកោះថ្មនិងភូមិពងទឹក។ ពួកវៀតកុងឬវៀតណាមខាងជើងនៅតាមព្រៃនៅជិតប្រភពទឹក ហើយចូលមកក្នុងភូមិរហូត។ ទាហានអាមេរិកតាំងនិង ពួកវៀតកុងធ្លាប់វាយគ្នាពីរទៅបីដងនៅជិតភូមិក្តុលលើ ប៉ុន្តែខ្ញុំមិនបានឃើញដោយផ្ទាល់ទេឮតែសំឡេងកាំភ្លើង។ បន្ទាប់មកមានការរៀបចំធ្វើស្រែចម្ការរួមគ្នា បានផលបែកគ្នា។ ហូបបាយតាមផ្ទះបានរយៈពេល១ឆ្នាំ ខ្មែរក្រហមប្រមូលទ្រព្យសម្បត្តិ មាសប្រាក់ ដីធ្លី គោក្របី ដាក់ចូលជាសម្បត្តិរួម។ ប្រជាជននៅក្នុងភូមិត្រូវគោរពតាមច្បាប់វិន័យរបស់អង្គការ បើហ៊ានធ្វើខុសខ្មែរក្រហមនឹងចាប់យកទៅកសាង។ ក្រុមគ្រួសារខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅភូមិស្រែតាពេជ្រ នៅធ្វើស្រែបាន៩ទៅ១០ថ្ងៃ ខ្មែរក្រហមជម្លៀសទៅភូមិស្អាត ខាងស្រុកស្នួល។ នៅភូមិស្អាតធ្វើការជាមួយប្រជាជននៅទីនោះបានរយៈពេល៣ខែ ខ្មែរក្រហមជម្លៀសទៅស្វាយជ្រះ។ នៅស្វាយជ្រះធ្វើការទាំងយប់ថ្ងៃ ពិបាកហូបចុកណាស់យាយតាចាស់ៗស្លាប់ច្រើន។ បន្ទាប់មកខ្មែរក្រហមជម្លៀសទៅម្ចិច នៅធ្វើការលើកទំនប់ ភ្លឺស្រែ កាប់គាស់រានព្រៃ មើលក្របី ភ្ជួរស្រែ ធ្វើស្រែគ្មានពេលសម្រាក។ បបររាវគ្មានគ្រាប់អង្ករ ហូបមួយថ្ងៃ២ដង នៅតែគ្មានកម្លាំងធ្វើការ។ មនុស្សចាស់ ក្មេង ឈឺ ស្លាប់។ ខ្ញុំបន្តទៅថ្មគ្រែទៅដល់មានការណ៍តាមកយកទៅក្រូចឆ្មារ ហើយជិះឡានទៅភូមិជយោ នៅបាន២ទៅ៣ខែបានហូបបាយឆ្អែត។ បន្ទាប់មកពូចាស់ៗក្នុងភូមិថាអ្នកនៅស្រុកណាទៅនៅស្រុកនោះវិញ។ ខ្ញុំធ្វើដំណើរតាមភូមិបុស្សខ្នុរ ឈប់សម្រាកមួយយប់។ បន្ទាប់មកដើរថ្មើរជើងរហូតមកដល់មេមត់ ដេកមួយយប់ ហើយពេលមកដល់ក្តុលសម្រាក៤ទៅ៥ថ្ងៃទៀត ទាល់តែដោះមីនរួចទើបហ៊ានចូលរស់នៅ។ ចូលមកនៅដំបូងមានតែ៣ទៅ១០គ្រួសារទេ បន្ទាប់មកប្រជាជនចេះតែចូលមកនៅតាមគ្នារហូតមកដល់សព្វថ្ងៃ។

# រឿងរ៉ាវជីវិតរបស់ប្រជាជនក្នុងរបបខ្មែរក្រហម នៅភូមិបុស្សតាអឹម

*ឈុំ រ៉ា និង វ៉ី ស៊ីថា*



ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ ជួបសម្ភាសន៍ជាមួយ កង យីន គឺជាមេភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ ជួប សម្ភាសន៍ជាមួយ សួង សុធី គឺជាប្រជាជននៅភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មរួមមាន ឈុំ រ៉ា និង វី ស៊ីថា បានធ្វើដំណើរទៅកាន់ភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដើម្បីទំនាក់ទំនងជាមួយអាជ្ញាធរ និង ប្រជាពលរដ្ឋក្នុងភូមិបុស្សតាអ៊ឹម ក្នុងគោលបំណងរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅពេលខាងមុខៗ ឆ្លៀតឱកាសនោះ យើងបានជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣រូប ហើយអ្នកទាំងនោះបានរៀបរាប់អំពីប្រវត្តិភូមិ និងរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមដូចខាងក្រោម៖

លោក **កង យីន** គឺជាមេភូមិបុស្សតាអឹម រៀបរាប់អំពីប្រវត្តិរបស់ភូមិនេះដូចតទៅ៖ កាលពីដើមខ្ញុំឮប្រជាជនក្នុងភូមិបុស្សតាអឹមដំណាលតគ្នាថា មានក្រុមគ្រួសារមួយមានកូនបីនាក់ឈ្មោះអឹម, ពេជ្រ និងម៉ៅ។ ពេលកូនៗទាំងបីនាក់ធំឡើងមានប្រពន្ធកូនរៀងៗខ្លួន ក៏នាំគ្នាទៅធ្វើស្រែចម្ការនៅកន្លែងផ្សេងៗគ្នា។ ក្រុមគ្រួសារ ពេជ្រ បានទៅកាប់ឆ្ការដីបុស្ស ហើយរស់នៅត្រង់នោះ សព្វថ្ងៃទីនោះមានឈ្មោះថាភូមិស្រែតាពេជ្រ។ ចំពោះគ្រួសារ ម៉ៅបានទៅរស់នៅ ទីតាំងមួយ ដែលបច្ចុប្បន្នប្រជាជនហៅថា

ភូមិជាំតាម៉ៅ។ ចំណែកក្រុមគ្រួសារឈ្មោះ អឹម គឺបាននៅធ្វើស្រែ ចម្ការ កាប់ឆ្ការដីបុស្សនៅត្រង់ភូមិបុស្សតាអឹមនេះមុនគេ ហើយគាត់មានសណ្ដានចិត្តល្អ ធ្វើឲ្យអ្នកភូមិ ស្រឡាញ់ចូលចិត្ត គោរពសរសើរ រីឯតាអឹមក៏ធ្វើអំពើល្អទៅលើប្រជាពលរដ្ឋនៅក្នុងភូមិដែរ។ នៅពេលគាត់ស្លាប់ទៅអ្នកភូមិបាននាំគ្នាហៅឈ្មោះភូមិនេះថា ភូមិបុស្សតាអឹមរហូតមកដល់សព្វថ្ងៃនេះ ដើម្បីជាការនឹករឭកដល់ តាអឹម ដែលបានកាប់ឆ្ការដីបុស្សនៅក្នុងភូមិនេះ។ សព្វថ្ងៃនេះភូមិបុស្សតាអឹមមានប្រជាជនរស់នៅចំនួន១០៦២នាក់ ស្រី៥៤៩ នាក់ ក្នុងនោះចាប់ពីអាយុ១៨ឡើង មានចំនួន ៧០៥នាក់ បើគិតជាគ្រួសារមានចំនួន ២៨៥គ្រួសារ។

លោក សួង សុធី ភេទប្រុស អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ សួង ធី មានប្រពន្ធឈ្មោះ លឿង សុខឡេង មានកូនចំនួន៣នាក់ ក្នុងនោះមានស្រី២នាក់ បានរៀបរាប់ថា ៖ កាលពីកុមារភាពខ្ញុំទៅរស់នៅជាមួយឪពុកធ្វើជា ទាហាននៅ ទីក្រុងភ្នំពេញ។ ថ្វីត្បិតតែខ្ញុំរស់នៅជាមួយឪពុកមែនប៉ុន្តែ ខ្ញុំមិនបានជួបគាត់ទេ ព្រោះគាត់មិនសូវនៅផ្ទះ។ ព្រឹកឡើងខ្ញុំដឹងតែទៅរៀននៅសាលាសន្ធរម៉ុក។ ពេលនោះខ្ញុំជិតប្រឡងចូលអនុវិទ្យាល័យ ប៉ុន្តែមិនទាន់បានប្រឡងឡើយ។ ក្រោយពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាប់ទៅសម្លាប់ ព្រោះឪពុកខ្ញុំជាទាហាន លន់ នល់។ ខ្មែរក្រហមចាប់ផ្ដើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ខ្មែរក្រហមបាននិយាយថា នៅ ទីក្រុងខ្វះស្បៀងសម្រាប់ហូបណាមួយខ្លាចអាមេរិកទម្លាក់គ្រាប់បែក។ ខ្ញុំត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញមករស់នៅភូមិជើងព្រៃ ឃុំជើងព្រៃ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ទម្រាំមកដល់ខេត្តកំពង់ចាម ខ្ញុំធ្វើដំណើរអស់រយៈពេល ១សប្ដាហ៍។ ខ្ញុំបានមករស់នៅជាមួយម្ដាយធំ ដែលជាសាច់ញាតិខាងម្ដាយ។ ដំបូងខ្ញុំចូលជាកងកុមារ



វី ស៊ីថា បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តត្បូងឃ្មុំ ជួបសម្ភាសន៍ជាមួយ ស៊ិន ញិប គឺជាប្រជាជននៅភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងភូមិជើងព្រៃ។ បន្ទាប់មក នៅក្នុងភូមិជើងព្រៃមានការបែងចែកប្រជាជនចំនួន៣ប្រភេទ គឺប្រជាជនចាស់ ប្រជាជន១៧ ៣ និងប្រជាជនថ្មី។ ខ្ញុំត្រូវខ្មែរក្រហមចាត់ទុកជាប្រជាជនថ្មី។ នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មីចេញពីភូមិ ដោយប្រាប់ថាឲ្យទៅរស់នៅភូមិថ្មីមួយទៀត។ ប្រជាជនដែលត្រូវបានខ្មែរក្រហមជម្លៀសចេញពីដំបូង គឺមិនដែលឃើញត្រឡប់មកវិញទេ។ នៅឆ្នាំ១៩៧៨ ខ្ញុំចូលក្នុងក្រុមកងចល័ត លើកប្រព័ន្ធភ្លឺស្រែ លើកទំនប់ រហូតដល់ខេត្តកំពង់ធំ។ នៅក្នុងកងចល័ត គឺពិបាកខ្លាំងណាស់ ព្រោះការហូបចុកមិនដែលបានគ្រប់គ្រាន់នោះទេ។ ប្រជាជននៅក្នុងកងស្លាប់ជារៀងរាល់ថ្ងៃ ដោយសារតែអត់មានអាហារ។ ចំណែកខ្ញុំក៏ជិតស្លាប់ដែរ ប៉ុន្តែបានចាកចេញពីកងចល័តខេត្តកំពង់ធំទាន់ពេលវេលា។ ចូលដល់ឆ្នាំ១៩៧៩ ខ្ញុំចូលបម្រើនៅក្នុងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយជាមួយខ្មែរក្រហម នៅខេត្តកំពង់ធំ។ នៅឆ្នាំ១៩៨៥ ខ្ញុំត្រូវរបួសដៃនៅក្នុងសមរភូមិស្វាយចេក និងពិការរហូតមកដល់សព្វថ្ងៃ។

ខ្ញុំឈ្មោះ ស៊ិន ញិប ភេទស្រី អាយុ៦៤ឆ្នាំ មានទីកន្លែងកំណើតនៅភូមិតាម៉ៅ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្នខេត្តត្បូងឃ្មុំ។ ខ្ញុំមាន

ឪពុកឈ្មោះ ស៊ិន និង ម្តាយឈ្មោះ ឆេង។ ឪពុករបស់ខ្ញុំស្លាប់នៅក្នុងជំនាន់ខ្មែរក្រហម ពេលនោះគាត់គឺជាកម្មាភិបាលនៅសហករណ៍។ កាលពីសម័យខ្មែរក្រហម ខ្ញុំមិនបានរស់នៅក្បែរឪពុកម្តាយទេ។ កម្មាភិបាលខ្មែរក្រហមចាត់ខ្ញុំឲ្យទៅលើកទំនប់នៅបឹងក្រចាប់ ដោយធ្វើការទាំងយប់ទាំងថ្ងៃ។ នរណាមិនទៅធ្វើការងារគឺខ្មែរក្រហមមិនចែករបបបាយបុបបរឲ្យហូបទេ។ មុនពេលទៅធ្វើការខ្មែរក្រហមតែងតែប្រជុំដាស់តឿនឲ្យប្រជាជនស្មោះត្រង់ជាមួយអង្គការ និងខិតខំធ្វើការងារឲ្យអស់ពីកម្លាំងកាយចិត្ត កុំលាក់កម្លាំង កុំធ្វើខុសច្បាប់ និងវិន័យរបស់អង្គការ។ សព្វថ្ងៃខ្ញុំគឺជាស្ត្រីមេម៉ាយរស់នៅពឹងផ្អែកទៅលើការត្បាញកន្ទេលលក់ដើម្បីចិញ្ចឹមកូន៩ នាក់។ ខ្ញុំកាប់ដើមរុនមកធ្វើជាកន្ទេល និងក្រងស្បូវលក់។ ការកាប់ដើមរុន ប្រើរយៈពេលយូរ ព្រោះដើមរុនពិបាករក ហើយពេលដែលកាប់បាន ត្រូវយកមកពុះមួយដើមជាបួនចម្រៀករួចដាក់ហាលឲ្យស្ងួត។ បន្ទាប់មក ត្រូវយកមកសិតឲ្យស្អាត រួចយកទៅត្បាញ និងដេរជាកន្ទេល។ នៅពេលដែលធ្វើកន្ទេលរួចរាល់ គឺមានឈ្មួញមកទិញដល់ផ្ទះមិនដែលសល់ឡើយ។



កាដាររបស់បងប្អូនជនជាតិស្អៀង នៅឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សម្បុកក្រចៅដែលប្រជាជនក្នុងឃុំជាំតាម៉ៅ ប្រើប្រាស់ជាចំណងសម្រាប់ចងឧបករណ៍នេសាទ និងកសិកម្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



តុំសម្រាប់ដាក់ត្រីរបស់ប្រជាជន នៅឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



កន្ទេលដែល ស៊ិន ញ៉ិប ត្បាញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិក្តុលលើ

***គីម សុវណ្ណដានី***



ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំចំនួន៩០នាក់ ដែលបានផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជា តាំងពីឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ពីថ្ងៃទី១៨, ១៩ និង២០ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាពិនិត្យសុខភាពជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ចំនួន៩០នាក់ ដែលបានផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជា ដែលចុះសម្ភាសន៍តាំងពីឆ្នាំ២០២១។ តាមរយៈលទ្ធផលនៃការពិនិត្យសុខភាពរកឃើញជំងឺ៣ប្រភេទចម្បងគឺ៖ ១) ជំងឺលើសឈាម ៩៨ ភាគរយ ២) ជំងឺក្រពះពោះវៀន ៥០ភាគរយ ៣) និងជំងឺសន្លាក់ ៨៥ ភាគរយ។ ចំពោះជំងឺទឹកនោមផ្អែមមានតែ ១០ភាគរយ ប៉ុណ្ណោះ។

វេជ្ជបណ្ឌិត ដោក រដ្ឋា សង្កេតឃើញថា របបអាហាររបស់អ្នកភូមិក្តុលលើ គឺចូលចិត្តហូបអាហារប្រៃ និងអាហារផ្អាប់ទុកយូរ ដូចជា ផ្អក ប្រហុក ជ្រក់ត្រីប្រឡាក់ និងសាច់ប្រឡាក់ ដែលប្រើប្រាស់អំបិលច្រើន។ បន្ថែមលើនេះ ពេលបរិភោគអាហារ អ្នកភូមិភាគច្រើនបន្ថែមទឹកជ្រលក់ ដូចជាទឹកត្រី និងទឹកស៊ីអ៊ីវជាដើម។ វេជ្ជបណ្ឌិត ដោក រដ្ឋា បានណែនាំអ្នកជំងឺឲ្យផ្លាស់ប្តូររបបអាហារ ដើម្បីជួយពន្លឿន



ក្រុមការងាររគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំចំនួន៩០នាក់ ដែលបានផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជាតាំងពីឆ្នាំ២០២១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ការព្យាបាលឲ្យកាន់តែមានប្រសិទ្ធភាព ព្រោះតាមការពិនិត្យ និងប្រឹក្សាយោបល់ដល់អ្នកជំងឺ ឃើញថា ទោះបីជាអ្នកជំងឺផឹកថ្នាំទៀងទាត់ក៏សម្ពាធឈាម និងស្ថានភាពជំងឺពុំបានធូរស្បើយឡើយ។ ដូច្នេះហើយ ទើបវេជ្ជបណ្ឌិត ដោក រដ្ឋា លើកឡើងថា គ្រូពេទ្យបានត្រឹមតែណែនាំ និងចេញវេជ្ជបញ្ជាជូនដល់អ្នកជំងឺ ប៉ុន្តែប្រសិនបើអ្នកជំងឺមិនតមចំណីអាហារដែលពេទ្យហាមឃាត់ ឬក៏ផ្លាស់ប្តូររបបអាហារតាមការណែនាំរបស់ពេទ្យ គឺមិនអាចព្យាបាលជាសះស្បើយទេ។ ជាពិសេស ជំងឺលើសឈាម អាចឈានដល់ការស្លាប់មួយចំហៀងខ្លួន ឬដល់កម្រិតធ្ងន់ធ្ងរ ដែលអ្នកជំងឺត្រូវសម្រាន្តនៅកន្ទេលអស់មួយជីវិត។

ភូមិក្តុលលើ មានប្រជាពលរដ្ឋប្រមាណ៩០ភាគរយ គឺជាជនជាតិដើមភាគតិចស្ទៀង ដែលប្រកបរបរធ្វើស្រែ, ចម្ការកៅស៊ូ, ចម្ការស្វាយ, ចម្ការម្រេច, ចម្ការទុរេន, ចម្ការសាវម៉ាវ។ ដោយឡែកបន្លែដែលប្រមូលផលឆាប់រួមមាន ពោត និងសណ្តែកតាមរដូវកាល។ តាំងពីយូរលង់ណាស់មកហើយ ពេលដែលមានជំងឺដង្កាត់ផ្សេងៗ ជនជាតិដើមភាគតិចស្ទៀងតែងតែប្រើវិធីតាមព្រហ្មញ្ញសាសនា ដូចជាសែនអ្នកតា ការបញ្ជាន់អារក្ស សំពះគ្រូបាធ្យាយ និងការប្រើវិធីសាស្ត្រអុជព្យាបាលជំងឺ ដែលជនជាតិដើមភាគតិចស្ទៀងហៅថា អណ្តើក អាវ៉ុស ពិសកុក។ ការព្យាបាលនេះ គឺតាមការស្មានដោយអុជឲ្យបាត់ឈឺ រួមមាន ឈឺពោះ ចុកពោះ គ្រុនក្តៅខ្លួន ព្រោះពេលដែលឈឺក្នុងពោះមានសភាពរឹង ដែលអ្នកជំនាញអុជព្យាបាលហៅថា អណ្តើក។ ពេលដែលអុជរួច គឺសភាពរឹងនោះនឹងបាត់ទៅវិញព្រមគ្នានឹងរោគសញ្ញាផ្សេងៗ ដោយបន្ថែមការដាំថ្នាំស្លឹកឈើឬសឈើ សម្បកឈើ។ វិធីសាស្ត្រអុជព្យាបាលនេះគឺប្រើ ធូប ប៉ុយ ខ្សែ សម្បកឬសំឡឹក និងកំបោរដើម្បីអុជតាមអាការៈដែលកើតមាន។ ការអុជព្យាបាលជំងឺនេះ គឺអុជម្តុំពោះ និងមានខ្លះទៀតអុជដល់ទ្រូង ហើយការអុជនេះធ្វើឡើងដោយព្រឹទ្ធាចារ្យដែលមានវ័យចំណាស់ និងធ្លាប់មានបទពិសោធន៍តាំងពីដើមមក។ បន្ទាប់ពីអុជរួច គ្រូព្យាបាលជំងឺប្រើផេះ ដើម្បីលាបលើស្នាមអុជកុំឲ្យមានដំបៅ និងឲ្យឆាប់ផ្សះ។ ចាប់តាំងពីឆ្នាំ២០០០ ជំនឿទាំងនេះចាប់ផ្តើមបាត់បង់បន្តិចម្តងៗ ដោយប្រជាជនចាប់ផ្តើមយល់ដឹងអំពីការព្យាបាលតាមវិទ្យាសាស្ត្រសុខាភិបាល ដែលមានប្រសិទ្ធភាពខ្ពស់ជាងការព្យាបាល ដោយប្រើថ្នាំបុរាណ។ បន្ថែមលើនេះទៀត ខាងមន្ទីរសុខាភិបាល មានពេទ្យខេត្ត ពេទ្យស្រុកបានចុះមកជួយពន្យល់ពីការដាក់ថ្នាំកម្ចាត់មូសខ្លា និងការសម្អាតអនាម័យតាមភូមិ ដែលបានជួយកាត់បន្ថយការចម្លងជំងឺគ្រុនឈាម ដោយរដូវនេះជារដូវវស្សា ដែលអាចបង្កើតនូវជម្រកមូសខ្លាបាន ប្រសិនបើមិនមានការយល់ដឹងពីវិធីសាស្ត្របង្ការ។

**ឈម ផាត** អាយុ៣៣ឆ្នាំ ភេទស្រី ត្រូវជាកូនរបស់នាយ ឈមបានរៀបរាប់ថាឪពុករបស់គាត់នាយ ឈម បានទទួលមរណភាព កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ក្នុងអាយុ៦៨ឆ្នាំ ដោយជំងឺរលាកក្រពះរលាកសួត និងជំងឺឈាមសស៊ីឈាមក្រហម។ ឪពុក

របស់គាត់បានសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាមរយៈពេល១២ថ្ងៃ បន្ទាប់មកវិលត្រឡប់មកព្យាបាលនៅផ្ទះបន្តដោយលេបថ្នាំ។ តាមសម្តីរបស់ ផាត បានឲ្យដឹងបន្ថែមថា ឪពុករបស់គាត់មិនដែលបានពិនិត្យសុខភាពទេ។ ឪពុករបស់គាត់មិនព្រមទៅពិនិត្យសុខភាព និងទទួលការព្យាបាលនៅមន្ទីរពេទ្យទេ គឺឪពុករបស់គាត់បានទិញថ្នាំនៅ ហ្វាម៉ាស៊ី ដើម្បីព្យាបាលពេលមានជំងឺក្អកតែប៉ុណ្ណោះ។ ឈម ផាត បានបញ្ជាក់បន្ថែមថា ប្រសិនបើឪពុករបស់ខ្ញុំព្រមទៅទទួលការព្យាបាលតាំងពីឆ្នាំមុន គាត់នឹងអាចព្យាបាលជា ព្រោះពេទ្យដឹងរោគសញ្ញា និងឲ្យថ្នាំមកត្រូវនឹងជំងឺ។ ឈម ផាត មានអារម្មណ៍ត្រេកអរណាស់ដែលបានមកទទួលសេវាពិនិត្យសុខភាពដោយ ឥតគិតថ្លៃជំនួសឪពុក ព្រោះ ផាត មិនធ្លាប់ដឹងថា ខ្លួនមានជំងឺលើសសម្ពាធឈាមទេពីមុនមក។ លោកគ្រូពេទ្យ ផ្តល់យោបល់ឲ្យ ឈម ផាត ទៅពិនិត្យអេកូបន្ថែមនៅមន្ទីរពេទ្យដើម្បីស្វែងរកពីជំងឺចុករួយជើងទាំងសងខាង។ ក្នុងនោះដែរ ឈម ផាត ចាប់អារម្មណ៍ចំពោះចំណីអាហារដែល ហូបប្រចាំថ្ងៃ គឺចូលចិត្តសម្លផ្អែម និងភេសជ្ជៈប៉ូវកម្លាំង ដែលអាចមានជំងឺទឹកនោមផ្អែម និងជាកត្តាដែលធ្វើឲ្យ ឈម ផាត មានជំងឺលើសឈាម។ ជាចុងក្រោយ ឈម ផាត អរគុណដល់ក្រុមការងារ ដែលអនុញ្ញាតឲ្យទទួលសេវាពិនិត្យសុខភាពជំនួសឪពុក និងបានដឹងពីស្ថានភាពសុខភាពរបស់ខ្លួនដោយមិនអស់ថ្លៃសេវាពិនិត្យ និងធ្វើដំណើរទៅមន្ទីរពេទ្យ។

**ម៉ាត់ ភាក់** អាយុ៤១ឆ្នាំ មេភូមិក្តុលលើ មានសេចក្តីត្រេកអរក្រៃលែងដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមទាំងលោកគ្រូ អ្នកគ្រូពេទ្យ ដែលបានចុះមកពិនិត្យសុខភាពដល់ប្រជាពលរដ្ឋក្នុងភូមិដល់ទីកន្លែង និងជួយជាថវិកាឧបត្ថម្ភដើម្បីឲ្យប្រជាពលរដ្ឋអាចធ្វើដំណើរទៅពិនិត្យសុខភាពបន្ថែមនៅពេលក្រោយ ជាពិសេសប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាត។ ការចុះមកពិនិត្យសុខភាពអ្នកភូមិដល់ទីតាំងនេះគឺ ទី១ ជួយដល់អ្នកភូមិបានពិនិត្យសុខភាពដើម្បីព្យាបាល និងថែទាំសុខភាពឲ្យបានល្អប្រសើរ, ទី២ ជួយសម្រួលដល់ការចំណាយថវិកាលើការពិគ្រោះ និងពិនិត្យសុខភាព ក៏ដូចជាការទិញថ្នាំព្យាបាលដល់ប្រជាពលរដ្ឋ និងទី៣ ជួយសម្រួលដល់ការធ្វើដំណើរឆ្ងាយទៅពិនិត្យសុខភាព ដែលប្រជាពលរដ្ឋត្រូវចំណាយថវិកាផ្ទាល់ខ្លួន។ ម៉ាត់ ភាក់ គឺជាមេភូមិបង្ហាញការគាំទ្រ និងសំណូមពរដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ជួយសម្រួលរៀបចំកម្មវិធីពិនិត្យសុខភាពឲ្យបានញឹកញាប់ដល់ប្រជាពលរដ្ឋដែលមានការខ្វះខាត ឲ្យបានយល់ដឹងបន្ថែមពីបញ្ហាថែទាំសុខភាព។

តាមការសាកសួរមតិពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចូលរួមទទួលសេវាពិនិត្យសុខភាពរយៈពេល៣ថ្ងៃនេះ ១) ញឹក ញ៉ាល់ អាយុ ៧៩ឆ្នាំ ភេទប្រុស ២) ចប ម៉ូ អាយុ ៦២ឆ្នាំ ភេទប្រុស ៣) កន សេង អាយុ ៨២ឆ្នាំ ភេទប្រុស និង៤) យ៉ុល ម៉ួយ អាយុ ៦២ឆ្នាំ ភេទប្រុស គឺមានការសប្បាយចិត្ត និងអរគុណដល់ក្រុមការងារ ក៏ដូចជា លោកគ្រូពេទ្យ អ្នកគ្រូពេទ្យ ដែលបានចំណាយពេលវេលាចុះមកពិនិត្យសុខភាពដល់ភូមិផ្ទាល់ ដែលបានជួយសម្រួលដល់ការធ្វើដំណើរឆ្ងាយ និងការព្យាបាលនៅមន្ទីរសម្រាកព្យាបាលឯកជន ក៏ដូចជាមណ្ឌលសុខភាពរដ្ឋ។ ជាពិសេស អ៊ំពូមីង ដែលកំពុងតែមានជំងឺស្រាប់បានទទួល សេវាពិនិត្យសុខភាពនៅជិតផ្ទះតែម្តង។ ការពិនិត្យសុខភាពនេះ អ៊ំពូមីង ជឿជាក់ថា នឹងអាចជួយព្យាបាលជំងឺគាត់ឲ្យបានធូរស្បើយ មានស្ថានភាពសុខភាពប្រសើរឡើងវិញ ដោយលោកគ្រូពេទ្យមានបទពិសោធន៍ច្បាស់លាស់ និងបានណែនាំគាត់ឲ្យយល់ដឹងបន្ថែមពីការវិវត្តន៍ធ្ងន់ធ្ងរនៃជំងឺប្រសិនបើមិនមានការព្យាបាលត្រឹមត្រូវ និងទាន់ពេលវេលា។



ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ចំនួន៩០នាក់ ដែលបានផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជាតាំងពីឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាថ្នាក់រៀនស្តីអំពី «របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស» សម្រាប់សិស្សវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន មេមត់

*សុភ័ក្ត្រ ភាណា*



នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀន ស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស ដោយមានសិស្សានុសិស្ស ចំនួន៤៥នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ មកចូលរួម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស ដោយមានសិស្សានុសិស្សចំនួន៤៥នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ មកចូលរួម។

គោលបំណងនៃវេទិកាថ្នាក់រៀនថ្ងៃនេះ គឺផ្តល់ឲ្យសិស្សានុសិស្សនូវការយល់ដឹងទូលំទូលាយ លើបរិបទប្រវត្តិសាស្ត្រ និងទំនាក់ទំនងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្លឹមសារដែលលើកយកមកបង្ហាញក្នុងថ្ងៃនេះ គឺផ្តោតទៅលើទំនាក់ទំនងការបរទេសទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

អ្នកស្រី សុភ័ក្ត្រ ភាណា គឺជាគ្រូឧទ្ទេស បានផ្តល់នូវព័ត៌មានដោយសង្ខេប លើការប្រាស្រ័យទាក់ទងផ្លូវទូតរបស់ប្រទេសកម្ពុជា ជាមួយប្រទេសជិតខាង,



នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារ កោះថ្ម បានរៀបចំវេទិកាថ្នាក់រៀន ស្ដីពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទំនាក់ទំនងការបរទេស ដោយមានសិស្សានុសិស្ស ចំនួន៤៥នាក់ មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ មកចូលរួម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ថាប័នអន្តរជាតិ និងប្រទេសមានឥទ្ធិពលដទៃទៀត នៅក្រោមការដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្លឹមសារមេរៀន ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ តាមរយៈព័ត៌មានប្រវត្តិសាស្ត្រ, ឧទាហរណ៍ និងរូបភាពជំនួយនានា។

បន្ទាប់មកអ្នកស្រី សុភ័ក្ត្រ ភាណា បានបង្កើតសកម្មភាពសិក្សា ពិភាក្សា ដល់សិស្សានុសិស្ស តាមរយៈការចែករំលែកចំណេះដឹង និងការយល់ឃើញរបស់ខ្លួន ព្រមទាំងលើកទឹកចិត្តឲ្យសិស្សចោទជាសំណួរ, ចែករំលែកមតិយោបល់ និងចូលរួមជជែកវែកញែក។ វិធីសាស្ត្រជំរុញនូវការសិក្សាយ៉ាងសកម្មនេះ ញាំងឲ្យសិស្ស កែប្រែទម្លាប់ពីអ្នកត្រងត្រាប់ស្ដាប់ពីគ្រូ ទៅជាអ្នកចូលរួមចំណែកយ៉ាងសកម្មនៅក្នុងដំណើរការរៀនសូត្រវិញ។

នៅចុងបញ្ចប់នៃថ្នាក់រៀន សិស្សានុសិស្សទទួលបានចំណេះដឹងច្រើនជាងមុន ពាក់ព័ន្ធនឹងប្រវត្តិ-សាស្ត្រ និងទំនាក់ទំនងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ សិស្សានុ-សិស្ស អាចវិភាគ និងវាយតម្លៃអំពីឥទ្ធិពលនៃការចូលរួមពីអន្តរជាតិ ទៅលើស្ថានភាពនយោបាយ និងសង្គមនៃប្រទេសកម្ពុជា ហើយវេទិកាថ្នាក់រៀននេះក៏បានផ្ដល់ឲ្យសិស្សានុសិស្សនូវការយល់ឃើញ





ទូលំទូលាយជាងមុន លើបរិបទប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ថែមទៀតផង។

# មជ្ឈមណ្ឌលឯកសារកោះថ្ម ត្រួតពិនិត្យ និង វាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បាន

## ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និង វិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍»

ធ្យុង ដានី



ការត្រួតពិនិត្យ និង វាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ ( ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បានរៀបចំធ្វើការត្រួតពិនិត្យ និងវាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន «ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍»។ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានជ្រើសរើសយកវិទ្យាល័យចំនួនបីដែលក្នុងមួយវិទ្យាល័យជ្រើសយកសិស្សចំនួន៥នាក់ ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃការសិក្សា។ សកម្មភាពដែលក្រុមការងារបានជួបសិស្សានុសិស្ស ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃការសិក្សានៅតាមវិទ្យាល័យនីមួយៗមានដូចខាងក្រោម ៖

### ១) វិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន លាជលើ ៖

នៅវេលាម៉ោង០៨:០០ព្រឹក ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មបានធ្វើដំណើរទៅដល់វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនលាជលើ និងបានជួបនាយកវិទ្យាល័យ ស៊ុំ គុងហេង ដើម្បីស្នើសុំជួបសិស្ស



ការត្រួតពិនិត្យ និង វាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។
( ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ចំនួន៥នាក់ដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន «ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍» នៅមជ្ឈមណ្ឌលឯកសារកោះថ្មកន្លងមក។

លោក ស៊ុំ តុងហេង បានអនុញ្ញាតឲ្យសិស្សចំនួន៥នាក់ស្រី២នាក់ និងប្រុស៣នាក់ដើម្បីជួបជាមួយក្រុមការងារ។ ជាកិច្ចបន្ទាប់លោក ឡុង ដានី បានណែនាំ និងពន្យល់នូវសំណួរក្នុងតារាងស្ទាបស្ទង់មតិទៅកាន់សិស្សានុសិស្សទាំង៥នាក់។ នៅវេលាម៉ោង០៨:២០នាទីព្រឹក សិស្សចាប់ផ្តើមបំពេញកម្រងសំណួរដោយយកចិត្តទុកដាក់។ សិស្សទាំង៥នាក់បានសរសេរចម្លើយ ទាំងអស់យ៉ាងឆាប់រហ័ស។ សិស្សបាននិយាយថាក្រោយពេលចូលរួមវេទិកាថ្នាក់រៀនកន្លងមក គាត់បានចែករំលែករឿងរ៉ាវដែលធ្លាប់បានសិក្សារៀនសូត្រទៅដល់ គ្រួសារ មិត្តភក្តិ និងអ្នកភូមិដែលខ្លួនកំពុងរស់នៅ។ ជាចុងក្រោយ សិស្សសំណូមពរឲ្យមានការរៀនលម្អិតអំពីប្រវត្តិ-សាស្ត្រខ្មែរក្រហមឲ្យបានកាន់តែច្រើនបន្ថែមទៀត។

**២) វិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន ស្រែតានងកើត ៖**

នៅម៉ោង០៩:១៥នាទីព្រឹក ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើដំណើរចេញពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែនលាជលើ ឆ្ពោះទៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្រែតានងកើត។ លោកគ្រូអ្នកគ្រូបានចេញមកទទួលស្វាគមន៍ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មយ៉ាងកក់ក្តៅ។ នៅវេលាម៉ោង១០:០០នាទីព្រឹក លោក ឡុង ដានី បានជួប និង ពន្យល់សំណួរក្នុងតារាងស្ទាបស្ទង់មតិទៅកាន់សិស្សានុសិស្សចំនួន៥នាក់ គឺស្រី៣នាក់ និងប្រុស២នាក់ ដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន «ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍» កាលពីខែមីនា ឆ្នាំ២០២៣ កន្លងមក។ បន្ទាប់មកបានបំពេញកម្រងសំណួរដោយយកចិត្តទុកដាក់។ សិស្សសរសេរចម្លើយទៅតាមការយល់ដឹងរបស់ខ្លួន។ សិស្សនៅវិទ្យាល័យស្រែតានងកើត ពិតជាទទួលបានការបណ្តុះបណ្តាលពីគ្រូ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងបានចែករំលែកចំណេះដឹងរបស់



ការត្រួតពិនិត្យ និង វាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។
(ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)





ខ្លួនដែលបានរៀនសូត្រទៅដល់ក្រុមគ្រួសារ មិត្តភក្តិនៅក្នុងសាលារៀន និងមូលដ្ឋានដែលគាត់រស់នៅថែមទៀត។

## ៣) វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន មេមត់ ៖

នៅពេលរសៀលម៉ោង២ ថ្ងៃដដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មបានធ្វើដំណើរទៅដល់វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់។ ពេលនៅដល់លោកគ្រូ អ្នកគ្រូ និងសិស្ស ចំនួន៥នាក់ ស្រី៣នាក់និងប្រុស២នាក់ កំពុងរង់ចាំទទួលក្រុមការងារជាស្រេច។ លោក ឡុង ដានី បានណែនាំខ្លួន និងឈ្មោះក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស និង និយាយ សំណេះ សំណាល ជាមួយ លោក គ្រូអ្នកគ្រូ ប្រមាណ១៥នាទី។ បន្ទាប់មក លោក ឡុង ដានី បានធ្វើការពន្យល់សិស្សានុសិស្សអំពីកម្រងសំណួរ ដើម្បីឲ្យសិស្សានុសិស្សងាយស្រួលយល់។ នៅពេលគាត់កំពុងពន្យល់ គាត់យល់ឃើញថាសិស្សានុសិស្សមានចំណេះដឹងច្រើននិងយល់អំពីសំណួរ។ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកកម្រងសំណួរឲ្យសិស្សានុសិស្សបំពេញ។ សិស្សានុសិស្សចាប់ផ្តើមបំពេញកម្រងសំណួរយ៉ាងរហ័ស និងបានចប់សព្វគ្រប់នូវសំណួរទាំង៧ នៅវេលាម៉ោង០៣:០០នាទីរសៀល។ សិស្សបានបំពេញកម្រងសំណួរប្រកបដោយភាពក្លាហាន និងជឿជាក់ដោយប្រើរយៈពេលខ្លី។ ដូចនេះសិស្សានុសិស្សនៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន មេមត់ ពិតជាទទួលបានចំណេះដឹងច្រើន «ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍» ។



វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនលាជលើ។
(ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំសហគមន៍ស្តីពីជីវិតរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្ទៀង

## នៅក្នុងរបបខ្មែរក្រហម (១៩៧៥ -១៩៧៩)នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

ឡុង ដានី ឈុំ រ៉ា និង ទីស៊ីថា





មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីជីវិតរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្ទៀង នៅក្នុងរបបខ្មែរក្រហម នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៧: ៣០នាទីព្រឹក ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣៣នាក់ (ស្រី១៨នាក់) ដែលភាគច្រើនជាជនជាតិដើមភាគតិចស្ទៀង រស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងសិស្សានុសិស្សចំនួន១៨នាក់ (ស្រី៩នាក់) មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ក្តុលផ្សារ បានមកជួបជុំគ្នានៅបរិវេណសាលាបុណ្យភូមិក្តុលលើ ដើម្បីចូលរួមវេទិកាអប់រំសហគមន៍។ គោលបំណងក្នុងការបង្កើតវេទិកានេះ គឺដើម្បីផ្តល់ឱកាសសន្ទនាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្មេងជំនាន់ក្រោយស្តីអំពីជីវិតរស់នៅរបស់ជនជាតិដើមភាគតិចស្ទៀង នៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មរួមមាន៖ ឡុង ដានី សុខ វណ្ណៈ ឈុំ រ៉ា និងវី ស៊ីថា បានចាប់ផ្តើមវេទិកាសហគមន៍ដូចខាងក្រោម៖

ជាកិច្ចចាប់ផ្តើមលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានធ្វើការណែនាំខ្លួន និងក្រុមការងារជូនដល់លោកតាលោកយាយ អ៊ុំ ពូមីង និងប្អូនៗសិស្សានុសិស្សដែលបានចូលរួមក្នុងវេទិកានេះ។ បន្ទាប់មកលោក ឡុង ដានី បានធ្វើបទបង្ហាញជាសង្ខេបទាក់ទងនឹងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម



មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាអប់រំសហគមន៍ ស្តីពីជីវិតរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្មៀង នៅក្នុងរបបខ្មែរក្រហម នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និងជាពិសេសអំពីជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) និងបានរៀបរាប់ជាសង្ខេបអំពីដំណើរការកាត់ក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) នៅអង្គជំនុំជម្រះក្នុងតុលាការកម្ពុជាដែលចៅក្រម និងសហព្រះរាជអាជ្ញាបានចាប់ផ្តើមការងារពីខែកក្កដា ឆ្នាំ២០០៦ រហូតដល់ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២។ ក្នុងនោះមានជនជាប់ចោទចំនួន៥នាក់ត្រូវបាននាំយកមកកាត់ទោសរួមមាន៖ ១) នួន ជា អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ២) ខៀវ សំផន គណប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ៣) អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ៤) អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និង ៥) កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រធានប្រធានមន្ទីរសន្តិសុខ ស-២១ នៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

ជាកិច្ចបន្តក្រុមការងារបានបែងចែកអ្នកចូលរួមវេទិកាជា៤ក្រុម ក្នុងមួយក្រុមៗមានចំនួន១១ទៅ



១២នាក់ដោយរួមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សានុសិស្ស។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអាចចែករំលែកបទពិសោធន៍រស់នៅក្នុងរបបខ្មែរក្រហមដល់សិស្សានុសិស្ស។ ចំណែកសិស្សានុសិស្សអាចស្តាប់ កត់ត្រា និងសួរសំណួរទៅកាន់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាន។ សកម្មភាពសង្ខេបៗរបស់ក្រុមទាំង៤មានដូចខាងក្រោម៖

### ក្រុមទី១
### អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

ស៊ីន ញឹម ភេទស្រី អាយុ ៦៨ឆ្នាំ ជាជនជាតិដើមភាគតិចស្ទៀងមានស្រុកកំណើតនៅភូមិតាម៉ៅ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ រៀបរាប់ថា កាលពីសម័យខ្មែរក្រហម ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានក្រុមកុមារនៅក្នុងភូមិ។ បន្ទាប់មកឆ្នាំ១៩៧៦ ទៅធ្វើជាកងចល័តនៅបឹងក្រចាប់។ នៅបឹងក្រចាប់ពិបាកខ្លាំងណាស់សូម្បីតែទឹកស្ទើរមិនបានផឹកផង នៅក្នុងមួយថ្ងៃធ្វើការជីកដី ធ្វើទំនប់សម្រាប់ស្តុកទឹកទាល់ល្ងាច ថ្ងៃខ្លះដល់ពេលយប់ត្រូវធ្វើការបន្ថែមទៀត។ ខ្ញុំនៅធ្វើកងចល័តបឹងក្រចាប់ចំនួន១ខែ បានត្រឡប់មកផ្ទះ។ ដេកផ្ទះបាន៥យប់ ត្រូវធ្វើជាកងចល័តនៅឃុំជាំក្រវៀន ស្រុកមេមត់ ចេញពីក្រវៀនបានទៅដល់ខេត្តក្រចេះ។

### សិស្សានុសិស្សសួរសំណួរ ៖
### ១ តើខ្មែរក្រហមចាប់ផ្តើមកើតឡើងពីពេលណា ?

កន សេង អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានឆ្លើយថា ខ្មែរក្រហមបានចាប់ផ្តើមកើតឡើងតាំងពីពេលដែល លន់ នល់ ទម្លាក់សម្តេចនរោត្តមសីហនុ តែមិនមានទ្រង់ទ្រាយធំទេ គឺទាល់តែឆ្នាំ១៩៧១ ទើបមានពេញស្រុកខ្មែរ ។

### ២ តើខ្មែរក្រហមបានធ្វើអ្វីខ្លះដាក់ប្រជាជន ?

កន សេង និយាយថា ខ្មែរក្រហមមិនឲ្យយើងរស់នៅក្នុងតំបន់ដែលយើងធ្លាប់រស់នៅទេ គឺខ្មែរក្រហមជម្លៀសឲ្យទៅនៅតំបន់ផ្សេង ដែលយើងមិនទម្លាប់រស់នៅ ហើយតម្រូវឲ្យប្រជាជនធ្វើការងាររួម ហូបចុករួមគ្នា ធ្វើការរែកដី ឈឺស្លាប់កំពុងធ្វើការក៏មាន ហើយក្មេងៗជំនាន់នោះមិនសូវបានរៀនសូត្រទេ។ មនុស្សដែលខ្មែរក្រហមយកទៅសម្លាប់ ខ្មែរក្រហមចោទថាជាខ្មាំង បើសិនជាសម្លាប់នរណាម្នាក់ត្រូវសម្លាប់អ្នកជាប់ពាក់ព័ន្ធទាំងអស់ ។

### ៣ តើនៅពេលរំដោះរួចប្រជាជនធ្វើអ្វី ?

កន សេង រៀបរាប់ថា នៅពេលរំដោះឆ្នាំ១៩៧៩រួច រាជរដ្ឋាភិបាលបានជំរុញឲ្យប្រជាជនយើងធ្វើស្រែចម្ការ ដែល មានតំបន់ខ្លះមានការចែកគ្រាប់ពូជ ហើយតំបន់ខ្លះទៀតក៏សន្សំគ្រាប់ពូជដែលនៅសេសសល់ពីជំនាន់ នោះនិងដាំដុះដើម្បីផ្គត់ផ្គង់ការហូបចុកប្រចាំថ្ងៃ ។

### ក្រុមទី២
### អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

កន សេង ភេទប្រុស អាយុ៨០ឆ្នាំ គឺជាជនជាតិភាគតិចស្ទៀងរស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ រៀបរាប់ថា បន្ទាប់ពីរបបលន់ នល់ គឺរបបខ្មែរក្រហម។ កាលពីជំនាន់ ប៉ុល ពត មិនមានព្រះសម្រាប់ធ្វើបុណ្យទេ ព្រោះខ្មែរក្រហមវាយទម្លាក់ទឹកទន្លេអស់ហើយ។ និយាយពីការហូបចុកវិញ គឺមនុស្ស ៣០-៤០នាក់ ហូបអង្ករតែមួយកំប៉ុងប៉ុណ្ណោះ ធ្វើឲ្យយើងមិនមានកម្លាំងធ្វើការឡើយ។ ទាំងនេះជាដើមហេតុដែលបង្កឲ្យមានការលួចអាហារហូបចុក តែនៅក្នុងសម័យនោះមានច្បាប់វិន័យតឹងណាស់។ បើអ្នកណាហ៊ានលួចហូបចុកខុសច្បាប់វិន័យរបស់ខ្មែរក្រហម បើខ្មែរក្រហមចាប់បាន ខ្មែរក្រហមយកទៅដាក់ទោស ឬសម្លាប់ចោលក៏មាន។ សម្រាប់អ្នកចេះដឹង ឬក៏និស្សិតបញ្ញវន្តខ្មែរក្រហមយកទៅសម្លាប់ចោល ដោយទុកតែអ្នកដែលមានកម្លាំងធ្វើជាមេដឹកនាំ។ ខ្លួនខ្ញុំផ្ទាល់ កាលពីសម័យខ្មែរក្រហម គឺរងការគំរាមកំហែងខ្លាំងដែរ តែមិនបានបាត់បង់ជីវិត។ និយាយពីសង្គ្រាមវិញ គឺ



មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីជីវិតរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្ទៀងនៅក្នុងរបបខ្មែរក្រហម នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



មានច្រើនដំណាក់កាលណាស់ ដំនាន់ លន់ នល់ ដេកតែតាមរណ្តៅត្រង់សេ ដើម្បីរស់។ ការងារវិញ ទាល់តែចំណោញបានខ្មែរក្រហមឲ្យយើងធ្វើ។

## សិស្សានុសិស្សសួរសំណួរ ៖
## តើជំនាន់នោះខ្មែរក្រហមប្រជាជនរស់នៅបែបណា ?

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងក្រុមម្នាក់បានរៀបរាប់ថា នៅសម័យខ្មែរក្រហមប្រជាជនហៅគ្នាថា សមមិត្ត ចំពោះក្មេងៗក៏ខ្មែរក្រហមប្រើឲ្យធ្វើការដែរគឺ ធ្វើជី រើសអាចម៌គោ និងមិនបានរៀនសូត្រត្រឹមត្រូវទេ។ ខ្មែរក្រហមប្រើឲ្យយើងធ្វើការច្រើនហើយ ហូបតិច ព្រោះខ្មែរក្រហមគិតតែការចំណោញ។ អ្នកដែលមិនទៅធ្វើការ ខ្មែរក្រហមវាយដំ ទាត់ធាក់ និងបង្អត់អាហារ។ នៅក្នុងសម័យនោះ ភាគច្រើនខ្មែរក្រហមឲ្យយើងហូបបបរស។ លុយកាក់ ទ្រព្យសម្បត្តិ ផ្សារត្រូវបានខ្មែរក្រហមលុបបំបាត់ ចំណែក សាលារៀន វត្ត ត្រូវបានយកធ្វើជាមន្ទីរឃុំឃាំង។ ចំពោះជនជាតិចាម ជនជាតិភាគតិច និងអ្នកចេះដឹងត្រូវបានចាប់ខ្លួន និងចោទថាខ្មាំង។ របបនេះបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

## ក្រុមទី៣
## អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

រឹក អៀង ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិដើមភាគតិចស្អៀង រស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ រៀបរាប់ថា ខ្ញុំត្រូវបានប្រធានសហករណ៍បានចាត់តាំងឲ្យធ្វើការក្នុងកងកុមារ។ នៅក្នុងកងកុមារខ្ញុំមាឌធំជាងគេបន្តិច ហើយការងារត្រូវធ្វើ គឺដើររើសអាចម៌គោ កាប់ដើមទន្ទ្រានខែត្រ សម្រាប់ធ្វើជីដាក់ស្រូវ។ ខ្ញុំមិនសូវបានដេកជាមួយឪពុកម្តាយទេ ព្រោះប្រធានសហករណ៍មិនឲ្យទៅជួបឪពុកម្តាយទេ ទាល់៥-៦ថ្ងៃ ទើបអនុញ្ញាតឲ្យមកលេងឪពុកម្តាយម្តង។ ពេលឃើញឪពុកម្តាយត្រូវបានជម្លៀសចេញទៅនៅស្រុកផ្សេង ខ្ញុំចាប់ផ្តើមយំ ភ័យខ្លាច ព្រោះនៅក្មេង។

## សិស្សានុសិស្សសួរសំណួរ ៖
## តើសហករណ៍បានន័យដូចម្តេច?

រឹក អៀង ឆ្លើយតបថា ពាក្យថាសហករណ៍នៅក្នុងសម័យនោះសំដៅទៅលើការអនុវត្តជារួម ស៊ីបាយរួម និងមានការបែងចែកជាក្រុមដើម្បីប្រមូលកម្លាំងទៅធ្វើការ មានកងបុរស សម្រាប់ភ្ជួររាស់វែកដី។ កងនារីសម្រាប់ស្ទូង ដក ច្រូតកាត់។ កងចល័តគឺធ្វើការពីមួយកន្លែងទៅមួយកន្លែង និងកងកុមារ គឺជាកងដែលមានអាយុក្រោម១១ឆ្នាំ គឺខ្មែរក្រហមប្រើឲ្យធ្វើជី រើសអាចម៌គោ និងរៀនសូត្រតិចតួច។

## ក្រុមទី៤
## អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖

ទេព ឃី ភេទប្រុស អាយុ ៦៩ឆ្នាំ ជនជាតិដើមភាគតិចស្អៀងរស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បានចែករំលែក និងរៀបរាប់ពីជីវិតដែលធ្លាប់បានឆ្លងកាត់ពីសម័យខ្មែរ (១៩៧៥-១៩៧៩) ថា ខ្ញុំត្រូវបានប្រធានដែលជាអ្នកគ្រប់គ្រងស្រុកត្រមូង (បច្ចុប្បន្នស្រុកមេមត់) ចូលមកដល់ក្នុងភូមិក្តុលលើក្នុងឆ្នាំ១៩៧៦ ហើយជ្រើសខ្ញុំធ្វើជាពេទ្យប្រចាំនៅក្នុងឃុំទន្លូង។ នៅក្នុងឃុំទន្លូង មានប្រជាជនតែ២នាក់ប៉ុណ្ណោះ ដែលត្រូវជ្រើសរើសទៅរៀនធ្វើពេទ្យ រួមមានខ្ញុំ និងម្នាក់ទៀតឈ្មោះឪអាកំប៉ោង។ ពេលទៅដល់ស្រុកត្រមូងភ្លាម មេក្រុមបានមកសួរថា តើមានអ្នកណាចេះអក្សរទេ? ខ្ញុំបានឆ្លើយថា ខ្ញុំធ្លាប់បានចូលរៀនចេះអាន និងសរសេរបានខ្លះ បន្ទាប់មក មេក្រុមយកខ្ញុំទៅដាក់កន្លែងផ្សំថ្នាំ ផលិតថ្នាំពីឫសឈើ សម្បកឈើ ហើយគ្រាប់ថ្នាំចេញមកពណ៌ខ្មៅប្រផេះ ដូចជាអាចម៌ទន្សាយអីចឹង។ នៅពេលយប់មួយ អ្នករៀនពេទ្យទាំងអស់ ត្រូវបានខ្មែរ

ក្រហមនាំទៅមើលកុននៅសាលាស្រុកត្រមូង (មេមត់) ហើយកុនដែលបានបញ្ចាំងនោះ គឺជាខ្សែភាពយន្តចិនបេកាំង។ នៅក្នុងកំឡុងពេលកំពុងមើលកុន ស្រាប់តែមានអ្នករៀនពេទ្យដូចគ្នា និយាយថា ពួកយើងនឹងត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ទាំងអស់គ្នា ទុកតែអ្នកដែលមានរូបសម្រស់ស្អាតសម្រាប់បង្កាត់ពូជជាមួយចិនប៉េកាំង។ ក្រោយពេលមើលកុនចប់ ខ្ញុំត្រឡប់មកកន្លែងស្នាក់នៅវិញ ខ្ញុំដេកមិនលក់ ព្រោះខ្លាចខ្មែរក្រហមចាប់យកទៅសម្លាប់។

នៅក្នុងឆ្នាំ១៩៧៧-១៩៧៨ ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅរស់នៅស្រុកស្នួល ខេត្តក្រចេះ។ ពេលនោះប្រធានកងធំឲ្យខ្ញុំធ្វើប្រធានក្រុម ដែលមានសមាជិកចំនួន៣០នាក់។ នៅក្នុងចំណោម៣០នាក់ មាន២០នាក់បានមកនិយាយជាមួយខ្ញុំដើម្បីពិភាក្សារកផ្លូវរត់ ព្រោះសភាពការណ៍កំពុងតែមានការបាញ់គ្នាខ្លាំងរវាងខ្មែរក្រហម និងកងទ័ពវៀតណាមនៅក្នុងស្រុកស្នួល។ ខ្ញុំបាននិយាយថា យើងនាំគ្នារត់ប៉ះចំក្រុមកងទ័ពវៀតណាម យើងទាំងអស់គ្នាច្បាស់ជារស់ តែបើសិនយើងទាំងអស់គ្នារត់ចំខ្សែត្រៀមរបស់ខ្មែរក្រហមដឹងថាស្លាប់ទាំងអស់គ្នាជាមិនខាន។ និយាយគ្នារួចយើងមិនបានរត់ត្រឡប់ថយក្រោយទេ គឺដើរទៅមុខរហូតទាល់បានជួបកងទ័ព៣០៩ នៅខេត្តកំពង់ចាម។

### សិស្សានុសិស្សសួរសំណួរ៖ តើឆ្នាំណាដែលលំបាកវេទនាខ្លាំង ?

ទេព ឃី អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានរៀបរាប់ថា ឆ្នាំដែលលំបាកវេទនាខ្លាំង គឺឆ្នាំ១៩៧៧ ដល់១៩៧៩ គឺខ្មែរក្រហមជម្លៀសខ្ញុំចេញពីភូមិស្រុក ហើយឲ្យទៅធ្វើស្រែ។ ដោយសារតែខ្ញុំមានបងប្អូនច្រើន ដូច្នេះខ្មែរក្រហមបែងចែកបងប្អូនខ្ញុំឲ្យរស់នៅបែកគ្នា។ បងប្អូនខ្ញុំច្រើន តែបានស្លាប់នៅក្នុងសម័យប៉ុលពត៥នាក់។ ខ្ញុំក៏ត្រូវងើបទៅធ្វើតាំងពីព្រឹករហូតដល់ម៉ោង៧:០០យប់ ទើបបានមកផ្ទះវិញ។ ជំនាន់នោះទាល់តែយើងទៅធ្វើការបានចុងភៅបើករបបឲ្យ បើសិនជាមិនទៅធ្វើការ ចុងភៅមិនឲ្យហូបទេ មានអ្នកខ្លះទៅធ្វើការទាំងឈឺរហូតដល់ស្លាប់ក៏មាន។

ជាកិច្ចបញ្ចប់វេទិកាអប់រំសហគមន៍ មេភូមិគ្គូលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ឈ្មោះ ម៉ាប់ ភ័ក្ត្រ ដែលជាជនជាតិដើមភាគតិចស្ទៀង បានឡើងបង្ហាញចំណាប់អារម្មណ៍ចំពោះការរៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) នេះថា ខ្ញុំពិតជាមានអារម្មណ៍សប្បាយចិត្តដែលឃើញក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មបានចុះមករៀបចំវេទិកាដើម្បីឲ្យអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហមបានមកជួបជុំនិយាយប្រាប់គ្នាពីដំណើរជីវិតដែលធ្លាប់បានឆ្លងកាត់ និងបានចែករំលែកដល់សិស្សានុសិស្សជំនាន់ក្រោយឲ្យបានយល់ច្បាស់ពីសម័យខ្មែរក្រហម។ ខ្ញុំបានសង្កេតឃើញចាស់ៗដែលជាអ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម និងក្មេងៗបានពិភាក្សាគ្នាជាក្រុម ដោយពួកគាត់បានចែករំលែកបទពិសោធដល់ក្មេងជំនាន់ក្រោយ។ ម្យ៉ាងវិញទៀត វាបានបង្កើតភាពស្និតស្នាលរវាងគ្នា ធ្វើឲ្យមនុស្សចាស់និងក្មេងកាន់តែមានភាពស្និទ្ធស្នាលល្អប្រសើរឡើង។ ចំពោះខ្ញុំការរៀបចំវេទិកាអប់រំសហគមន៍នេះមានតម្លៃយ៉ាងខ្លាំង ព្រោះមនុស្សចាស់បាននិយាយប្រាប់ក្មេងដែលគាត់មិនដែលធ្លាប់បានដឹងពីមុនមក។ ដូច្នេះខ្ញុំពិតជាអរគុណដល់ក្រុមការងារសម្រាប់ថ្ងៃនេះដែលបានធ្វើឲ្យប្រជាជនមានការជួបជុំគ្នា បង្កើតចំណេះដឹងដល់គ្នាទៅវិញទៅមកជាពិសេសក្មេងៗជំនាន់ក្រោយ។



មជ្ឈមណ្ឌលឯកសារកោះថ្ម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីជីវិតរស់នៅប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិចស្ទៀងនៅក្នុងរបបខ្មែរក្រហម នៅភូមិគ្គូលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀង នៅភូមិបុស្សតាអ៊ឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

ឡុង ដានី



មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀងភូមិបុស្សតាអ៊ឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀងភូមិបុស្សតាអ៊ឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចស្ទៀង និងកូនចៅជំនាន់ក្រោយចូលរួមចំនួន៤០ នាក់ ក្នុងចំណោមនោះមានស្រី២៨ នាក់។

ជាកិច្ចចាប់ផ្តើមលោកមេភូមិ កង យឺន បានរៀបរាប់ថា ចាស់ៗដែលនៅរស់នៅក្នុងភូមិបុស្សតាអឹម បានដំណាលតៗមកថា កាលពីដើមឡើយមានក្រុមគ្រួសារជនជាតិដើមភាគតិចស្ទៀងមួយគ្រួសារ មានកូនប្រុសបីនាក់ឈ្មោះថា អឹម, ពេជ្រ និងម៉ៅ។ នៅពេលកូនប្រុសទាំងបីនាក់នៃគ្រួសារនេះធំដឹងក្តីឡើង និងមានប្រពន្ធកូនរៀងៗខ្លួន កូនប្រុសៗទាំងបីនាក់បាននាំប្រពន្ធកូនទៅធ្វើស្រែចម្ការនៅតាមកន្លែងផ្សេងៗពីគ្នា ប៉ុន្តែនៅមិនឆ្ងាយពីគ្នាប៉ុន្មានឡើយ។ ក្រុមគ្រួសារពេជ្របានទៅកាប់ឆ្ការដីបុស្សធ្វើស្រែចម្ការនិងរស់នៅ បន្ទាប់មកទីកន្លែងនោះត្រូវបានហៅថាភូមិស្រែតាពេជ្រ។ គ្រួសារ ម៉ៅ បានទៅរស់នៅធ្វើស្រែចម្ការនៅ ទីតាំងមួយដែលបច្ចុប្បន្នប្រជាជនបានដាក់



ឈ្មោះថា ភូមិជាំតាម៉ៅ។ ចំណែកក្រុមគ្រួសារឈ្មោះអឹមបានកាប់ឆ្ការដីបុស្សផ្ទើស្រែចម្ការ និងរស់នៅទីតាំងភូមិបុស្សតាអឹមសព្វថ្ងៃនេះ។ តាអឹម និងក្រុមគ្រួសារជាមនុស្សមានសន្តានចិត្តល្អចេះចែករំលែកដល់ប្រជាជនផ្សេងៗទៀតនៅក្នុងភូមិ។ សេចក្តីល្អនេះបានធ្វើឲ្យអ្នកភូមិស្រឡាញ់ចូលចិត្ត និងកោតសរសើរតាអឹម។ នៅពេលតាអឹម ចាស់ជរាស្លាប់ទៅ អ្នកភូមិបាននាំគ្នាហៅឈ្មោះភូមិនេះថាជាភូមិបុស្សតាអឹម រហូតមកដល់សព្វថ្ងៃនេះ ដើម្បីជាការរំឭកទឹកដល់តាអឹម ដែលបានកាប់ឆ្ការដីបុស្សនៅក្នុងភូមិនេះមុនគេ និងសេចក្តីល្អដែលតាអឹមបានធ្វើចំពោះអ្នកភូមិកាលពីពេលនោះ។ បច្ចុប្បន្នភូមិបុស្សតាអឹម មានប្រជាពលរដ្ឋរស់នៅចំនួន ២៨៥គ្រួសារ សរុប១០៦២នាក់ ស្រីមានចំនួន៥៤៩នាក់ ក្នុងនោះចាប់ពីអាយុ១៨ឡើងមានចំនួន៧០៥នាក់ ស្រីមានចំនួន ៣៥១នាក់។

ជាកិច្ចបន្ត លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម មានប្រសាសន៍ថា នៅថ្ងៃ២០ ឧសភាខាងមុខនេះ គឺជាទិវាជាតិនៃការចងចាំអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ជារៀងរាល់ឆ្នាំអាជ្ញាធរគ្រប់លំដាប់ថ្នាក់តែងតែដឹកនាំប្រារព្ធទិវាជាតិនៃការចងចាំ ២០ ឧសភា គឺដើម្បីរំឭកដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់ និងការឈឺចាប់ពីឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហមនេះ និងទប់ស្កាត់កុំឲ្យរបបនេះវិលត្រឡប់មកវិញម្តងទៀត។ យើងទាំងអស់គ្នាត្រូវចូលរួមថែរក្សាការពារសន្តិភាពឲ្យស្ថិតស្ថេរគង់វង្ស។



មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្មៀងភូមិបុស្សតាអ៊ឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចំពោះប្រវត្តិនៃថ្ងៃ២០ ខែឧសភានេះ លោក ឡុង ដានី បានបញ្ជាក់ជាសង្ខេបថា កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៨៣ សភានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានកំណត់យកថ្ងៃ២០ ឧសភា ជាទិវាចងកំហឹងលើរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ការកំណត់យកថ្ងៃ២០ ខែឧសភានេះ គឺដោយសារមេដឹកនាំខ្មែរក្រហមបានចាប់ផ្តើមប្រព្រឹត្តអំពើប្រល័យពូជសាសន៍យ៉ាងចំហចំពោះប្រជាជនកម្ពុជា ដោយអនុវត្តនូវគោលនយោបាយមួយចំនួនដូចខាងក្រោម៖



មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀងភូមិបុស្សតាអ៊ុម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

១) បក្សកុម្មុយនីស្តកម្ពុជាបានអបអរសាទរ និងកំណត់យកថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៣ ជាថ្ងៃកំណើតសហករណ៍។ ការបង្កើតសហករណ៍នេះគឺមេដឹកនាំខ្មែរក្រហមបានបង្ខំប្រជាជនលុបបំបាត់ចោលកម្មសិទ្ធិឯកជន និងរបបមូលធននិយម និងដើម្បីពង្រឹងវណ្ណៈកម្មករ និងកសិករ។ ការរស់នៅជាលក្ខណៈគ្រួសារខ្មែរអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយនោះ ត្រូវបានលុបបំបាត់ចោលទាំងស្រុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ខ្មែរក្រហមបង្កើតសហករណ៍មានន័យថាប្រជាជនត្រូវរស់នៅជាមួយគ្នា ធ្វើការជាមួយគ្នា ហូបចុកជាមួយគ្នា និងចែករំលែកការកម្សាន្តជាសមូហភាព។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មេដឹកនាំខ្មែរក្រហមបានរៀបចំជាសហករណ៍ជាពីរកម្រិត គឺសហករណ៍កម្រិតទាប ដែលមានសមាជិក៣០០ទៅ៤០០នាក់ ឬក៏មួយភូមិទាំងមូល និងសហករណ៍កម្រិតខ្ពស់ដែលរួមមានសមាជិក១ពាន់គ្រួសារ ឬក៏មួយឃុំទាំងមូល។ ក្រោយពេលឡើងកាន់អំណាចនៅថ្ងៃ១៧ មេសា ១៩៧៥ ខ្មែរក្រហមបានអនុវត្តនូវគោលនយោបាយសហករណ៍នេះ គឺបានប្រែក្លាយប្រជាជនទៅជាទាសករដាច់ថ្លៃរបស់អង្គការខ្មែរក្រហម ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការងារពលកម្មធ្ងន់ធ្ងរហួសកម្លាំង ធ្វើទារុណកម្ម ឈឺគ្មានថ្នាំព្យាបាល និងសម្លាប់រង្គាលជាដើម។

២) ថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រកាសចេញនូវគោលនយោបាយរួមមាន៖ ការជម្លៀសប្រជាជន ការលុបបំបាត់ទីផ្សារ រូបិយប័ណ្ណ ដកយកក្រដាសប្រាក់ដែលខ្លួនបានបោះពុម្ពរួច ផ្សឹកព្រះសង្ឃ បង្កើតផ្ទះបាយរួម បណ្តេញជនជាតិវៀតណាម បញ្ជូនកងទ័ពទៅព្រំដែន បិទមន្ទីរពេទ្យនៅភ្នំពេញ បិទសាលាអនុវិទ្យាល័យ វិទ្យាល័យ និងមហាវិទ្យាល័យជាដើម ដូច្នេះថ្ងៃ២០ឧសភា គឺជាថ្ងៃអនុវត្តគោលនយោបាយប្រល័យពូជសាសន៍នៅកម្ពុជា។

នៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ទិវាចងកំហឹងនេះត្រូវបានប្តូរមកជាទិវាចងចាំវិញ ពីព្រោះប្រទេសកម្ពុជា បានឈានចូលមកដល់ដំណាក់កាលនៃការបង្រួបបង្រួម និងផ្សះផ្សាជាតិ។ នៅឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី២០ ខែឧសភា ជា «ទិវាជាតិនៃការចងចាំ»។ ការកំណត់យកថ្ងៃនេះធ្វើជាថ្ងៃបុណ្យជាតិផ្លូវការ សម្រាប់ជាការរំឭកដល់ជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្ម ដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

បន្ទាប់មកអ្នកចូលរួមក្នុងវេទិកានេះ ឡើងបង្ហាញនូវចំណាប់អារម្មណ៍ដូចខាងក្រោម៖

**ញ៉ូ ឆាន** ជនជាតិដើមភាគតិចស្ទៀង មានអាយុ៦៦ឆ្នាំ ភេទប្រុស មានទីកន្លែងកំណើតនៅក្នុងភូមិបុស្សតាអឹម ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្ននេះខេត្តត្បូងឃ្មុំ បានរៀបរាប់ថា ឪពុកម្តាយខ្ញុំបានស្លាប់អស់ហើយ ខ្ញុំមានបងប្អូន៣នាក់ ប្រុស២នាក់។ ខ្ញុំមានប្រពន្ធឈ្មោះ សាំង ស មានអាយុ៦២ឆ្នាំ និងមានកូន៤នាក់ ក្នុងនោះស្រី២នាក់។ នៅឆ្នាំ១៩៧០ កាលខ្ញុំនៅតូចមានទាហានអាមេរិកាំង និងកងទ័ពវៀតកុង ចូលមកនៅក្នុងភូមិ។ ពេលចូលឆ្នាំ១៩៧៣ ខ្មែរក្រហមបានរៀបចំជាសហករណ៍ធ្វើចម្ការរួមគ្នាតែបានផលមកចែកគ្នា ព្រោះកាលនោះប្រជាជននៅ ហូបបាយតាមផ្ទះនៅឡើយ។ ចូលដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានខ្មែរក្រហមបានចាត់ឲ្យទៅរៀននៅសាលាស២០០ នៅភូមិភាគ បានរយៈពេលមួយខែ បន្ទាប់មកបញ្ជូនទៅធ្វើយោធានៅភ្នំពេញ។ ប៉ុន្តែដោយសារខាងសហជីពត្រូវការកម្មករ ខ្មែរក្រហមចាត់ក្រុមរបស់ខ្ញុំមានសមាជិកប្រហែលជា ១០នាក់ឲ្យចូលនៅក្នុងសហជីពវិញ។ កាលពីសម័យខ្មែរក្រហម គឺពិបាកណាស់ ពីព្រោះខ្មែរក្រហមបានប្រើប្រជាជនឲ្យធ្វើការ ទាំងយប់ថ្ងៃលើសពីកម្លាំង ចំណែកការហូបចុកក៏មិនបានគ្រប់គ្រាន់ ជាហេតុធ្វើឲ្យប្រជាជននៅក្នុងសម័យនោះបានស្លាប់ច្រើន។ នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅនៅខាងពោធិ៍សាត់ ឲ្យទៅធ្វើជាកងចល័តប្រមូលស្រូវ និងអង្ករ។ នៅឆ្នាំ១៩៨០ ខ្ញុំធ្វើដំណើរមកជួបជុំបងប្អូននៅស្រុកកំណើតវិញ ហើយខ្ញុំបានយកប្រពន្ធ និងរស់នៅក្នុងភូមិបុស្សតាអឹម នេះរហូតមក។

មេភូមិបុស្សតាអឹម ឈ្មោះ **ភង យឹន** អាយុ៧១ឆ្នាំ បានមានប្រសាសន៍ថា ការរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រនេះ មានផលប្រយោជន៍ច្រើនចំពោះក្មេងៗជំនាន់ក្រោយ បានដឹងអំពីប្រវត្តិសាស្ត្រ និងបានស្តាប់រឿងរ៉ាវជីវិតដែលលោកតាលោកយាយក៏ដូចជារូបខ្ញុំផ្ទាល់ ធ្លាប់បានឆ្លងកាត់នៅក្នុងសម័យខ្មែរក្រហម និយាយរៀបរាប់ប្រាប់ទៅ ដល់ពួកគាត់ដែលជាទំពាំងស្នងឫស្សីសម្រាប់ប្រទេសជាតិ ឲ្យបានដឹងពីការលំបាកវេទនារបស់ប្រជាជនដែលធ្លាប់រស់នៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩) ថាតើពួកគាត់ជួបប្រទះទុក្ខលំបាកយ៉ាងម៉េចខ្លះ ទម្រាំបានរស់មកដល់សព្វថ្ងៃ។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានរៀបចំវេទិការអប់រំប្រវត្តិសាស្ត្រសហគមន៍នៅក្នុងភូមិបុស្សតាអឹមនេះ។ វាជាឱកាសល្អមួយដែលរូបខ្ញុំ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀត មានពេលវេលា ចែករំលែករឿងរ៉ាវផ្ទាល់ខ្លួន ដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹង ហើយម្យ៉ាងទៀតខ្ញុំគិតថាក្មេងៗ គួរតែសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រនេះឲ្យបានច្រើន។







មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀងនៅភូមិបុស្សតាអ៊ឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


















# បណ្ណាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម

បណ្ណាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូនសិស្ស និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។ បណ្ណាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម គឺជាកន្លែងប្រមូលផ្តុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅបណ្ណាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម មាន៥ប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការផ្ទៀងផ្ទាត់ទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំ គឺជាខ្សែភាពយន្ត ឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម សាធារណជនអាចមកស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យមជ្ឈមណ្ឌលឯកសារកោះថ្ម

មានទីតាំងស្ថិតនៅផ្លូវលេខ៧ ភូមិក្តុលក្រោម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ព្រឹក ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២:០០ ដល់ម៉ោង ៥:០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងលោកឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម តាមរយៈទូរសព្ទលេខ: ០១២ ៧៧២ ០៧៧ ឬ អ៊ីម៉ែល: truthdany.l@ dccam.org ។

សូមអរគុណ!











# រឿងរ៉ាវរបស់ ឯម ម៉ើ ក្នុងរបបខ្មែរក្រហម

ឈុំ រ៉ា



ឯម ម៉ើ អាយុ៩១ឆ្នាំ និងប្រពន្ធកំពុងផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មៗ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯម ម៉ើ ភេទប្រុស កើតនៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣១បានរៀបរាប់ថា ខ្ញុំមានបងប្អូនចំនួន៧ នាក់ (ប្រុស៦នាក់ និងស្រី១នាក់) ហើយខ្ញុំគឺជាកូនច្បងៗ ខ្ញុំមានម្តាយឈ្មោះ ឡុ ឈុន បានស្លាប់ តាំងពីខ្ញុំមានអាយុ១២ឆ្នាំ ចំណែកឪពុកឈ្មោះ ឯមៗ ម្តាយឪពុករបស់ខ្ញុំគឺជាជនជាតិខ្មែរ មានស្រុកកំណើតនៅភូមិសាទុំ ឃុំដាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ (កាលពីមុនខេត្តកំពង់ចាម)ៗ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រច្រើនទេៗ បងប្រុសរបស់ខ្ញុំបានជំរុញឲ្យខ្ញុំចូលរៀនដែរប៉ុន្តែខ្ញុំមិនចង់បែកពីម្តាយៗ កាលពីតូច ខ្ញុំគ្មានសម្លៀកបំពាក់ទេ ខ្ញុំបានយកសម្បកឈើមកដំឲ្យទក់ដើម្បីបាំងខ្លួនៗ នៅពេលខ្ញុំអាយុ១១ឆ្នាំ ខ្ញុំបានចូលរៀននៅវត្តក្រវៀនៗ ខ្ញុំរៀនបានរយៈពេលបួនឆ្នាំ ព្រះចៅអធិការវត្តឈ្មោះ វែង បានឲ្យខ្ញុំបួសៗ ខ្ញុំបានរៀនធម៌វិន័យ និងរៀនអក្សរសាស្ត្រ ពីគ្រូ អ៊ុង, គ្រូ វែង និងគ្រូជីងៗ អំឡុងពេលដែលសិក្សានៅក្នុងវត្ត គឺមានសិស្សចំនួន៤០នាក់ នៅក្នុងនោះមានសិស្សស្រីចំនួន៥ នាក់តែប៉ុណ្ណោះៗ កាលពីសង្គមចាស់ ប្រជាជនមិនសូវឲ្យកូនស្រីសិក្សារៀនសូត្រទេ ព្រោះខ្លាចកាលណាកូនស្រីមានចំណេះដឹងច្រើន គឺចេះសរសេរសំបុត្រស្នេហាៗ ខ្ញុំបួសបានរយៈពេល៨វស្សា គឺបួសសាមណេរបានរយៈពេល៥ព្រះវស្សា និងបួសភិក្ខុបានរយៈពេល៣វស្សាៗ ក្រោយមក ខ្ញុំបានសឹកមកប្រកបរបរធ្វើស្រែចម្ការវិញៗ ក្រោយពីសឹករួច មេឃុំហៅខ្ញុំទៅឲ្យជួយសរសេររបាយការណ៍ជំនួសស្មៀន ព្រោះស្មៀន



ស្តូបគោរពវិញ្ញាណក្ខន្ធដែលសាងសង់តាំងពីសម័យសង្គ្រាមវៀតណាម ដើម្បីឧទ្ទិសដល់អ្នកដែលបានបាត់បង់ជីវិតដោយសារការទម្លាក់គ្រាប់បែក។
(ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មិនសូវធ្វើការ ហើយផឹកស្រា។ ខ្ញុំបានធ្វើការជំនួសស្មៀនអស់រយៈពេលបីខែ ក៏សុំមេឃុំមកលេងផ្ទះ ព្រោះអត់មានអ្នកជួយធ្វើការផ្ទះជំនួសឪពុកម្តាយ។ កាលពីសង្គមចាស់ នៅក្នុងភូមិសាទុំមានផ្លូវតែមួយខ្សែប៉ុណ្ណោះ។ ដំបូងបារាំងបានចូលមកដាំដើមកៅស៊ូ នៅក្រឡឹងសិទ្ធិ និងខ្នាយ ដែលមានកម្មករជាជនជាតិខ្មែរ និងជនជាតិវៀតណាម។ ឪពុករបស់ខ្ញុំមានចំណេះដឹង ដូច្នេះខាងរាជការឲ្យគាត់វាស់វែងដីធ្លីសម្រាប់ធ្វើផ្លូវ។ នៅសង្គមចាស់អ្នកចេះដឹងជនជាតិបារាំងហៅឈ្មោះថា ជី។ បារាំងបានធ្វើផ្លូវពីស្រុកឡុកនិញទៅព្រៃនគរ និងភ្ជាប់មកភូមិសាទុំ ភូមិប្រិយ៍, អូរអង្កាម, ក្រឡឹងសិទ្ធិ រហូតទៅដល់មេមត់។ កាលពីដើមប្រជាជននៅក្នុងភូមិសាទុំមិនហ៊ានចូលព្រៃទេព្រោះខ្លាចសត្វខ្លា និងដំរី។ ខ្ញុំបានជួបសម្តេចព្រះ នរោត្តម សីហនុ ម្តង ពេលដែលទ្រង់ចុះមកដល់ស្រុកមេមត់។ កាលពីដើម នៅក្នុងភូមិសាទុំ មានផ្ទះចំនួន១៧ខ្នងតែប៉ុណ្ណោះ។ ភូមិសាទុំក្លាយមកពីរឿងដំណាល «ស្រីយំ» ព្រោះមានស្រីម្នាក់ដើរមកពីខាងភូមិព្រៃ ប៉ុន្តែដោយសារចុកជើងខ្លាំងពេកក៏អង្គុយយំ។ ក្រោយមកដោយសារអ្នកស្រុកនិយាយមិនច្បាស់ ក៏បាននិយាយតៗគ្នាថា «សាទុំ»។ ប្រជាជនខ្លះហៅភូមិនេះថា «ស៊ុំ»។ ចំណែកប្រជាជនខ្លះទៀតដំណាលថា ពីដើមមានសត្វបក្សីជាច្រើនហើរមកទុំលើដើមពោធិ៍ ហើយក៏ហើរត្រឡប់ទៅវិញ ទើបអ្នកភូមិនាំគ្នាហៅថា «ស្រទុំ» ជាប់មក។

កាលពីសម័យបារាំង ប្រជាជននាំគ្នាវេចខោអាវត្រៀមរួចជាស្រេច ហើយពេលឮសំឡេងគ្រាប់កាំភ្លើងម្តងៗក៏នាំគ្នាចូលរត់ពួននៅក្នុងព្រៃព្រោះខ្លាចចោរប្លន់។ ខ្ញុំដឹងថាចោរទាំងអស់នោះមានខ្មែរ និងវៀតណាមខ្លះ។ បារាំងបានយកជនជាតិវៀតណាមមកពីហាណូយមកចៀរជ័រកៅស៊ូ ជំនួសឲ្យជនជាតិខ្មែរ ព្រោះបារាំងប្រើខ្មែរមិនបាន។ នៅពេលដែលខ្ញុំពេញកំលោះ ខ្ញុំសុំម្តាយរៀបការជាមួយនារីម្នាក់ដែលខ្ញុំស្រឡាញ់នៅក្នុងភូមិ ប៉ុន្តែដំបូងម្តាយរបស់ខ្ញុំបដិសេធ។ ខ្ញុំនៅតែចចេសចង់រៀបការជាមួយនារីនោះដដែលដែលត្រូវជាកូនស្រីរបស់ប៉ូលីសឈ្មោះ ឡឹក និងប្រពន្ធឈ្មោះយ៉ុង។ ក្រោយមក ខ្ញុំបានរៀបការជាមួយនារីនោះបានកូនពីរនាក់ ហើយកូនម្នាក់បានស្លាប់នៅក្នុងសម័យខ្មែរក្រហម។ ប្រពន្ធដើមរបស់ខ្ញុំមិនសូវរវល់ជាមួយគ្រួសារ និងខ្វល់ខ្វាយចំពោះកូនៗទេ។ ដោយសារតែយើងរស់នៅមិនចុះសម្រុងនឹងគ្នា ខ្ញុំបាននិយាយជាមួយប្រពន្ធរបស់ខ្ញុំថា បើយើងមិនស្រឡាញ់គ្នាទេយើងលែងគ្នា។ ក្រោយពេលខ្ញុំបានលែងលះជាមួយប្រពន្ធដើមរួចរាល់ហើយ ខ្ញុំបានរៀបការជាមួយប្រពន្ធក្រោយឈ្មោះ ឆន និងមានកូនចំនួន៧នាក់។ ក្រោយមក ប្រពន្ធក្រោយរបស់ខ្ញុំពិការដៃម្ខាងដោយសារពស់ចឹក។

នៅពេលមានបាតុកម្មទម្លាក់សម្តេចសីហនុ ខ្ញុំចាប់ផ្តើមរកស៊ីលក់ដូរអង្ករ។ ខ្ញុំធាក់កង់ដឹកអង្ករពីមេមត់យកទៅលក់ឲ្យកងទ័ពវៀតណាម។ ខ្ញុំដឹកអង្ករម្តងបាន២០គីឡូក្រាម ហើយក្នុងមួយគីឡូក្រាមខ្ញុំចំណេញមួយរៀល។ នៅពេលយប់ខ្ញុំមិនសូវបានដេកទេ ព្រោះត្រូវចេញទៅដឹកអង្ករយកទៅលក់ឲ្យកងទ័ពវៀតកុង។ ខ្ញុំដឹកជញ្ជូនអង្ករឲ្យកងទ័ពវៀតកុងនៅម្តុំត្រពាំងតាហត និងត្រពាំងឈើខ្ទីម។ កាលនោះមានអ្នកដឹកអង្ករលក់ច្រើននាក់ មកពីឃុំដាំក្រវៀន។ ខ្ញុំលក់អង្ករគិតជាលុយខ្មែរ ហើយមេការដែលរង់ចាំទិញអង្ករឈ្មោះ សៅ ភុក។ ដោយសារតែ

មានសង្គ្រាមរវាងអាមេរិកាំង និងកងទ័ពវៀតកុង ខ្ញុំមិនបានចាយលុយទេ ហើយក្របីញីរបស់ខ្ញុំមួយក្បាល និងក្របីឈ្មោលមួយក្បាល លក់បានត្រឹមតែ១០០០រៀលតែប៉ុណ្ណោះ។

កងទ័ពវៀតកុង បានសង់មន្ទីរពេទ្យនៅក្នុងព្រៃកាដូនម៉ាច និងព្រៃតាសីង។ នៅមន្ទីរពេទ្យនោះគឺមានផ្នែកវះកាត់ដែលប្រើឧបករណ៍ទំនើបៗ។ កងទ័ពវៀតកុងបានជួលខ្មែរឲ្យជួយបកប្រែ ហើយកងទ័ពវៀតកុងខ្លះអាចនិយាយភាសាខ្មែរបានប៉ុន្តែមិនសូវច្បាស់។ ខ្ញុំបានយកម្តាយក្មេករបស់ខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យរបស់វៀតកុង ក្រោយមកម្តាយក្មេករបស់ខ្ញុំបានជាសះស្បើយឡើងវិញ។ ក្រោយពេលយោធាអាមេរិកស៊ើបដឹងថាមានកងទ័ពវៀតកុងទើបមានការទម្លាក់គ្រាប់បែកដើម្បីសម្លាប់កងទ័ពវៀតកុង។ គ្រាប់បែកបេ-៥២ ជាច្រើនគ្រាប់បានផ្ទុះរង្គើរដល់ផ្ទះប្រជាជនដែលរស់នៅក្នុងភូមិសាទុំ និងផ្ទះខ្លះដែលប្រក់ស្លឹកទ្រាំងបានរបើកដំបូល។ នៅវេលាម៉ោង៥ល្ងាច មានការទម្លាក់គ្រាប់លើទីជម្រកកងទ័ពវៀតកុង បណ្តាលឲ្យកងទ័ពវៀតកុង និងប្រជាជនមួយចំនួនបានស្លាប់ ហើយប្រជាជននៅក្នុងភូមិសាទុំមួយចំនួនទៀតរងរបួស។ នៅអំឡុងពេលសង្គ្រាមរវាងអាមេរិក និងកងទ័ពវៀតកុងបានផ្ទុះឡើង ប្រជាជននៅក្នុងភូមិសាទុំ បានភៀសខ្លួនទៅរស់នៅភូមិជាំក្រវៀន និងភូមិដូង។ នៅពេលចប់សង្គ្រាម ទើបប្រជាជននាំគ្នាមករស់នៅក្នុងភូមិវិញ។

នៅសម័យខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិសាទុំឲ្យទៅនៅភូមិខ្វូរ។ ខ្មែរក្រហមចាត់តាំងឲ្យខ្ញុំនៅកងសិប្បកម្ម ធ្វើនង្គ័ល និងរនាស់។ ចំណែកប្រពន្ធកូនរបស់ខ្ញុំនៅក្នុងភូមិសាទុំដដែល។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានជម្លៀសប្រពន្ធរបស់ខ្ញុំឲ្យមករស់នៅភូមិខ្វូរជាមួយខ្ញុំដែរ។ ប្រធានកងបានចាត់តាំងខ្ញុំឲ្យទៅរកត្រី និងសាច់មកដាក់នៅក្នុងសហករណ៍ ចំណែកប្រពន្ធរបស់ខ្ញុំ ប្រធានកងចាត់តាំងឲ្យទៅស្ទូងស្រូវ និងធ្វើស្រែ។ មួយឆ្នាំក្រោយមក ខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំឲ្យទៅនៅភូមិតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ វិញ។ នៅទៅនោះ ខ្ញុំធ្វើស្រែ លើកប្រព័ន្ធភ្លឺស្រែ និងជីកប្រឡាយ។ តមក ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅនៅសហករណ៍ ក្នុងស្រុកឆ្លូង ខេត្តក្រចេះ។ ប្រធានសហករណ៍បានចោទប្រកាន់ខ្ញុំថា លួចក្របី ហើយយកកាំភ្លើងមកភ្ជង់ក្បាលខ្ញុំ។ ប្រធានសហករណ៍យកខ្ញុំទៅឃុំរយៈពេលមួយយប់។ ខ្ញុំបាននិយាយថាខ្ញុំមិនបានធ្វើអ្វីខុសនោះទេ ប្រសិនបើមិត្តសម្លាប់ខ្ញុំក៏ខ្ញុំមិនខ្លាចស្លាប់ដែរ។ ព្រឹកឡើងប្រធានសហរណ៍ដោះលែងឲ្យខ្ញុំត្រឡប់មកផ្ទះវិញ ហើយបន្ទាប់មកបានចាត់តាំងខ្ញុំឲ្យបររទេះដឹកសំណាប។ ចំណែកកូនរបស់ខ្ញុំប្រធានកងប្រើឲ្យរើសអាចម៍គោដើម្បីធ្វើជី។ ចំពោះម្ហូបអាហារគឺមានតែបបរ ប៉ុណ្ណោះ ហើយខ្ញុំហូបមិនដែលឆ្អែតទេ។ ថ្ងៃមួយ ខ្ញុំបានបររទេះទៅដឹកសំណាបឲ្យអ្នកស្ទូង។ ខ្ញុំគិតក្នុងចិត្តថាប្រសិនបើខ្ញុំមិនលួចច្បាស់ជាដាច់ពោះស្លាប់មិនខាន ដូច្នេះខ្ញុំបានយកផ្លែសន្ទូចលាក់ទុកនៅក្នុងហោប៉ៅខោ។ នៅពេលខ្ញុំទៅដល់បឹង ខ្ញុំយកផ្លែសន្ទូចចេញពីហោប៉ៅដើម្បីស្ទូចត្រី។ ក្រុមដឹកសំណាបរបស់ខ្ញុំមានគ្នាបួននាក់ ដូច្នេះខ្ញុំនិយាយប្រាប់អ្នកនៅក្នុងក្រុមថាប្រសិនបើយើងចង់ហូបឆ្អែតយើងកុំរាយការណ៍ឲ្យអ្នកផ្សេងដឹង។ នៅថ្ងៃនោះយើងស្ទូចបានត្រី និងបានហូបឆ្អែត។ ខ្ញុំបានលួចខ្ចប់ត្រីយកទៅឲ្យប្រពន្ធនិងកូនរបស់ខ្ញុំនៅផ្ទះថែមទៀត។ នៅទីនោះឪពុកក្មេករបស់ខ្ញុំបានស្លាប់ដោយសារអត់អាហារ។ ក្រោយមកទៀតខ្មែរក្រហមឲ្យខ្ញុំធ្វើជាជាងឈូសឈើ និងសសរផ្ទះ។ មេកងបានកំណត់ឲ្យខ្ញុំឈូសសសរផ្ទះឲ្យបាន២ទៅ៣ដើមក្នុងមួយថ្ងៃ។ ប្រសិនបើខ្ញុំឈូសមិនហើយ អង្គការនឹងយកខ្ញុំទៅរៀនសូត្រ។ ខ្ញុំរស់នៅក្នុងសហករណ៍ក្នុងស្រុកឆ្លូងរយៈពេលមួយឆ្នាំ ទើបខ្មែរក្រហមជ្រើសរើសខ្ញុំឲ្យទៅនៅស្រែរនាម ឃុំយ្សឹម ស្រុកឈ្នួល ខេត្តក្រចេះវិញ។ នៅថ្ងៃនោះខ្មែរក្រហមបានជជែកគ្នាថានឹងបើករថយន្តទៅក្រុងក្រចេះទាំងយប់។ ក្រោយពេលខ្ញុំស្តាប់ឮដំណឹងនេះ ខ្ញុំជាមួយកូនៗនិងប្រពន្ធខ្ញុំលួចឡើងជិះរថយន្ត

ខ្មែរក្រហមនោះ។ ព្រឹកឡើងខ្ញុំនិងគ្រួសារបានចុះពីលើឡាន ឃើញដូច្នេះអ្នកបើករថយន្តបានសួរថា ខ្ញុំតើលោកពូឡើងជិះលើឡានតាំងពីពេលណា។ ខ្ញុំបានប្រាប់តាមត្រង់ថា លួចឡើងតាំងពីយប់មិញម្ល៉េះ បន្ទាប់មកខ្មែរក្រហមបានសួរខ្ញុំថាតើលោកពូចង់ទៅណា? ខ្ញុំបានឆ្លើយថា ខ្ញុំមិនដឹងទៅណាទេ។ ខ្មែរក្រហមបាននាំខ្ញុំទៅរកកន្លែងសម្រាក និងឲ្យអង្ករមកខ្ញុំដើម្បីដាំបាយហូប។ នៅថ្ងៃបន្ទាប់ ខ្ញុំនិងគ្រួសារបានដើររហូតទៅដល់ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ។ នៅទីនោះ ខ្ញុំឃើញយោធា និងត្រីងៀតជាច្រើន។ ដោយសារតែខ្ញុំឃ្លានខ្លាំងពេក ទើបខ្ញុំដាច់ចិត្តសុំត្រីងៀតពីយោធាយកមកហូប។ នៅខណៈនោះប្រធានសហករណ៍ថ្មគ្រែបានសួរខ្ញុំថា លោកពូមកពីណា? ខ្ញុំឆ្លើយថា ខ្ញុំមិនដឹងមកពីណាទេព្រោះជិះឡានពេលយប់។ ខ្ញុំនិយាយទៅកាន់ប្រធានសហករណ៍ថា បើមិត្តចង់សម្លាប់ខ្ញុំក៏សម្លាប់ចុះ។ ប៉ុន្តែប្រធានសហករណ៍មិនបានធ្វើបាបខ្ញុំទេ ហើយបានចាត់តាំងខ្ញុំទៅធ្វើសម្បុកមាន់។ ដោយសារតែឃ្លានខ្លាំងពេក ខ្ញុំបានលួចពងមាន់នៅក្នុងសម្បុកមួយគ្រាប់។ ពេលនោះខ្ញុំចេះជាងឈើ ដូច្នេះប្រធានសហករណ៍ឲ្យខ្ញុំធ្វើជាងសង់ផ្ទះ។ ថ្ងៃមួយមានអ្នកឃ្វាលគោម្នាក់បានប្រាប់ខ្ញុំថា នៅផ្ទះដែលខ្ញុំរស់នៅមានមនុស្សស្លាប់ទាំងគ្រួសារ ឪពុក ម្តាយ និងកូន គឺស្លាប់ដោយសារលេបថ្នាំព្រោះតែស្តាយទ្រព្យសម្បត្តិ។ អ្នកឃ្វាលគោបានសួរខ្ញុំថា ខ្លាចខ្មោចដែរឬទេ? ខ្ញុំឆ្លើយថា ស្លាប់ហើយគ្មានអ្វីត្រូវខ្លាចឡើយ។ មិនបានប៉ុន្មានថ្ងៃផង ខ្មែរក្រហមជម្លៀសខ្ញុំតាមកាណូតទៅស្រុកស្ទឹងត្រង់ បន្ទាប់មកជិះឡានបន្តទៅភូមិតាអុង ឃុំតាអុង ស្រុកចំការលើ ដោយគ្មានបាយហូបឡើយ គឺយើងហូបបាយលាយចេក។ ខ្មែរក្រហមបានប្រើខ្ញុំឲ្យរែកទឹក ជីកដី ធ្វើដី ដើម្បីស្រោចស្ពៃ ប៉ុន្តែដោយសារតែខ្ញុំអត់បាយយូរថ្ងៃទើបខ្ញុំគ្មានកម្លាំងរែកទឹក។ ខ្ញុំរស់នៅទីនោះបានកន្លះខែ កងទ័ពវៀតណាមចូលមកដល់ ហើយយើងក៏ធ្វើដំណើរដោយថ្មើរជើងមកស្រុកកំណើតវិញ។ ពេលខ្ញុំមកក្រុងសួង ខ្ញុំដើររើសក្តួរស្រូវ រួចបន្តដំណើរមករស់នៅក្នុងភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ រហូតមកដល់សព្វថ្ងៃ។



សាលាឃុំជាំក្រវៀន ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា )

រូបក្របមុខ៖
សម្តេច ហ៊ុន សែន សួរសុខទុក្ខប្រជាជនឃុំទន្លូង ដែលភៀសខ្លួនទៅរស់នៅតាមជំរំ
ក្នុងស្រុកស្នួលខេត្តក្រចេះ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្របក្រោយ៖
សម្តេច ហ៊ុន សែនបានដឹកនាំព្រះសង្ឃ និងប្រជាជនចូលរួមការប្រារព្ធពិធីមិទ្ទិញបង្កើតរណសិរ្សសាមគ្គី
សង្គ្រោះជាតិកម្ពុជា នៅលើទឹកដីស្រុកស្នួល ខេត្តក្រចេះ ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណះ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ១២ ៨៨២ ៥០៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 12 882 505 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Special Issue 2024 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.